ធនាគារជាតិ នៃ កម្ពុជា

ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.



# ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុ

២០២៣

# មាតិកា


**អារម្ភកថា** ........ i

**អក្សរកាត់** ........ iii

**ខ្លឹមសារសង្ខេប** ........ v

**ទស្សនវិស័យ និងហានិភ័យ** ........ viii

**I. ស្ថានភាពនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច** ........ ១

១.១ ស្ថានភាពវិស័យខាងក្រៅ ........ ១

ក. សេដ្ឋកិច្ចពិភពលោក ........ ១

ខ. ជញ្ជីងទូទាត់កម្ពុជា ........ ៣

ខ.១ គណនីចរន្តនិងដើមទុន ........ ៣

ខ.២ គណនីហិរញ្ញវត្ថុ ........ ៤

គ. អត្រាប្តូរប្រាក់ និងទុនបម្រុងអន្តរជាតិ ........ ៥

ប្រអប់ ១.១: ការវិភាគតារាងតុល្យការ ........ ៧

១.២ ស្ថានភាពសេដ្ឋកិច្ចក្នុងស្រុក ........ ៨

ក. កំណើនសេដ្ឋកិច្ច ........ ៨

ខ. ស្ថានភាពអតិផរណា និងរូបិយវត្ថុ ........ ១២

គ. វិស័យសារពើពន្ធ ........ ១៣

១.៣ សន្និដ្ឋាន ........ ១៥

**II. ប្រព័ន្ធធនាគារ៖ សមិទ្ធកម្ម និងស្ថិរភាព** ........ ១៦

២.១ ទិដ្ឋភាពប្រព័ន្ធធនាគារ ........ ១៧

២.២ គ្រឹះស្ថានធនាគារពាណិជ្ជ ........ ១៩

ក. អន្តរការីយកម្មឥណទាន និងហានិភ័យឥណទាន ........ ១៩

ខ. មូលនិធិ និងសន្ទនីយភាព ........ ២៨

គ. លទ្ធភាពស្វែងរកប្រាក់ចំណេញ និងភាពគ្រប់គ្រាន់នៃដើមទុន ........ ៣១

២.៣ វិស័យមីក្រូហិរញ្ញវត្ថុ ........ ៣៤

ក. សមិទ្ធកម្មនៃឥណទាន ........ ៣៥

ខ. គុណភាពឥណទាន ........ ៣៦

គ. ស្ថានភាពសន្ទនីយភាព និងមូលនិធិ ........ ៣៧

ឃ. លទ្ធភាពស្វែងរកប្រាក់ចំណេញ និងភាពគ្រប់គ្រាន់នៃដើមទុន ........ ៣៩

២.៤ គ្រឹះស្ថានធនាគារឯកទេស ........ ៤២

២.៥ សន្និដ្ឋាន ........ ៤៣

**III. វិស័យហិរញ្ញវត្ថុមិនមែនធនាគារ** ..... ៤៥
៣.១ ទីផ្សារទ្រព្យសកម្ម ..... ៤៥
ក. ទីផ្សារមូលបត្រកម្មសិទ្ធិ ..... ៤៥
ខ. ទីផ្សារមូលបត្របំណុល ..... ៤៦
ខ.១ មូលបត្ររដ្ឋ ..... ៤៦
ខ.២ សញ្ញាប័ណ្ណសាជីវកម្ម ..... ៤៧
៣.២ វិស័យធានារ៉ាប់រង ..... ៤៨
៣.៣ សន្និដ្ឋាន ..... ៥០
**IV. ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់** ..... ៥១
**ឧបសម្ព័ន្ធទី១** ..... ៥៧
**ឧបសម្ព័ន្ធទី២** ..... ៦១
**ឧបសម្ព័ន្ធទី៣** ..... ៦៧
**ឧបសម្ព័ន្ធទី៤** ..... ៧៣

# អារម្ភកថា

ក្រោយពីបានឆ្លងកាត់វិបត្តិកូវីដ-១៩ សេដ្ឋកិច្ចពិភពលោកបានប្រឈមជាមួយបញ្ហាផ្សេងទៀតជាបន្តបន្ទាប់ ជាពិសេសភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយ និងការរឹតបន្តឹងនយោបាយរូបិយវត្ថុនៅប្រទេសអភិវឌ្ឍន៍ ដើម្បីគ្រប់គ្រងកម្រិតខ្ពស់នៃអតិផរណា។ ទោះបីប្រឈមនឹងឧបសគ្គទាំងនេះក៏ដោយ សេដ្ឋកិច្ចពិភពលោករក្សាបានភាពធន់ ជាមួយនឹងអត្រាកំណើនវិជ្ជមាន ៣,២% នៅឆ្នាំ២០២៣ និងអតិផរណាបានថយចុះលឿនជាងការរំពឹងទុកនៅតាមតំបន់ជាច្រើន។

កម្ពុជា ដែលជាប្រទេសមានសេដ្ឋកិច្ចតូចនិងបើកចំហ ក៏បានទទួលរងផលប៉ះពាល់ពីបញ្ហាប្រឈមរបស់ពិភពលោកផងដែរ ក្នុងនោះ វិស័យកម្មន្តសាលកាត់ដេរ សំណង់ និងអចលនទ្រព្យបានទទួលរងផលប៉ះពាល់ខ្លាំង។ ប៉ុន្តែ កិច្ចខិតខំប្រឹងប្រែងក្នុងការធ្វើពិពិធកម្មមូលដ្ឋានឧស្សាហកម្មបានផ្តល់នូវផលវិជ្ជមាន ដោយសមាមាត្រនៃការនាំចេញផលិតផលមិនមែនកាត់ដេរបានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងអំឡុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ លើសពីនេះ ការងើបឡើងនៃវិស័យទេសចរណ៍និងតម្រូវការក្នុងស្រុក បានរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២៣ ឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត។

ប្រព័ន្ធធនាគារបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការរួមចំណែកគាំទ្រដល់ភាពរឹងមាំនៃសេដ្ឋកិច្ចកម្ពុជា។ បើទោះជាទទួលរងសម្ពាធពីកត្តាខាងក្រៅ ប្រព័ន្ធធនាគារកម្ពុជារក្សាបានភាពធន់ ឆ្លុះបញ្ចាំងតាមរយៈកម្រិតខ្ពស់នៃអនុបាតភាពគ្រប់គ្រាន់នៃដើមទុន និងសន្ទនីយភាព។ ទោះយ៉ាងណាធនាគារជាតិនៃកម្ពុជា បន្តស្មារតីប្រុងប្រយ័ត្នចំពោះការថមថយកំណើនឥណទាន ក្នុងបរិការណ៍នៃកំណើនអត្រាការប្រាក់ និងការកើនឡើងនៃអនុបាតឥណទានមិនដំណើរការបន្ទាប់ពីការបញ្ចប់វិធានការអនុគ្រោះបទប្បញ្ញត្តិនានា។

សម្រាប់ឆ្នាំ២០២៤ ទស្សនវិស័យសេដ្ឋកិច្ចពិភពលោកត្រូវបានព្យាករថានឹងប្រសើរឡើង ប៉ុន្តែហានិភ័យនៅតែស្ថិតក្នុងកម្រិតខ្ពស់។ ហានិភ័យចម្បងៗ ដែលអាចរារាំងដល់កំណើនសេដ្ឋកិច្ចពិភពលោកនិងតំបន់ រួមមាន ជម្លោះផ្នែកភូមិសាស្ត្រនយោបាយ ដែលអាចបង្កភាពរអាក់រអួលដល់ខ្សែច្រវាក់ផ្គត់ផ្គង់ និងឈានទៅដល់ការបែងចែកប្លុកពាណិជ្ជកម្ម ភាពមិនប្រាកដប្រជាជុំវិញបញ្ហាវិស័យអចលនទ្រព្យនៅប្រទេសចិន ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងការវាយប្រហារតាមសាយប័រ។ ហានិភ័យទាំងនេះប្រសិនបើកើតឡើង អាចនឹងប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចកម្ពុជា បង្កឱ្យមានការកើនឡើងនៃអត្រាអតិផរណានិងអត្រាប្តូរប្រាក់ ព្រមទាំងអាចដាក់សម្ពាធលើគុណភាពឥណទានក្នុងចំណោមក្រុមហ៊ុន-សហគ្រាស និងអង្គភាពគ្រួសារដែលមានបំណុលខ្ពស់។

ធនាគារជាតិនៃកម្ពុជា បន្តកិច្ចសហការជាមួយភាគីពាក់ព័ន្ធទាំងអស់ ដើម្បីតាមដានឱ្យបានជិតដល់នូវការវិវត្តថ្មីៗ និងហានិភ័យចំពោះស្ថិរភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ របាយការណ៍ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុឆ្នាំ២០២៣ គឺជាមធ្យោបាយដ៏សំខាន់មួយ សម្រាប់ធនាគារជាតិនៃកម្ពុជាក្នុងការផ្សព្វផ្សាយការវិភាគ និងការវាយតម្លៃស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា ដោយបានបង្ហាញពី

ហានិភ័យដែលមាននៅក្នុងវិស័យហិរញ្ញវត្ថុ ជាពិសេសក្នុងប្រព័ន្ធធនាគារ និងផ្តល់ជាជម្រើសគោលនយោបាយក្នុងការគ្រប់គ្រងហានិភ័យទាំងនោះ។ ខ្ញុំជឿជាក់ថារបាយការណ៍ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុនេះ នឹងជួយដល់គ្រប់ភាគីពាក់ព័ន្ធ និងសាធារណជនទូទៅ ក្នុងការកំណត់ជាមុននូវហានិភ័យដែលអាចគំរាមកំហែង ដល់ស្ថិរភាពហិរញ្ញវត្ថុ និងជំរុញកិច្ចសហការរួមគ្នារវាងភាគីពាក់ព័ន្ធជាមួយនឹងធនាគារជាតិនៃកម្ពុជា ដើម្បីអនុវត្តវិធានការសមស្របឱ្យបានទាន់ពេលវេលា។

ថ្ងៃចន្ទ ១៣កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤

**ទេសាភិបាល**

**ជា សិរី**

# អក្សរកាត់

| | | |
|---|---|---|
| ផ.ស.ស. | ផលិតផលក្នុងស្រុកសរុប | Gross Domestic Product (GDP) |
| ABC | ធនាគារអេស៊ីលីដា | ACLEDA Bank Plc. |
| AMRO | អង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ | ASEAN+3 Macroeconomic Research Office |
| CAR | អនុបាតភាពគ្រប់គ្រាន់នៃដើមទុន | Capital Adequacy Ratio |
| CCB | ទ្រនាប់ដើមទុនខនស៊ើវេសិន | Capital Conservation Buffer |
| CGSM | ក្រុមហ៊ុនខេមជីអេសអេម | CAMGSM Plc. |
| CSS | ប្រព័ន្ធខេមបូឌានស៊ែស្វីច | Cambodia Shared Switch |
| CSX | ផ្សារមូលបត្រកម្ពុជា | Cambodia Securities Exchange |
| DBDE | ឌីប៊ីឌី អ៊ិនជីនារីង ម.ក | DBD Engineering Plc. |
| EMP | សម្ពាធទីផ្សារប្តូរប្រាក់ | Exchange Market Pressure |
| FTA | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី | Free Trade Agreement |
| G20 | ប្រទេសមានឧស្សាហកម្មជឿនលឿនទាំង២០ | The Group of 20 |
| GTI | ហ្គ្រេនធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី | Grand Twins International (Cambodia) Plc. |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ | International Monetary Fund |
| IPO | ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | Initial Public Offering |
| JSL | ជេអេស លែន ភីអ៊ិលស៊ី | JS LAND PLC. |
| LCR | អនុបាតក្របខ័ណ្ឌសន្ទនីយភាព | Liquidity Coverage Ratio |
| M2 | រូបិយវត្ថុទូទៅ | Broad Money |
| MDI | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | Microfinance Deposit-Taking Institution |
| MFI | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ | Microfinance Non-Deposit-Taking Institution |
| MJQE | ក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន | Mengly J. Quach Education Plc. |

| | | |
|---|---|---|
| MSME | សហគ្រាសធុនមីក្រូ តូច និងមធ្យម | Micro, Small and Medium Enterprise |
| NCS | ប្រព័ន្ធផាត់ទាត់ជាតិ | National Clearing System |
| NEER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាម | Nominal Effective Exchange Rate |
| NFC | គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុ | Non-Financial Corporations |
| NPLR | អនុបាតឥណទានមិនដំណើរការ | Non-Performing Loan Ratio |
| OBS | ប្រព័ន្ធធនាគារអនឡាញ | Online Banking System |
| ODC | គ្រឹះស្ថានទទួលប្រាក់បញ្ញើផ្សេងទៀត | Other Depository Corporations |
| PAS | កំពង់ផែស្វយ័តក្រុងព្រះសីហនុ | Sihanoukville Autonomous Port |
| PESTECH | ផេសថិច (ខេមបូឌា) ម.ក | PESTECH (Cambodia) Plc. |
| PPAP | កំពង់ផែស្វយ័តក្រុងភ្នំពេញ | Phnom Penh Autonomous Port |
| PPSP | ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី | Phnom Penh Special Economic Zone Plc. |
| PPWSA | រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | Phnom Penh Water Supply Authority |
| RCEP | កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ | Regional Comprehensive Economic Partnership |
| REER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិត | Real Effective Exchange Rate |
| ROA | អនុបាតប្រាក់ចំណេញសុទ្ធធៀបនឹងទ្រព្យសកម្ម | Return on Asset |
| ROE | អនុបាតប្រាក់ចំណេញសុទ្ធធៀបនឹងមូលនិធិភាគទុនិក | Return on Equity |
| SOE | សហគ្រាសរដ្ឋ | State-Owned Enterprise |
| SOFR | អត្រាហិរញ្ញប្បទានអូវើណាយដោយមានការធានា | Secured Overnight Financing Rate |

## ខ្លឹមសារសង្ខេប

**កំណើនសេដ្ឋកិច្ចពិភពលោករក្សាបានភាពធន់ ទោះជាបានថមថយដោយសារការប្រឈមនឹងកម្រិតខ្ពស់នៃអតិផរណានិងការរឹតបន្តឹងនយោបាយរូបិយវត្ថុ។** កំណើនសេដ្ឋកិច្ចពិភពលោកបានថយមកត្រឹម ៣,២% នៅឆ្នាំ២០២៣ ជាពិសេសអត្រាកំណើននៅប្រទេសអភិវឌ្ឍន៍បានថយចុះពី ២,៦% នៅឆ្នាំ២០២២ មកត្រឹម ១,៦%។ កំណើនសេដ្ឋកិច្ចអាស៊ានក៏បានថយចុះពី ៥,៦% មក ៤,២% ផងដែរ ដោយសារភាពទន់ខ្សោយនៃតម្រូវការខាងក្រៅ។

**កំណើនសេដ្ឋកិច្ចកម្ពុជាមានភាពរឹងមាំក្នុងអត្រា ៥% ទាបជាងកំណើន ៥,១% កាលពីឆ្នាំ ២០២២ បន្តិច។** ការនាំចេញផលិតផលពាក់ព័ន្ធនឹងកាត់ដេរ ទទួលរងផលប៉ះពាល់ដោយសារតម្រូវការទាបនៅសហរដ្ឋអាមេរិកនិងសហភាពអឺរ៉ុប ប៉ុន្តែការនាំចេញផលិតផលមិនមែនកាត់ដេរមានកំណើនរឹងមាំ។ វិស័យទេសចរណ៍បានបន្តងើបឡើង ដែលបានគាំទ្រដល់វិស័យសេវាកម្មពាក់ព័ន្ធផ្សេងទៀត ប៉ុន្តែសកម្មភាពសំណង់និងអចលនទ្រព្យនៅមានកម្រិតទាបនៅឡើយ។ ស្របតាមការងើបឡើងនៃសេដ្ឋកិច្ច លំហូរវិនិយោគផ្ទាល់ពីបរទេសបានបន្តកើនឡើង ប៉ុន្តែមានទំហំខុសគ្នាតាមវិស័យ ហើយជញ្ជីងទូទាត់បានប្តូរពីអតិរេកទៅជាឱនភាពបន្តិចប្រមាណ ០,៩% នៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស.)។

**ទោះជាទទួលរងសម្ពាធពីកត្តាខាងក្រៅ អត្រាប្តូរប្រាក់រៀលមានស្ថិរភាព ដែលមួយផ្នែកដោយសារអន្តរាគមន៍របស់ធនាគារជាតិនៃកម្ពុជានៅលើទីផ្សារប្តូរប្រាក់ ខណៈដែលទុនបម្រុងអន្តរជាតិមានកម្រិតខ្ពស់គ្រប់គ្រាន់។** អត្រាប្តូរប្រាក់រៀលមានកម្រិតជាមធ្យម ៤.១១១រៀលក្នុង១ដុល្លារអាមេរិក សម្រាប់ឆ្នាំ២០២៣ ដោយបានថយថ្លៃ ០,២% ធៀបនឹងអត្រាមធ្យមក្នុងឆ្នាំ២០២២ ឬ ១,៥% ធៀបនឹងឆ្នាំ២០១៩ មុនវិបត្តិកូវីដ-១៩។ ទោះយ៉ាងណា ដោយសាររូបិយប័ណ្ណដៃគូពាណិជ្ជកម្មសំខាន់ៗមួយចំនួនរបស់កម្ពុជាបានធ្លាក់ថ្លៃធៀបនឹងប្រាក់ដុល្លារអាមេរិក អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតបានបន្តនិន្នាការឡើងថ្លៃ ដែលអាចប៉ះពាល់ដល់ភាពប្រកួតប្រជែងពាណិជ្ជកម្មកម្ពុជា។ ដោយឡែកទុនបម្រុងអន្តរជាតិបានកើនឡើង ១៣,២% ដល់ ២០ ប៊ីលានដុល្លារអាមេរិក ដែលស្មើនឹង ៧ខែនៃការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់។

**អតិផរណាកម្ពុជាបានធ្លាក់ចុះពី ៥,៤% ក្នុងឆ្នាំ២០២២ មកត្រឹម ២,១% នៅឆ្នាំ២០២៣ ដោយសារការធ្លាក់ថ្លៃប្រេងឥន្ធនៈ និងការថយចុះនៃអត្រាអតិផរណាក្នុងតំបន់និងពិភពលោក។** អតិផរណានៅកម្ពុជាបានត្រឡប់មករកកម្រិតទាបឡើងវិញនៅឆ្នាំ២០២៣ ដោយថ្លៃក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈបានថយចុះ ២,៧% ដែលរួមចំណែកដល់ការកាត់បន្ថយអតិផរណាម្ហូបអាហារនិងអតិផរណាស្នូល ស្របពេលដែលស្ថិរភាពនៃអត្រាប្តូរប្រាក់ក៏បានជួយកាត់បន្ថយសម្ពាធនៃអតិផរណានាំចូលផងដែរ។ ក្នុងគោលដៅធានាស្ថិរភាពថ្លៃឱ្យកាន់តែប្រសើរជាងមុន ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនៅក្នុងសេដ្ឋកិច្ចពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ទាមទារនូវការបង្កើនការយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីឱ្យធនាគារជាតិនៃកម្ពុជាអាចប្រើប្រាស់នយោបាយរូបិយវត្ថុក្នុងការគ្រប់គ្រងអត្រាអតិផរណា និងសកម្មភាពសេដ្ឋកិច្ចកាន់តែមានប្រសិទ្ធភាពខ្ពស់។

**សមតុល្យសារពើពន្ធមានកម្រិតអវិជ្ជមានដោយសារតែការប្រមូលចំណូលទាបជាងមុន និងការកើនឡើងនៃការចំណាយសាធារណៈ។** ការថយចុះនៃសកម្មភាពសេដ្ឋកិច្ចក្នុងវិស័យមួយចំនួនបានធ្វើឱ្យការប្រមូលពន្ធថយចុះ ស្របពេលដែលការនាំចូលទាបនិងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក៏បានរួមចំណែកធ្វើឱ្យចំណូលពន្ធគយថមថយផងដែរ។ ទន្ទឹមនេះ ការកើនឡើងនៃចំណាយទាក់ទងនឹងការរៀបចំព្រឹត្តិការណ៍ស៊ីហ្គេមនិងអាស៊ានប៉ារ៉ាហ្គេម និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានធ្វើឱ្យសមតុល្យសារពើពន្ធអវិជ្ជមាន -២,៦% នៃផ.ស.ស. នៅក្នុងឆ្នាំ២០២៣។ បំណុលរាជរដ្ឋាភិបាលធៀបនឹងផ.ស.ស. បានកើនឡើង ១,២ពិន្ទុភាគរយ ដល់ ២៦,២% នៃផ.ស.ស. ប៉ុន្តែនៅតែមានកម្រិតទាបជាងកម្រិតពិដាន ៤០%។

**បើទោះជាហានិភ័យឥណទានបានកើនឡើង ប្រព័ន្ធធនាគារនៅតែរក្សាបានភាពធន់ និងបន្តផ្តល់ឥណទានគាំទ្រដល់ការងើបឡើងនៃសេដ្ឋកិច្ចក្រោយវិបត្តិកូវីដ-១៩។** កំណើនទ្រព្យសកម្ម និងឥណទាននៅក្នុងប្រព័ន្ធធនាគារបានថយចុះមកត្រឹម ៨,២% និង ៤,២% រៀងគ្នា នៅក្នុងឆ្នាំ ២០២៣ ប៉ុន្តែប្រាក់បញ្ញើមានកំណើនល្អក្នុងអត្រា ១៣% ដោយសារតែភាពទាក់ទាញនៃកំណើនអត្រាការប្រាក់បញ្ញើ។ ទ្រព្យសកម្មធនាគារពាណិជ្ជមានសមាមាត្រ ៩១% នៃទ្រព្យសកម្មសរុបក្នុងប្រព័ន្ធធនាគារ ដែលគិតជាទឹកប្រាក់ ៣១៤,៣ ទ្រីលានរៀល (៧៦,៩ ប៊ីលានដុល្លារអាមេរិក) បន្ទាប់ពីការរួមបញ្ចូលគ្នារវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើនិងធនាគារមួយ។

**ការរួមបញ្ចូលគ្នារវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើនិងធនាគារ បានធ្វើឱ្យកំណើនឥណទានវិស័យធនាគារមានភាពល្អប្រសើរជាងមុនជាមួយអត្រាកំណើន ១៦,៤%។** ឥណទានត្រូវបានបែងចែកទៅកាន់វិស័យផ្សេងៗ ក្នុងនោះឥណទានពីរប្រភេទធំៗ គឺឥណទានទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន សំណង់និងអចលនទ្រព្យ និងឥណទានទៅកាន់វិស័យជួញដូរាយនិងដុំដែលមានសមាមាត្រជាងពាក់កណ្តាលនៃឥណទានសរុប។ គុណភាពទ្រព្យសកម្មបានធ្លាក់ចុះដូចការរំពឹងទុក បន្ទាប់ពីការបញ្ចប់វិធានការអនុគ្រោះបទប្បញ្ញត្តិលើការរៀបចំឥណទានឡើងវិញ ដោយអនុបាតឥណទានមិនដំណើរការបានកើនឡើងដល់ ៥,១% ក្នុងឆ្នាំ២០២៣។

**សន្ទនីយភាព និងដើមទុនរបស់គ្រឹះស្ថានធនាគារមានស្ថានភាពល្អ ប៉ុន្តែប្រាក់ចំណេញបានធ្លាក់ចុះ។** ចំពោះសន្ទនីយភាព អនុបាតក្របខ័ណ្ឌសន្ទនីយភាពរបស់ធនាគារបានកើនដល់ ១៦៦,៦% ខ្ពស់ជាងកម្រិតកំណត់ដោយបទប្បញ្ញត្តិ (១០០%) ប៉ុន្តែសូចនាករសន្ទនីយភាពផ្សេងទៀត រួមមានទ្រព្យសកម្មងាយបំប្លែងជាសាច់ប្រាក់ធៀបនឹងទ្រព្យសកម្មសរុប និងទ្រព្យសកម្មងាយបំប្លែងជាសាច់ប្រាក់ធៀបនឹងប្រាក់បញ្ញើ បានថយចុះបន្តិច។ ទន្ទឹមនេះ ប្រាក់ចំណេញសុទ្ធក្រោយកាត់ពន្ធរួចរបស់គ្រឹះស្ថានធនាគារបានធ្លាក់ចុះ ៩៥% ដោយសារការកើនឡើងនៃចំណាយលើការប្រាក់ និងសំវិធានធន ប៉ុន្តែអនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារជាមធ្យមស្មើនឹង ២២,៣% ខ្ពស់ជាងកម្រិតកំណត់ដោយបទប្បញ្ញត្តិ ១៥% ដែលបានឆ្លុះបញ្ចាំងពីលទ្ធភាពរបស់គ្រឹះស្ថានធនាគារក្នុងការស្រូបយកការខាតបង់ក្នុងករណីដែលមានការប៉ះទង្គិចជាយថាហេតុ។

**ទ្រព្យសកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើបានថយចុះស្ទើរតែពាក់កណ្តាលក្នុងឆ្នាំ២០២៣ ក្រោយពីការរួមបញ្ចូលគ្នារវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើនិងធនាគារដែលបណ្តាលឱ្យឥណទានថយចុះ ៤៦%។** ទន្ទឹមនេះ គុណភាពឥណទានបានធ្លាក់ចុះ ប៉ុន្តែស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបានជាមួយការធ្វើសំវិធានធនគ្រប់គ្រាន់ និងស្ថានភាពដើមទុនរឹងមាំ ដូចដែលបានឆ្លុះបញ្ចាំងតាមរយៈកម្រិតខ្ពស់នៃអនុបាតភាពគ្រប់គ្រាន់នៃដើមទុន ២២,៩% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និង ៣១,៦% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ។ សំវិធានធនខ្ពស់ គួបផ្សំនឹងការរឹតបន្តឹងស្ថានភាពហិរញ្ញវត្ថុ បានរួមចំណែកដល់ការធ្លាក់ចុះនៃប្រាក់ចំណេញរបស់វិស័យមីក្រូហិរញ្ញវត្ថុ។

**ទ្រព្យសកម្មរបស់ធនាគារឯកទេសបានថយចុះបន្តិច ដោយសារការថមថយកំណើនឥណទាន និងការកើនឡើងនៃអនុបាតឥណទានមិនដំណើរការ។** គិតត្រឹមឆ្នាំ២០២៣ ទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារឯកទេសបានថយចុះ ៣,២% និងមានសមាមាត្រ ០,៨% នៃទ្រព្យសកម្មនៃប្រព័ន្ធធនាគារ។ កំណើនឥណទានបានថយមកត្រឹម ១,៦% និងអនុបាតឥណទានមិនដំណើរការបានកើនឡើងដល់ ១២,១% ប៉ុន្តែអនុបាតភាពគ្រប់គ្រាន់នៃដើមទុនមានកម្រិតខ្ពស់ ៣៩%។

**វិស័យហិរញ្ញវត្ថុមិនមែនធនាគារបានបន្តរីកចម្រើនជាមួយនឹងការចុះបញ្ជីក្រុមហ៊ុនថ្មីៗបន្ថែមទៀតនៅក្នុងទីផ្សារមូលបត្រកម្មសិទ្ធិនិងទីផ្សារមូលបត្របំណុល។** មូលធនូបនីយកម្មទីផ្សារមូលបត្រកម្មសិទ្ធិបានកើនដល់ ៧១,២% ដែលមានតម្លៃស្មើនឹង ១២,៨ ទ្រីលានរៀល (៣,២ ប៊ីលានដុល្លារអាមេរិក)។ សម្រាប់ទីផ្សារមូលបត្របំណុល ទំហំសញ្ញាប័ណ្ណសាជីវកម្មសរុបបានកើនឡើង ០,៦% រហូតដល់ ៥១៨,២ ប៊ីលានរៀល (១២៦,៩ លានដុល្លារអាមេរិក) ជាមួយនឹងការបោះផ្សាយសញ្ញាប័ណ្ណបៃតង និងសញ្ញាប័ណ្ណនិរន្តរភាពជាលើកដំបូងនៅក្នុងទីផ្សារហិរញ្ញវត្ថុកម្ពុជា។ លើសពីនេះ ទំហំមូលបត្ររដ្ឋមិនទាន់ដល់ឥណប្រតិទានបានកើនឡើង ដែលគាំទ្រដល់ការអភិវឌ្ឍទីផ្សារមូលបត្របំណុលជារូបិយវត្ថុជាតិ។ វិស័យធានារ៉ាប់រងបានបន្តអភិវឌ្ឍជាមួយកំណើនទ្រព្យសកម្ម ១០,៦% ដល់ជាង ៤,៤ ទ្រីលានរៀល (១,១ ប៊ីលានដុល្លារអាមេរិក) បើទោះជាកំណើនបុព្វលាភធានារ៉ាប់រងដុលសរុបបានថយពី ១០,៧% នៅឆ្នាំ២០២២ មកត្រឹម ២,៣% នៅឆ្នាំ២០២៣។

**ស្របតាមយុទ្ធសាស្ត្របញ្ញាកោណរបស់រាជរដ្ឋាភិបាល និងតម្រូវការទីផ្សារ ប្រព័ន្ធទូទាត់ត្រូវបានធ្វើទំនើបកម្មជាបន្តបន្ទាប់ និងបានតភ្ជាប់ជាមួយប្រទេសផ្សេងទៀតក្នុងតំបន់។** ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិកបានបន្តកើនឡើងគួរឱ្យកត់សម្គាល់ ជាមួយនឹងទំហំនៃការទូទាត់តាមប្រព័ន្ធឌីជីថលបានកើនដល់ជាង ១២ ដងនៃផ.ស.ស. ក្នុងឆ្នាំ២០២៣។ ការកើនឡើងនៃការប្រើប្រាស់ប្រព័ន្ធទូទាត់តាមប្រព័ន្ធឌីជីថលដូចជា បាគង និង ខេអេចឃ្យូអរ (KHQR) ក៏បានលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ខណៈដែលធនាគារជាតិនៃកម្ពុជា បានអភិវឌ្ឍការតភ្ជាប់ប្រព័ន្ធទូទាត់ឆ្លងដែនយ៉ាងសកម្ម ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យកាន់តែស៊ីជម្រៅ ក៏ដូចជាលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិនៅក្នុងតំបន់។

## ទស្សនវិស័យ និងហានិភ័យ

**នៅឆ្នាំ២០២៤ សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងកើន ៦% ដែលគាំទ្រដោយភាពប្រសើរឡើងនៃស្ថានភាពសេដ្ឋកិច្ចក្រៅប្រទេស និងសេដ្ឋកិច្ចក្នុងស្រុក។** មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានព្យាករថាសេដ្ឋកិច្ចពិភពលោកនឹងមានកំណើន ៣,២% នៅឆ្នាំ២០២៤ ខ្ពស់ជាងការព្យាករកាលពីគ្រាមុន ជាចម្បងដោយសារភាពធន់ជាងការរំពឹងទុកនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក និងការងើបឡើងលឿននៃសេដ្ឋកិច្ចចិន ដែលជាដៃគូពាណិជ្ជកម្ម និងវិនិយោគដ៏សំខាន់របស់កម្ពុជា។ អតិផរណាពិភពលោកត្រូវបានព្យាករថានឹងថយចុះពី ៦,៨% មកត្រឹម ៥,៩% ក្នុងឆ្នាំ ២០២៤ ដោយក្នុងនោះការធ្លាក់ចុះលឿននៃអតិផរណានៅប្រទេសអភិវឌ្ឍន៍អាចជំរុញឱ្យប្រទេសទាំងនោះកាត់បន្ថយអត្រាការប្រាក់គោលលឿនជាងការរំពឹងទុក។ ភាពប្រសើរឡើងនៃទស្សនវិស័យពិភពលោកនឹងគាំទ្រដល់ការនាំចេញរបស់កម្ពុជា ទាំងផលិតផលកម្មន្តសាលកាត់ដេរនិងមិនមែនកាត់ដេរ និងវិស័យទេសចរណ៍។ លើសពីនេះ កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTAs) នឹងអាចទាក់ទាញលំហូរវិនិយោគផ្ទាល់មកកម្ពុជាកាន់តែច្រើន ដែលជួយដល់ការធ្វើពិពិធកម្មផលិតកម្មនិងការនាំចេញ។ ការកើនឡើងនៃការតភ្ជាប់ជើងហោះហើរមកកាន់កម្ពុជា ការងើបឡើងឆាប់រហ័សនៃវិស័យទេសចរណ៍ក្នុងតំបន់ និងការដាក់ចេញនូវយុទ្ធនាការ "ទស្សនាសៀមរាប ២០២៤" ត្រូវបានរំពឹងថានឹងរួមចំណែកដល់ការពង្រឹងការងើបឡើងនៃវិស័យទេសចរណ៍ ដែលនឹងផ្តល់ផលវិជ្ជមានផងដែរដល់វិស័យពាក់ព័ន្ធផ្សេងទៀត រួមមានវិស័យជួញដូរដុំនិងរាយ ដឹកជញ្ជូននិងគមនាគមន៍។ វិស័យកសិកម្មនៅអាចនឹងមានកំណើនទាប ប៉ុន្តែបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច។ វិស័យសំណង់ និងអចលនទ្រព្យនឹងអាចមានកំណើនយឺត ជាពិសេសវិស័យអចលនទ្រព្យដែលការផ្គត់ផ្គង់ខុនដូ អគារពាណិជ្ជកម្ម និងគេហដ្ឋាន មានលើសពីតម្រូវការ ក្នុងខណៈពេលដែលតម្រូវការមានភាពទន់ខ្សោយបន្ទាប់ពីវិបត្តិកូវីដ-១៩ និងភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចពិភពលោក។ ទោះជា សេដ្ឋកិច្ចត្រូវបានរំពឹងថាមានកំណើនខ្ពស់ជាងមុន អតិផរណានៅកម្ពុជាត្រូវបានព្យាករថានឹងបន្តស្ថិតក្នុងកម្រិតទាបក្នុងរង្វង់ ២%។

**ហានិភ័យនៅតែមានកម្រិតខ្ពស់ ជាពិសេសពីកត្តាខាងក្រៅ ទោះជា ទស្សនវិស័យត្រូវបានរំពឹងថាមានភាពល្អប្រសើរក៏ដោយ។** ហានិភ័យទាំងនោះរួមមានភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយ ការអូសបន្លាយនៃការរឹតបន្តឹងនយោបាយរូបិយវត្ថុនៅប្រទេសអភិវឌ្ឍន៍ កំណើនទាបជាងការរំពឹងទុកនៃប្រទេសចិន និងការប្រែប្រួលអាកាសធាតុ។ ភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយបានឡើងកំដៅខ្លាំងនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ ដែលអាចបង្កឱ្យមានភាពរអាក់រអួលដល់ខ្សែច្រវាក់ផ្គត់ផ្គង់ និងការបែងចែកប្លុកពាណិជ្ជកម្ម ដែលប៉ះពាល់ដល់កំណើនផលិតកម្ម និងសេដ្ឋកិច្ចពិភពលោក។ ទាក់ទងនឹងចំណុចនេះផងដែរ អតិផរណាពិភពលោកអាចកើនឡើងវិញ ដែលនឹងជំរុញឱ្យធនាគារកណ្តាលរក្សាអត្រាការប្រាក់គោលខ្ពស់ ព្រមទាំងអាចកាត់បន្ថយតម្រូវការសកល និងលំហូរមូលធនទៅកាន់ប្រទេសកំពុងលូតលាស់ និងកំពុងអភិវឌ្ឍន៍។ ក្នុងស្ថានភាពនេះ សេដ្ឋកិច្ចតូចនិងបើកចំហដូចជាកម្ពុជានឹងងាយទទួលរងផលប៉ះពាល់ ជាចម្បងទៅលើការនាំចេញ ខណៈដែលអតិផរណាអាចប្រឈមនឹងសម្ពាធកើនឡើង តាមរយៈផលិតផលនាំចូលនិងថ្លៃដើមផលិតកម្មខ្ពស់។ បញ្ហាវិស័យអចលនទ្រព្យនៅក្នុងប្រទេសចិនអាចធ្វើឱ្យសកម្មភាពសេដ្ឋកិច្ចក្នុងតំបន់ថយចុះ រួមទាំងប្រទេសកម្ពុជា

ផងដែរ ដោយសារចិនគឺជាប្រទេសដែលវិនិយោគច្រើនជាងគេនៅកម្ពុជា។ លើសពីនេះ ការប្រែប្រួលអាកាសធាតុនៅតែជាហានិភ័យចម្បងមួយចំពោះវិស័យកសិកម្ម ដែលងាយទទួលរងគ្រោះពីការប្រែប្រួលនៃបរិមាណទឹកភ្លៀង។

**ប្រព័ន្ធធនាគារនឹងបន្តគាំទ្រកំណើនសេដ្ឋកិច្ច ស្របពេលដែលស្ថិរភាពហិរញ្ញវត្ថុនឹងត្រូវបានរក្សា។** ប្រព័ន្ធធនាគារកម្ពុជានៅតែមានភាពធន់ទោះបីបានឆ្លងកាត់វិបត្តិកូវីដ-១៩ និងបញ្ហាប្រឈមពីកត្តាខាងក្រៅជាបន្តបន្ទាប់។ ភាពរឹងមាំនៃប្រព័ន្ធធនាគារបានកាត់បន្ថយផលប៉ះពាល់នៃការប៉ះទង្គិចពីកត្តាខាងក្រៅមកលើសេដ្ឋកិច្ចកម្ពុជាផងដែរ។ ដូច្នេះ ប្រព័ន្ធធនាគារត្រូវបានរំពឹងថានឹងបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមជាតិ តាមរយៈការបែងចែកឥណទានទៅកាន់វិស័យនានា ការផ្តល់សេវាហិរញ្ញវត្ថុផ្សេងទៀត និងទំនើបកម្មនៃប្រព័ន្ធទូទាត់ដែលសម្រួលដល់ពាណិជ្ជកម្ម ការវិនិយោគ និងការទូទាត់ឆ្លងដែន។

**ទោះយ៉ាងណា ប្រព័ន្ធធនាគារក៏ប្រឈមនឹងហានិភ័យមួយចំនួនផងដែរ។** ការអូសបន្លាយនៃការរឹតបន្តឹងស្ថានភាពហិរញ្ញវត្ថុអន្តរជាតិអាចប៉ះពាល់ដល់អត្រាការប្រាក់នៅកម្ពុជា ដោយសារមួយផ្នែកនៃមូលនិធិរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានប្រភពមកពីក្រៅប្រទេស។ ទន្ទឹមនេះ ប្រសិនបើសកម្មភាពសេដ្ឋកិច្ចកើនឡើងយឺតជាងការរំពឹងទុក គួបផ្សំនឹងចំណាយលើការប្រាក់ខ្ពស់ អាចនាំឱ្យតម្រូវការឥណទានធ្លាក់ចុះ កាត់បន្ថយប្រាក់ចំណូលរបស់ក្រុមហ៊ុន-សហគ្រាសនិងអង្គភាពគ្រួសារ និងបង្កើនអនុបាតឥណទានមិនដំណើរការ។ ការកើនឡើងយឺតនៃទីផ្សារអចលនទ្រព្យ គឺជាហានិភ័យមួយទៀតដែលទាមទារការប្រុងប្រយ័ត្នខ្ពស់ ពីព្រោះផលប៉ះពាល់អាចកើតមានដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយចំនួន ដែលមានការពាក់ព័ន្ធជាមួយវិស័យនេះខ្លាំង។ ដូច្នេះ ធនាគារជាតិនៃកម្ពុជានឹងបន្តសហការជាមួយអាជ្ញាធរពាក់ព័ន្ធទាំងអស់ ដើម្បីតាមដានយ៉ាងដិតដល់នូវការវិវត្ត និងហានិភ័យទាំងនេះ ហើយដាក់ចេញនូវវិធានការបុរេសកម្មក្នុងករណីចាំបាច់ ដើម្បីរក្សាស្ថិរភាពហិរញ្ញវត្ថុ និងគាំទ្រដល់កំណើនសេដ្ឋកិច្ច។

# I ស្ថានភាពនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច

*នៅឆ្នាំ២០២៣ សេដ្ឋកិច្ចពិភពលោកបានបន្តងើបឡើង ប៉ុន្តែក្នុងល្បឿនយឺត ដោយសារការប្រឈមនឹងបញ្ហាជាច្រើន រួមមាន ជម្លោះភូមិសាស្ត្រនយោបាយ អតិផរណាខ្ពស់ និងការរឹតបន្តឹងស្ថានភាពហិរញ្ញវត្ថុ ជាដើម។ ទោះជាទទួលរងសម្ពាធពីកត្តាខាងក្រៅក៏ដោយ សេដ្ឋកិច្ចកម្ពុជារក្សាបានកំណើន ៥% ប្រហាក់ប្រហែលនឹងឆ្នាំ២០២២ ប៉ុន្តែនៅទាបជាងកំណើនសក្តានុពល។ វិស័យកម្មន្តសាលមានកំណើនយឺត ជាពិសេសវិស័យកាត់ដេរ ដោយសារការថមថយនៃតម្រូវការខាងក្រៅពីសហភាពអឺរ៉ុបនិងសហរដ្ឋអាមេរិក។ ដោយឡែក វិស័យទេសចរណ៍បន្តងើបឡើង ដោយចំនួនភ្ញៀវទេសចរអន្តរជាតិបានកើនដល់កម្រិត ៨២,៥% នៃគ្រាមុនវិបត្តិកូវីដ-១៩ ប៉ុន្តែចំណូលពីទេសចរបរទេសបានងើបឡើងយឺតជាង មកត្រឹមកម្រិត ៦២,៧%។ វិស័យកសិកម្មមានកំណើនទាប ខណៈដែលវិស័យសំណង់និងអចលនទ្រព្យនៅប្រឈមនឹងបញ្ហាពីកត្តាខាងក្រៅ ជាពិសេសវិស័យអចលនទ្រព្យដែលបានធ្លាក់ចុះប្រមាណ ០,៩%។ សម្ពាធពីកត្តាខាងក្រៅក៏ត្រូវបានឆ្លុះបញ្ចាំងតាមរយៈឱនភាពបន្តិចនៃសមតុល្យជញ្ជីងទូទាត់ប្រមាណ ០,៤% នៃផ.ស.ស.។ ទន្ទឹមនេះ សមតុល្យសារពើពន្ធមានឱនភាព ២,៦% នៃផ.ស.ស. ដោយសារការធ្លាក់ចុះនៃចំណូលពន្ធនិងការកើនឡើងនៃចំណាយពាក់ព័ន្ធនឹងការរៀបចំកីឡាស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេម និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ យ៉ាងណាមិញ អត្រាប្តូរប្រាក់មានស្ថិរភាព ហើយអត្រាអតិផរណាបានធ្លាក់ចុះពី ៥,៤% មក ២,១% ជាចម្បងដោយសារការថយចុះនៃថ្លៃប្រេង ដែលបានបណ្តាលឱ្យអតិផរណាក្រុមម្ហូបអាហារនិងអតិផរណាស្នូលមានការថមថយផងដែរ។ ទុនបម្រុងអន្តរជាតិបានកើនឡើងដល់ ២០ ប៊ីលានដុល្លារអាមេរិក ប៉ុន្តែកម្រិតខ្ពស់នៃដុល្លាវូបនីយកម្ម តម្រូវការគរពូនទុនបម្រុងអន្តរជាតិបន្ថែមនៅតែមាន ហើយការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលជាការងារចាំបាច់ ដើម្បីពង្រឹងឯករាជ្យនយោបាយរូបិយវត្ថុក្នុងគោលដៅធានាបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងភាពធន់ទៅនឹងហានិភ័យខាងក្រៅ។*

## ១.១ ស្ថានភាពវិស័យខាងក្រៅ

### ក. សេដ្ឋកិច្ចពិភពលោក

**នៅឆ្នាំ២០២៣ សេដ្ឋកិច្ចពិភពលោកបានបន្តងើបឡើងពីវិបត្តិកូវីដ-១៩ ប៉ុន្តែក្នុងល្បឿនយឺតដោយសារបញ្ហាប្រឈមជាច្រើន។** កំណើនសេដ្ឋកិច្ចពិភពលោកបានថមថយពី ៣,៥% នៅឆ្នាំ២០២២ មក ៣,២% នៅឆ្នាំ២០២៣ ជាចម្បងដោយសារការធ្លាក់ចុះនៃកំណើនសេដ្ឋកិច្ចនៃប្រទេសអភិវឌ្ឍន៍ពី ២,៦% មក ១,៦% ខណៈដែលកំណើនសេដ្ឋកិច្ចនៅប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍មានកម្រិតមធ្យម ៤,៣% (ក្រាហ្វ ១.១)។ ការអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន អតិផរណាខ្ពស់ និងការរឹតបន្តឹងស្ថានភាពហិរញ្ញវត្ថុ បានបន្តចបង្អាក់ដល់ការងើបឡើងនៃសេដ្ឋកិច្ចពិភពលោក ឆ្ពោះទៅរកនិន្នាការកំណើននៅគ្រាមុនវិបត្តិកូវីដ-១៩ ប៉ុន្តែសេដ្ឋកិច្ចពិភពលោកនៅមានភាពធន់ ដោយអាចរក្សាបានកំណើនវិជ្ជមាន ទោះក្នុងល្បឿនមួយយឺតជាងមុន។ កំណើន

**១.១ កំណើនសេដ្ឋកិច្ចពិភពលោក**

(ភាគរយ, ឆ្នាំ២០២១-២០២៣)




ប្រភព៖ របាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចពិភពលោករបស់ IMF និងរបាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចតំបន់របស់ AMRO ចេញផ្សាយក្នុងខែមេសា ឆ្នាំ២០២៤

សេដ្ឋកិច្ចអាស៊ានក៏បានថមថយមក ៤,២% នៅឆ្នាំ២០២៣ ដោយសារភាពទន់ខ្សោយនៃតម្រូវការខាងក្រៅ។

**អត្រាអតិផរណាបានធ្លាក់ចុះលឿនជាងការរំពឹងទុកនៅបណ្តាប្រទេសអភិវឌ្ឍន៍ ដែលអាចធ្វើឱ្យធនាគារកណ្តាលនៃប្រទេសទាំងនោះកាត់បន្ថយអត្រាការប្រាក់គោលនៅឆ្នាំនេះ។** អត្រាអតិផរណាពិភពលោកបានថមថយមកត្រឹម ៦,៨% នៅឆ្នាំ២០២៣ ពី ៨,៧% កាលពីឆ្នាំមុន (ក្រាហ្វ ១.២) ដោយសារភាពប្រសើរឡើងវិញនៃខ្សែច្រវាក់ផ្គត់ផ្គង់ និងការរឹតបន្តឹងនយោបាយរូបិយវត្ថុដែលបានកាត់បន្ថយសម្ពាធតម្រូវការ។ អតិផរណានៅប្រទេសអភិវឌ្ឍន៍បានធ្លាក់ចុះពី ៧,៣% មក ៤,៦% នៅឆ្នាំ២០២៣ នឹងត្រូវបានព្យាករថានឹងថយចុះមកត្រឹម ២,៦% នៅឆ្នាំ២០២៤។ ការណ៍នេះបានគាំទ្រដល់ទស្សនៈទីផ្សារដែលរំពឹងថាអត្រាការប្រាក់គោល នៅបណ្តាប្រទេសអភិវឌ្ឍន៍ នឹងអាចត្រូវកាត់បន្ថយនាឆ្នាំនេះ។ យ៉ាងណាមិញ អតិផរណានៅតំបន់អាស៊ានបានកើនឡើងពី ៧,៩% ទៅ ៨%។ ប៉ុន្តែ ការកើនឡើងនេះ គឺដោយសារកម្រិតខ្ពស់នៃអត្រាអតិផរណានៅប្រទេសឡាវ និងមីយ៉ាន់ម៉ា ដែលកំពុងមានបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចនិងនយោបាយ។ ប្រសិនបើដកចេញអត្រាអតិផរណានៃប្រទេសទាំង២ អតិផរណានៅតំបន់អាស៊ានបានធ្លាក់ចុះពី ៤,៧% នៅឆ្នាំ២០២២ មក ៣% នៅឆ្នាំ២០២៣។

**អត្រាការប្រាក់គោលនៅប្រទេសអភិវឌ្ឍន៍ត្រូវបានដំឡើង ដើម្បីកាត់បន្ថយអតិផរណា ប៉ុន្តែអត្រាការប្រាក់គោលនេះត្រូវបានរំពឹងថានឹងអាចកាត់បន្ថយក្នុងឆ្នាំ២០២៤។** ដោយសារអត្រាអតិផរណានៅក្នុងឆ្នាំ២០២២ មានកម្រិតខ្ពស់មិនធ្លាប់មាននៅក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយ ប្រទេសអភិវឌ្ឍន៍ដូចជា សហរដ្ឋ-អាមេរិក សហភាពអឺរ៉ុប និងចក្រភពអង់គ្លេសបានបង្កើនអត្រាការប្រាក់គោលយ៉ាងគំហុក (ក្រាហ្វ ១.៣)។ ដោយមានការរំពឹងថាអតិផរណានឹងវិលត្រលប់ទៅរកអត្រាគោលដៅត្រឹមចុងឆ្នាំ២០២៥ ធនាគារកណ្តាលនៅប្រទេសអភិវឌ្ឍន៍ភាគច្រើននៃបណ្តាប្រទេស G20 អាច

**១.២ អតិផរណាពិភពលោក**
(ជាភាគរយ, ឆ្នាំ២០១៨-២០២៣)




ប្រភព៖ របាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចពិភពលោករបស់ IMF និងរបាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចតំបន់របស់ AMRO ចេញផ្សាយក្នុងខែមេសា ឆ្នាំ២០២៤

**១.៣ អត្រាការប្រាក់គោលនៅប្រទេសអភិវឌ្ឍន៍**
(ជាភាគរយ, ឆ្នាំ២០១៨-២០២៣)




ប្រភព៖ Trading Economics

នឹងចាប់ផ្តើមបន្ធូរបន្ថយអត្រាការប្រាក់គោលនៅក្នុងឆ្នាំនេះ។

## ខ. ជញ្ជីងទូទាត់កម្ពុជា

**សមតុល្យជញ្ជីងទូទាត់មានឱនភាព ០,៤% នៃ ផ.ស.ស. (ក្រាហ្វ ១.៤)។** ការថយចុះខ្លាំងនៃឱនភាពពាណិជ្ជកម្មទំនិញពី ២២,១% នៃផ.ស.ស.[1] ក្នុងឆ្នាំ២០២២ មកឱនភាព ៧% ក្នុងឆ្នាំ២០២៣ និងការងើបឡើងនៃវិស័យទេសចរណ៍ បានធ្វើឱ្យគណនីចរន្តនិងដើមទុនមានអតិរេក ១,៦% នៃផ.ស.ស. ក្នុងឆ្នាំ២០២៣។ យ៉ាងណាមិញ គណនីហិរញ្ញវត្ថុដោយរាប់បញ្ចូលខ្ទង់កំហុសនិងរំលង បានប្តូរពីអតិរេកទៅជាឱនភាព ២% នៃផ.ស.ស. ជាចម្បងដោយសារលំហូរចេញសុទ្ធនៃវិនិយោគផ្សេងៗតាមរយៈការកើនឡើងទ្រព្យសកម្មបរទេសសុទ្ធរបស់វិស័យឯកជន។

### ខ.១ គណនីចរន្តនិងដើមទុន

**គណនីចរន្តនិងដើមទុនបានប្តូរពីឱនភាពទៅអតិរេក ជាចម្បងដោយសារការថយចុះនៃឱនភាពពាណិជ្ជកម្មទំនិញ។** ទោះជា ការនាំចេញសម្លៀកបំពាក់[2] ថយចុះ ១៣,២% ដោយសារការថយចុះតម្រូវការពីសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ដែលជាគោលដៅសំខាន់នៃការនាំចេញផលិតផលសម្លៀកបំពាក់ ការកើនឡើងលឿននៃការនាំចេញគ្រឿងបង្គុំអេឡិចត្រូនិក (៦៦,៣%) និងផលិតផលកសិកម្ម ដូចជា អង្ករ (១២,៥%) និងកៅស៊ូ (២៩%) បានជួយឱ្យការនាំចេញសរុបកើនឡើងប្រមាណ ១,៧%។ ការណ៍នេះ បានឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការធ្វើពិពិធកម្ម និងឥទ្ធិពលនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីពហុភាគី និងទ្វេភាគី។ ទន្ទឹមនេះ ការនាំចូលថយចុះ ១៧% ដោយសារការធ្លាក់ចុះនៃការនាំចូលយានយន្ត (៣៥,៩%) វត្ថុធាតុដើមសម្រាប់វិស័យកាត់ដេរ (៦,៥%) ប្រេងឥន្ធនៈ (៥,៣%) និងទំនិញផ្សេងទៀត (២៥,៦%)។ ជារួម ឱនភាពពាណិជ្ជកម្មទំនិញបានថយចុះពី ២២,១%

**១.៤ ជញ្ជីងទូទាត់កម្ពុជា**

(គិតជាភាគរយនៃផ.ស.ស., ឆ្នាំ២០១៨-២០២៣)




*គណនីហិរញ្ញវត្ថុរាប់បញ្ចូលកំហុសនិងរំលង

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**១.៥ ពាណិជ្ជកម្មទំនិញកម្ពុជា**

(ឆ្នាំ២០១៨-២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[1] ទិន្នន័យ ផ.ស.ស. ថ្មីរបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ដោយយកឆ្នាំគោល២០១៥។

[2] រាប់បញ្ចូលសម្លៀកបំពាក់ ស្បែកជើង និងវាយនភណ្ឌផ្សេងៗ។

នៃផ.ស.ស. ក្នុងឆ្នាំ២០២២ មក ៧% ក្នុងឆ្នាំ២០២៣ (ក្រាហ្វ ១.៥)។

**កំណើនលឿននៃភ្ញៀវទេសចរអន្តរជាតិ និងការកើនឡើងប្រាក់បង្វែរនិវេសន៍ក៏បានរួមចំណែក ដល់អតិរេកគណនីចរន្ត និងដើមទុនផងដែរ។** ភ្ញៀវទេសចរអន្តរជាតិបានកើនឡើងទ្វេដងពី ២,៣ លាននាក់ ដល់ ៥,៥ លាននាក់ ក្នុងឆ្នាំ២០២៣។ ទន្ទឹមនេះ ប្រាក់បង្វែរនិវេសន៍បានកើនឡើង ៦,៥% ដល់ ២,៨ ប៊ីលានដុល្លារអាមេរិក (ក្រាហ្វ ១.៦) ជាចម្បងដោយសារប្រាក់បង្វែរនិវេសន៍ពីប្រទេសថៃ ដែលមានសមាមាត្រច្រើនជាងពីរភាគបីនៃប្រាក់បង្វែរនិវេសន៍សរុប និងបានកើនឡើង ២,៤%។ ប្រាក់បង្វែរនិវេសន៍ពីប្រទេសកូរ៉េ (សមាមាត្រ ១២,៥% នៃប្រាក់បង្វែរនិវេសន៍សរុប) បានកើនឡើង ៣,៦% ស្របពេលដែលប្រាក់បង្វែរពីប្រទេសជប៉ុនបានកើនខ្លាំង ៣៣%។

### ខ.២ គណនីហិរញ្ញវត្ថុ

**លំហូរវិនិយោគផ្ទាល់បរទេសបានបន្តកើនឡើងឆ្ពោះទៅរកកម្រិតមុនវិបត្តិកូវីដ-១៩ ប៉ុន្តែលំហូរវិនិយោគមានភាពមិនស្មើគ្នាតាមវិស័យ។** លំហូរចូលវិនិយោគផ្ទាល់បរទេសសរុបមានទំហំ ៤ ប៊ីលានដុល្លារអាមេរិក ក្នុងឆ្នាំ២០២៣ ស្មើនឹងអត្រាកំណើន ១០,៦% និងលើសពីលំហូរមុនវិបត្តិកូវីដ-១៩ (៣,៧ ប៊ីលានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៩) (ក្រាហ្វ ១.៧)។ កំណើនលំហូរវិនិយោគផ្ទាល់បរទេសទៅកាន់វិស័យកម្មន្តសាលបានស្ទុះឡើងដល់ ៧៦,៤% និងមានសមាមាត្រ ៣៦,៥% នៃលំហូរវិនិយោគផ្ទាល់បរទេសសរុប។ វិស័យកម្មន្តសាលកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងវាយនភណ្ឌ នៅតែបន្តទាក់ទាញការវិនិយោគ ស្របពេលដែលវិស័យកម្មន្តសាលផ្សេងទៀតក៏មានការស្ទុះឡើង ដូចជា ការផលិតផ្ទាំងសូឡា ការកែច្នៃម្ហូបអាហារ និងសំបកកង់រថយន្ត។ លំហូរចូលនៃវិនិយោគផ្ទាល់បរទេសទៅកាន់វិស័យដទៃទៀត ក៏មានកំណើនវិជ្ជមានផងដែរ ដូចជា វិស័យ សំណង់ (១៧,៤%) កសិកម្ម (២,៧%) និងវារីអគ្គិសនី (២០,៣%)។ ប៉ុន្តែ លំហូរចូលនៃវិនិយោគផ្ទាល់បរទេសទៅកាន់វិស័យ

**១.៦ ប្រាក់បង្វែររបស់ពលករតាមប្រទេស**
(ឆ្នាំ២០១៨-២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**១.៧ លំហូរចូលវិនិយោគផ្ទាល់បរទេសតាមវិស័យ**
(ឆ្នាំ២០១៨-២០២៣)




ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

មួយចំនួនបានថយចុះ តួយ៉ាងវិស័យហិរញ្ញវត្ថុ (-១៨,៦%) អចលនទ្រព្យ (-១១,៨%) និងការស្នាក់នៅ (-១,៦%)។

**ប្រទេសចិននៅតែបន្តនាំមុខក្នុងការវិនិយោគនៅកម្ពុជា។** ប្រទេសចិនមានចំណែកវិនិយោគច្រើនជាងពាក់កណ្តាលនៃលំហូរវិនិយោគផ្ទាល់បរទេសសរុបក្នុងឆ្នាំ២០២៣ (ក្រាហ្វ ១.៨) និងបានវិនិយោគភាគច្រើនលើវិស័យកម្មន្តសាល ហិរញ្ញវត្ថុ សំណង់ អចលនទ្រព្យ និងការស្នាក់នៅ។ ទន្ទឹមនេះ ប្រទេសក្នុងតំបន់អាស៊ីផ្សេងទៀតក៏បានរួមចំណែកច្រើនក្នុងការវិនិយោគនៅកម្ពុជា រួមមាន ប្រទេសកូរ៉េ (១០,២%) ជប៉ុន (៧,៦%) និងសិង្ហបុរី (៦,៦%) ជាដើម។ ចំណែកឯ ការវិនិយោគពីប្រទេសកាណាដាក៏មានទំហំធំផងដែរ (៩,៥%)។ ប្រទេសទាំងនេះភាគច្រើនបានវិនិយោគលើវិស័យហិរញ្ញវត្ថុ អចលនទ្រព្យ និងកម្មន្តសាល។

**បំណុលក្រៅប្រទេសដុល[៣]បន្តកើនឡើង ប៉ុន្តែបានធ្លាក់ចុះបើធៀបនឹង ផ.ស.ស.។** បំណុលក្រៅប្រទេសដុលបានកើនឡើង ១,១% ធៀបទៅនឹងឆ្នាំមុន គឺកើនដល់ ២២,៦ ប៊ីលានដុល្លារអាមេរិក ដែលនៅក្នុងនោះ ១៨,៣ ប៊ីលានដុល្លារអាមេរិក ជាបំណុលរយៈពេលវែង។ ប៉ុន្តែបើធៀបទៅនឹង ផ.ស.ស. បំណុលក្រៅប្រទេសបានថយចុះពី ៥៦,១% ទៅ ៥៣% (ក្រាហ្វ ១.៩)។ បំណុលក្រៅប្រទេសរបស់រាជរដ្ឋាភិបាល ដែលសុទ្ធតែជាកម្ចីរយៈពេលវែង មានចំនួន ១១,៥ ប៊ីលានដុល្លារអាមេរិក ដោយបានកើនឡើង ១១,៨%។ បំណុលក្រៅប្រទេសដុលរបស់គ្រឹះស្ថានទទួលប្រាក់បញ្ញើបានថយចុះ ៨,១% ដល់ ១១,១ ប៊ីលានដុល្លារអាមេរិក ក្នុងនោះ ៦,៧ ប៊ីលានដុល្លារអាមេរិក ជាកម្ចីរយៈពេលវែង។

## គ. អត្រាប្តូរប្រាក់ និងទុនបម្រុងអន្តរជាតិ

**ទោះជាទទួលរងសម្ពាធពីកត្តាខាងក្រៅ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកនៅតែរក្សាបានស្ថិរភាព។** ការថយចុះនៃលំហូរចូលប្រាក់ដុល្លារអាមេរិក ការឡើងថ្លៃនៃប្រាក់ដុល្លារអាមេរិកនៅលើទីផ្សារអន្តរជាតិ

**១.៨ លំហូរចូលវិនិយោគផ្ទាល់បរទេសតាមប្រទេស**
(គិតជាភាគរយ, ឆ្នាំ២០២៣)




ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**១.៩ សមាសធាតុនៃបំណុលក្រៅប្រទេសដុល**
(គិតជាភាគរយនៃផ.ស.ស., ឆ្នាំ២០១៨-២០២៣)




ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា

[៣] បំណុលក្រៅប្រទេសគ្របដណ្តប់លើកម្ចីក្រៅប្រទេសរបស់វិស័យសាធារណៈ (រាជរដ្ឋាភិបាល និងធនាគារកណ្តាល) និងគ្រឹះស្ថានទទួលប្រាក់បញ្ញើតែប៉ុណ្ណោះ។

និងកំណើនចំណាយសាធារណៈក្នុងព្រឹត្តិការណ៍កីឡាស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេម បានធ្វើឱ្យអត្រាប្តូរប្រាក់រៀលចាប់ផ្តើមធ្លាក់ថ្លៃជាបន្តបន្ទាប់ពីខែឧសភា ឆ្នាំ២០២៣ មក ដល់អត្រា ៤.១៥៨ រៀលក្នុងមួយដុល្លារអាមេរិកនៅចុងខែសីហា។ ក្នុងស្ថានភាពនេះ ធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់ និងប្រើប្រាស់ឧបករណ៍នយោបាយរូបិយវត្ថុដើម្បីរក្សាស្ថិរភាពអត្រាប្តូរប្រាក់។ ជាលទ្ធផល អត្រាប្តូរប្រាក់មានស្ថិរភាព ក្នុងអត្រាមធ្យម ៤.១១១ រៀលក្នុងមួយដុល្លារអាមេរិក ក្នុងឆ្នាំ២០២៣ ដែលធ្លាក់ថ្លៃតិចតួច ០,២% ធៀបនឹងឆ្នាំ ២០២២ ឬ ១,៥% ធៀបនឹងគ្រាមុនវិបត្តិ (ឆ្នាំ២០១៩)។ ការធ្លាក់ថ្លៃបន្តិចនេះមិនបង្កជាការបារម្ភនោះទេ ដោយសារសន្ទស្សន៍សម្ពាធទីផ្សារប្តូរប្រាក់[4] (EMP) នៅតែស្ថិតក្រោមគម្លាតស្តង់ដារ[5] គាំទ្រដោយកម្រិតខ្ពស់នៃទុនបម្រុងអន្តរជាតិ (ក្រាហ្វ ១.១០)។

**ទោះយ៉ាងណា ស្ថិរភាពនៃប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកបានធ្វើឱ្យអត្រាប្តូរប្រាក់ប្រសិទ្ធភាពឡើងថ្លៃធៀបនឹងរូបិយប័ណ្ណនៃដៃគូពាណិជ្ជកម្មសំខាន់ៗ។** ក្នុងឆ្នាំ២០២៣ រូបិយប័ណ្ណនៃប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជាបានធ្លាក់ថ្លៃធៀបនឹងប្រាក់ដុល្លារអាមេរិក ដូចជា ប្រាក់យេនជប៉ុនបានធ្លាក់ថ្លៃ ៩% យ៉ន់ចិន ៦,៧%ដុល្លារកាណាដា៤,៩%វ៉ុនកូរ៉េ ៣,៧%ដុងវៀតណាម ២,៦% បាតថៃ ១,៤% និងផោនអង់គ្លេស ១,៣%។ ជាលទ្ធផល អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាម (NEER) កម្ពុជាធៀបនឹងដៃគូពាណិជ្ជកម្មសំខាន់ៗបានឡើងថ្លៃ ៣% និងអត្រាប្តូរប្រាក់ប្រសិទ្ធភាពពិត (REER) បានឡើងថ្លៃ ១,៩% (ក្រាហ្វ ១.១១) ដែលអាចកាត់បន្ថយភាពប្រកួតប្រជែងនៃពាណិជ្ជកម្មកម្ពុជា។

**ក្រោយការធ្លាក់ចុះអស់២ឆ្នាំ ទុនបម្រុងអន្តរជាតិបានកើនឡើងវិញនៅឆ្នាំ២០២៣។** ទុនបម្រុងអន្តរជាតិ

**១.១០ សម្ពាធទីផ្សារប្តូរប្រាក់ (EMP)**
(ឆ្នាំ២០១៨-២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**១.១១ អត្រាប្តូរប្រាក់រៀល**
(ឆ្នាំ២០១៨-២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

---

[4] សន្ទស្សន៍សម្ពាធទីផ្សារប្តូរប្រាក់ (EMP) ត្រូវបានប្រើដើម្បីវិភាគសម្ពាធអត្រាប្តូរប្រាក់ក្នុងទីផ្សារដែលឆ្លុះបញ្ចាំងពីការប្រែប្រួលប្រចាំខែនៃអត្រាប្តូរប្រាក់ និងទុនបម្រុងអន្តរជាតិ (តំណាងឱ្យសមត្ថភាពរបស់ធនាគារកណ្តាលក្នុងការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ដើម្បីរក្សាស្ថិរភាពអត្រាប្តូរប្រាក់ក្នុងករណីចាំបាច់)។ នៅក្នុងបរិការណ៍សេដ្ឋកិច្ចដែលមានដុល្លារូបនីយកម្មខ្ពស់ នៅពេលដែលEMPឡើងហួសដែនកំណត់ខាងលើ មិនមានន័យថាកម្ពុជាមានហានិភ័យវិបត្តិរូបិយវត្ថុនោះទេ ប៉ុន្តែមានន័យថាទុនបម្រុងអន្តរជាតិបានធ្លាក់ចុះ និង/ឬ មានសម្ពាធនៃការធ្លាក់ថ្លៃប្រាក់រៀល ដែលអាចនឹងមានឥទ្ធិពលលើទំនុកចិត្តរបស់ទីផ្សារមកលើស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។

[5] ដែនកំណត់គម្លាតស្តង់ដារត្រូវបានកំណត់ដោយ $\mu EMP+\sigma EMP*\varphi$ ដែល $\mu EMP$៖ មធ្យមនៃ EMP; $\sigma EMP$៖ គម្លាតស្តង់ដារនៃ EMP; $\varphi$៖ ៩៩% នៃ $\sigma EMP$។

មានចំនួន ២០ ប៊ីលានដុល្លារអាមេរិក នៅចុងឆ្នាំ២០២៣ ដោយបានកើនឡើង ១៣,២% ធៀបនឹងឆ្នាំ២០២២ និងអាចធានាការនាំចូលទំនិញ និងសេវា សម្រាប់គ្រាបន្ទាប់បាន ៧,១ ខែ (ក្រាហ្វ ១.១២) ខ្ពស់ជាងកម្រិតអប្បបរមា ៣ខែ ដែលប្រទេសកំពុងអភិវឌ្ឍន៍គួរមាន។ បើធៀបនឹងរូបិយវត្ថុទូទៅ ទុនបម្រុងអន្តរជាតិមានកម្រិត ៤២% ដែលខ្ពស់ជាងអត្រាគោល ២០%។ ទោះយ៉ាងណា នៅក្នុងបរិការណ៍នៃកម្រិតដុល្លារូបនីយកម្មខ្ពស់ (ទុនបម្រុងអន្តរជាតិមានសមាមាត្រ ៥១% ធៀបនឹងប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស) ការគរពូនទុនបម្រុងអន្តរជាតិបន្ថែមនៅតែមានភាពចាំបាច់ដើម្បីពង្រឹងភាពធន់នៃសេដ្ឋកិច្ចទល់នឹងការប៉ះទង្គិចនានា។

**១.១២ ទុនបម្រុងអន្តរជាតិ**
(ឆ្នាំ២០១៨-២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ប្រអប់ ១.១**

## ការវិភាគតារាងតុល្យការ

ក្នុងឆ្នាំ២០២៣នេះ ស្ថានភាពហិរញ្ញវត្ថុដុលនៃគ្រប់វិស័យ (ទាំងផ្នែកទ្រព្យសកម្ម និងទ្រព្យអកម្ម) សរុបមានចំនួន ៩៩៩,៦ ប៊ីលានដុល្លារអាមេរិក ដោយបានកើនឡើង ៩,៨% ធៀបនឹងឆ្នាំ២០២២។ ការកើនឡើងនេះជាចម្បងបណ្តាលមកពីការកើនឡើងនៃវិស័យខាងក្រៅ (១០,៥%) អង្គភាពគ្រួសារ (១១,៤%) និងគ្រឹះស្ថានទទួលប្រាក់បញ្ញើផ្សេងទៀត (ODCs) (៨,៩%)។ ទំហំនៃវិស័យចម្បងៗក្នុងស្ថានភាពហិរញ្ញវត្ថុដុលនេះ រួមមាន ODCs បានរួមចំណែក ១៤៩,៣ ប៊ីលានដុល្លារអាមេរិក វិស័យខាងក្រៅ ១០៥,១ ប៊ីលានដុល្លារអាមេរិក គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុ (NFCs) ១០០,៤ ប៊ីលានដុល្លារអាមេរិក និងអង្គភាពគ្រួសារ ៧៧,៦ ប៊ីលានដុល្លារអាមេរិក។

ចំពោះស្ថានភាពហិរញ្ញវត្ថុសុទ្ធវិញ ODCs មានទ្រព្យសកម្មសុទ្ធចំនួន ២,៧ ប៊ីលានដុល្លារអាមេរិក ដោយបានកើនឡើង ២៧,៣% ពីចំនួន ២,២ ប៊ីលានដុល្លារអាមេរិក ក្នុងឆ្នាំ២០២២។ លំហូរមូលធនពីគ្រប់វិស័យចូលក្នុង ODCs មានចំនួន ៧៣,៣ ប៊ីលានដុល្លារអាមេរិក ជាមួយអត្រាកំណើន ៨,៦% (ឆ្នាំលើឆ្នាំ)

**ក ស្ថានភាពហិរញ្ញវត្ថុរួមតាមវិស័យដុល**
(គិតជាប៊ីលានដុល្លារអាមេរិក, ឆ្នាំ២០២៣)




កំណត់សម្គាល់៖
- ទំហំរង្វង់ តំណាងឱ្យទំហំទឹកប្រាក់សរុបនៃទ្រព្យសកម្មនិងទ្រព្យអកម្មរបស់វិស័យនីមួយៗ
- ពណ៌នៃខ្សែដែលចេញពីវិស័យមួយទៅវិស័យផ្សេងទៀត តំណាងឱ្យបំណុលត្រូវទារពីវិស័យទាំងនោះ។

ជាចម្បងបណ្ដាលមកពីការកើនឡើងនៃលំហូរចូលមូលធនពីអង្គភាពគ្រួសារ (១២,៤%) និង NFCs (៨,៩%)។ ដោយឡែក មូលធនដែល ODCs បានផ្ដល់ទៅកាន់គ្រប់វិស័យវិញមានចំនួន ៧៦ ប៊ីលានដុល្លារអាមេរិក ដោយបានកើន ៩,១% ពីចំនួន ៧០ ប៊ីលានដុល្លារអាមេរិកនៅឆ្នាំមុន ជាចម្បងដោយសារការកើនឡើងនៃការផ្ដល់មូលធនទៅកាន់ NFCs (២,២%) និងអង្គភាពគ្រួសារ (៩,៦%) ដែលភាគច្រើនជាប្រាក់កម្ចី។ ទន្ទឹមនេះ NFCs មានទ្រព្យអកម្មសុទ្ធចំនួន ៧០,២ ប៊ីលានដុល្លារអាមេរិក ដោយបានកើនឡើង ៧,១%។ លំហូរចូលមូលធនមកកាន់ NFCs មានចំនួន ៨៥,៣ ប៊ីលានដុល្លារអាមេរិក ដែលបានកើនឡើង ៧,២% (ឆ្នាំលើឆ្នាំ)។ ដោយឡែក លំហូរមូលធនចេញទៅកាន់គ្រប់វិស័យមានចំនួន ១៥,១ ប៊ីលានដុល្លារអាមេរិក ស្មើនឹងកំណើន ៧,៨%។

វិស័យខាងក្រៅមានឥណទេយ្យត្រូវទារសុទ្ធចំនួន ៤០ ប៊ីលានដុល្លារអាមេរិក (កើនឡើង ០,៩%)។ លំហូរចូលមូលធនពីវិស័យខាងក្រៅមកគ្រប់វិស័យនៅក្នុងប្រទេសកម្ពុជាមានចំនួន ៧២,៦ ប៊ីលានដុល្លារអាមេរិក ជាមួយអត្រាកំណើន ៧,៧% ខណៈដែលលំហូរចេញទៅវិស័យក្រៅប្រទេសវិញមានចំនួន ៣២,៥ ប៊ីលានដុល្លារអាមេរិក ស្មើនឹងកំណើន ១៧,៤%។ NFCs ជាអ្នកទទួលមូលធនចម្បងពីវិស័យនេះ ដែលមានសមាមាត្រស្មើនឹង ៦៧,៩% នៃលំហូរចេញសរុបពីវិស័យខាងក្រៅ ខណៈដែលលំហូរមូលធនពី NFCs ទៅកាន់វិស័យខាងក្រៅបានរួមចំណែកត្រឹម ១៧,៧% ប៉ុណ្ណោះ។

**ខ ស្ថានភាពហិរញ្ញវត្ថុរួមតាមវិស័យសុទ្ធ**

(គិតជាប៊ីលានដុល្លារអាមេរិក, ឆ្នាំ២០២៣)




កំណត់សម្គាល់៖

- វិស័យសេដ្ឋកិច្ចដែលរំលេចដោយពណ៌ **ក្រហម** សំដៅលើឥណទាយិក (Net Debtor) ខណៈដែលវិស័យសេដ្ឋកិច្ចដែលរំលេចដោយពណ៌ **បៃតង** សំដៅលើឥណទាយក (Net Creditor)
- ទំហំរង្វង់ តំណាងឱ្យទំហំស្ថានភាពសុទ្ធ (Net Position) របស់វិស័យនីមួយៗ
- សញ្ញាព្រួញដែលចេញពីវិស័យមួយទៅវិស័យផ្សេងទៀត តំណាងឱ្យបំណុលត្រូវទារពីវិស័យទាំងនោះ។

## ១.២ ស្ថានភាពសេដ្ឋកិច្ចក្នុងស្រុក

### ក. កំណើនសេដ្ឋកិច្ច

សេដ្ឋកិច្ចកម្ពុជាបានកើន ៥% ក្នុងឆ្នាំ២០២៣ ប្រហាក់ប្រហែលនឹងឆ្នាំ២០២២ ប៉ុន្តែនៅទាបជាងឆ្ងាយពីកម្រិតមុនវិបត្តិ (ក្រាហ្វ១.១៣)។ កំណើន ផ.ស.ស. ជាចម្បងរួមចំណែកដោយវិស័យឧស្សាហកម្ម (២,៥២ ពិន្ទុភាគរយនៃកំណើនផ.ស.ស.) និងវិស័យសេវាកម្ម (២,៣៦ ពិន្ទុភាគរយ) ខណៈដែលវិស័យកសិកម្មរួមចំណែកបន្តិចដល់កំណើនសេដ្ឋកិច្ច (០,១៥ ពិន្ទុភាគរយ)។ តាមអនុវិស័យ កម្មន្តសាលកាត់ដេរបន្តដើរតួនាទីសំខាន់ជាមួយនឹងសមាមាត្រនៃការរួមចំណែកប្រមាណ ០,៧២

**១.១៣ ការរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចតាមវិស័យចម្បងៗ**

(គិតជាភាគរយ, ឆ្នាំ២០១៨ - ២០២៣ប)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ

ពិន្ទុភាគរយ ដោយថយចុះពី ១,៨ ពិន្ទុភាគរយ កាលពីឆ្នាំ២០២២។ យ៉ាងណាមិញ អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរបានក្លាយជាអនុវិស័យដ៏មានសក្តានុពលមួយ ជាមួយនឹងការរួមចំណែកប្រមាណ ១,៣៨ ពិន្ទុភាគរយ កើនពី ១,១៦ ពិន្ទុភាគរយ កាលពីឆ្នាំ២០២២។ ជាមួយនឹងការងើបឡើងឆាប់រហ័សនៃចំនួនភ្ញៀវទេសចរ អន្តរជាតិ និងភ្ញៀវទេសចរក្នុងស្រុក ការរួមចំណែកនៃវិស័យដែលទាក់ទងនឹងវិស័យទេសចរណ៍បានបន្តងើបឡើង ក្នុងនោះរួមមាន វិស័យពាណិជ្ជកម្មជួញដូរជុំនិងរាយ ការស្នាក់នៅ ការដឹកជញ្ជូន និងគមនាគមន៍។

**វិស័យកម្មន្តសាលបានបន្តជាកាតាលីករជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាដ៏សំខាន់ បើទោះជាទទួលរងការប្រឈមពីកត្តាខាងក្រៅក្តី** (ក្រាហ្វ ១.១៤)។ កំណើននៃវិស័យនេះបានថយចុះមកត្រឹម ៧,២% ក្នុងឆ្នាំ ២០២៣ ពី ១០,៦% កាលពីឆ្នាំ២០២២ ដែលជាចម្បងដោយសារតែការធ្លាក់ចុះនៃតម្រូវការខាងក្រៅ ជាពិសេសពីសហរដ្ឋ-អាមេរិក និងសហភាពអឺរ៉ុប លើការនាំចេញផលិតផលកម្មន្តសាលកាត់ដេរ។ ទោះយ៉ាងណា ការនាំចេញផលិតផលមិនមែនកាត់ដេរបាននិងកំពុងមានសន្ទុះ ដែលធ្វើឱ្យឧស្សាហកម្មកម្មន្តសាលមិនមែនកាត់ដេរ មានកំណើនដល់ ១១,១%។

**វិស័យទេសចរណ៍បានងើបឡើងលឿន បើផ្អែកលើចំនួនភ្ញៀវទេសចរ។** ការងើបឡើងដ៏គួរឱ្យកត់សម្គាល់នេះ គឺជាលទ្ធផលនៃកត្តាជាច្រើនរួមមាន៖ ភាពជោគជ័យក្នុងការរៀបចំការប្រកួតកីឡាស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេម ដែលបានទាក់ទាញភ្ញៀវទេសចរយ៉ាងច្រើននៅក្នុងតំបន់ ការដាក់ឱ្យដំណើរការជើងហោះហើរត្រង់ឡើងវិញ និងការបើកអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរថ្មី។ ជាក់ស្តែង ចំនួនភ្ញៀវទេសចរអន្តរជាតិមកកម្ពុជាបានកើនឡើងដល់ ៥,៥ លាននាក់ ពី ២,៣ លាននាក់ ក្នុងឆ្នាំ២០២២ (ក្រាហ្វ ១.១៥) និងមានសមាមាត្រស្មើនឹង ៨២,៥% នៃចំនួនភ្ញៀវទេសចរអន្តរជាតិមុនវិបត្តិកូវីដ-១៩។

**១.១៤ កំណើននៃវិស័យកម្មន្តសាល**

(គិតជាភាគរយ, ឆ្នាំ២០១៨-២០២៣ប)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ

**១.១៥ ភ្ញៀវទេសចរអន្តរជាតិបែងចែកតាមគោលបំណង**

(ឆ្នាំ២០១៨ - ២០២៣)




ប្រភព៖ ក្រសួងទេសចរណ៍

**ទោះជាចំនួនភ្ញៀវទេសចរអន្តរជាតិកើនឡើងលឿន គុណភាពនៃការងើបឡើងនេះ ហាក់មិនទាន់ល្អនោះទេ ដោយភ្ញៀវទេសចរអន្តរជាតិភាគច្រើនបានធ្វើដំណើរមកកម្ពុជាតាមផ្លូវគោកដែលជាធម្មតាមានចំណាយតិចជាងក្រុមភ្ញៀវទេសចរដែលធ្វើដំណើរមកតាមផ្លូវអាកាស។** ដូចដែលបានបង្ហាញក្នុង (ក្រាហ្វ ១.១៦) ការមកដល់របស់ភ្ញៀវទេសចរអន្តរជាតិតាមផ្លូវអាកាសមុនវិបត្តិកូវីដ-១៩ មានសមាមាត្រ ២/៣ នៃភ្ញៀវទេសចរអន្តរជាតិសរុប។ យ៉ាងណាមិញ សមាមាត្រនៃភ្ញៀវទេសចរអន្តរជាតិធ្វើដំណើរតាមផ្លូវអាកាស ដែលជាធម្មតាចាយប្រាក់ច្រើនជាងភ្ញៀវទេសចរធ្វើដំណើរតាមមធ្យោបាយផ្សេងទៀត បានធ្លាក់ចុះមកត្រឹម ១/៣ ក្នុងរយៈពេល ២ឆ្នាំចុងក្រោយនេះ។ ជាក់ស្តែង ខណៈដែលចំនួនភ្ញៀវទេសចរអន្តរជាតិសរុបបានកើនឡើងស្មើនឹង ៨២,៥% នៃចំនួនភ្ញៀវទេសចរក្នុងឆ្នាំ២០១៩ ចំនួនភ្ញៀវទេសចរអន្តរជាតិមកទស្សនារមណីយដ្ឋានអង្គរទើបកើនបានត្រឹម ៣៦,២% ហើយចំណូលពីភ្ញៀវទេសចរអន្តរជាតិទើបបានស្មើនឹង ៦២,៧% នៃតួលេខក្នុងឆ្នាំ២០១៩ ប៉ុណ្ណោះ (ក្រាហ្វ ១.១៧)។

**ទោះយ៉ាងណា ភ្ញៀវទេសចរក្នុងស្រុកបានបន្តកើនឡើងគួរឱ្យកត់សម្គាល់ប្រមាណ ៣៤,៥% ខ្ពស់លើសកម្រិតនៃគ្រាមុនវិបត្តិ។** ការកើនឡើងនៃភ្ញៀវទេសចរក្នុងស្រុកត្រូវបានគាំទ្រដោយកត្តាជាច្រើន រួម-មាន៖ ការកើនឡើងនៃចំណាប់អារម្មណ៍ក្នុងការស្វែងរកគោលដៅទេសចរណ៍ថ្មីក្នុងស្រុក ក៏ដូចជាភាពងាយស្រួលក្នុងការធ្វើដំណើរដោយសារការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនានា។ គួរកត់សម្គាល់ថា ភ្ញៀវទេសចរក្នុងស្រុកប្រមាណ ៤៥% បានធ្វើដំណើរទៅកាន់តំបន់ឆ្នេរ ដែលត្រូវបានគាំទ្រដោយការបញ្ចប់គម្រោងកសាងហេដ្ឋារចនាសម្ព័ន្ធមួយចំនួន ដូចជា ផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុជាដើម។ ម៉្យាងទៀត កត្តារួមចំណែកបន្ថែមដល់ការកើនឡើងនៃវិស័យទេសចរណ៍ក្នុងស្រុក គឺការអនុវត្តយុទ្ធនាការផ្សព្វផ្សាយតាមគោលដៅរបស់រាជរដ្ឋាភិបាលក្នុងគោលបំណងលើកកម្ពស់មោទនភាពជាតិ និងលើក

**១.១៦ សមាមាត្រនៃភ្ញៀវទេសចរអន្តរជាតិតាមរយៈមធ្យោបាយធ្វើដំណើរ**

(គិតជាភាគរយ, ឆ្នាំ២០១៨ - ២០២៣)




ប្រភព៖ ក្រសួងទេសចរណ៍

**១.១៧ ការងើបឡើងនៃវិស័យទេសចរណ៍**

(គិតជាភាគរយ, ឆ្នាំ២០២០ - ២០២៣)




សម្គាល់៖ ភាគរយធៀបនឹងតួលេខក្នុងឆ្នាំ២០១៩

ប្រភព៖ ក្រសួងទេសចរណ៍

**១.១៨ ភ្ញៀវទេសចរក្នុងស្រុក**

(ឆ្នាំ២០១៨-២០២៣)




ប្រភព៖ ក្រសួងទេសចរណ៍

ទឹកចិត្តប្រជាពលរដ្ឋឱ្យស្វែងយល់ពីភាពស្រស់ស្អាត និងបេតិកភណ្ឌជាតិ។ យុទ្ធនាការផ្សព្វផ្សាយនេះមិនត្រឹមតែជួយជំរុញដល់វិស័យទេសចរណ៍ក្នុងស្រុកប៉ុណ្ណោះទេ ថែមទាំងក្លាយជាកាតាលីករសម្រាប់គាំទ្រកំណើនសេដ្ឋកិច្ច និងតម្លៃវប្បធម៌ជាតិផងដែរ (ក្រាហ្វ ១.១៨)។

**វិស័យកសិកម្មបន្តមានកំណើនទាប។** ក្នុងឆ្នាំ ២០២៣ វិស័យកសិកម្មមានកំណើនប្រមាណ ១% ធៀបនឹង ០,៦% ក្នុងឆ្នាំ២០២២ (ក្រាហ្វ ១.១៩) ជាចម្បង ដោយសារកត្តាអាកាសធាតុអំណោយផល គួបផ្សំនឹងឥទ្ធិពលនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់។ ទោះយ៉ាងណា វិស័យនេះងាយរងឥទ្ធិពលខ្លាំងពីការប្រែប្រួលអាកាសធាតុ ដែលទាមទារឱ្យមានការបន្សាំដើម្បីកាត់បន្ថយហានិភ័យផ្សេងៗទាក់ទងនឹងបញ្ហាអាកាសធាតុ។

**វិស័យសំណង់បានបន្តងើបឡើងសន្សឹមៗ បន្ទាប់ពីវិបត្តិកូវីដ-១៩ ប៉ុន្តែវិស័យអចលនទ្រព្យនៅបន្តទទួលរងផលប៉ះពាល់ពីកត្តាខាងក្រៅ។** វិស័យសំណង់បានកើនឡើង ១,៥% (ក្រាហ្វ ១.១៩) ដែលត្រូវបានគាំទ្រដោយការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ប៉ុន្តែនៅមានកម្រិតទាបជាងអត្រាកំណើនមធ្យម ១៨,៥% ក្នុងអំឡុងទសវត្សរ៍ឆ្នាំ២០១០។ វិស័យអចលនទ្រព្យដែលជាទូទៅមាននិន្នាការកើនឡើងស្របគ្នានឹងវិស័យសំណង់ បានថយចុះបន្តិច ជាមួយកំណើនអវិជ្ជមាន -០,៩%។

**តម្លៃលំនៅឋាន បានធ្លាក់ចុះនៅឆមាសទី២ ឆ្នាំ២០២៣ ក្នុងស្ថានភាពមិនប្រាកដប្រជានៃកត្តាខាងក្រៅ។** ក្រោយឥទ្ធិពលអវិជ្ជមាននៃការកើនឡើងករណីឆ្លងជំងឺកូវីដ-១៩ ប្រភេទអូមីក្រុងនៅកម្ពុជាបានបញ្ចប់ តម្លៃលំនៅឋានបានចាប់ផ្តើមងើបឡើងវិញនៅឆមាសទី២ ឆ្នាំ២០២២ ប៉ុន្តែតម្លៃនេះ បានចាប់ផ្តើមធ្លាក់ចុះម្តងទៀតនៅពាក់កណ្តាលឆ្នាំ២០២៣។ នៅខែធ្នូ ឆ្នាំ២០២៣នេះ តម្លៃលំនៅឋានជារួម បានធ្លាក់ចុះ ២,៩% (ឆ្នាំលើឆ្នាំ) ដោយនៅរាជធានីភ្នំពេញ តម្លៃលំនៅឋានបានធ្លាក់ថ្លៃ ៣,៩% ខណៈនៅតាមបណ្តាខេត្ត តម្លៃបាន

**១.១៩ កំណើននៃវិស័យកសិកម្ម សំណង់ និង អចលនទ្រព្យ**

(គិតជាភាគរយ, ឆ្នាំ២០១៨ - ២០២៣)




ប្រភព៖ ៖ វិទ្យាស្ថានជាតិស្ថិតិ

**១.២០ សន្ទស្សន៍ថ្លៃលំនៅឋាន**

(បម្រែបម្រួលប្រចាំឆ្នាំគិតជាភាគរយ)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

កើន ៣,៦% (ក្រាហ្វ ១.២០)។ ការធ្លាក់ថ្លៃនេះ ជាចម្បង បណ្តាលមកពីការដើបឡើងយឺតនៃវិស័យអចលនទ្រព្យ ដូចដែលបានឆ្លុះបញ្ចាំងតាមរយៈការថមថយនៃលំហូរវិនិយោគផ្ទាល់ពីបរទេសមកកាន់វិស័យនេះ ដោយសារការផ្គត់ផ្គង់លើស និងភាពមិនប្រាកដប្រជានៃកត្តាខាងក្រៅ រួមមាន បញ្ហាអចលនទ្រព្យនៅប្រទេសចិន និងការរឹតត្បិតនៃស្ថានភាពហិរញ្ញវត្ថុអន្តរជាតិ ជាដើម។

## ខ. ស្ថានភាពអតិផរណា និងរូបិយវត្ថុ

**អតិផរណាបានថយចុះពី ៥,៤% ក្នុងឆ្នាំ ២០២២ មកត្រឹម ២,១% ក្នុងឆ្នាំ ២០២៣ ដោយសារតែការថយចុះនៃថ្លៃក្រុមទំនិញពាក់ព័ន្ធនឹងប្រេងឥន្ធនៈ និងការថយចុះនៃអតិផរណាក្រុមម្ហូបអាហារ និងក្រុមអតិផរណាស្នូល (ក្រាហ្វ ១.២១)។** ថ្លៃក្រុមទំនិញពាក់ព័ន្ធនឹងប្រេងឥន្ធនៈបានធ្លាក់ចុះ ២,៧% បន្ទាប់ពីតម្លៃប្រេងឆៅសកលជាមធ្យមធ្លាក់ចុះ ១៦,៨% ក្នុងឆ្នាំ ២០២៣។ ការធ្លាក់ចុះនេះបានធ្វើឱ្យអតិផរណាក្រុមម្ហូបអាហារនៅកម្ពុជាបានថយមកត្រឹម ៣,២% ក្នុងឆ្នាំ២០២៣ ពី ៥% កាលពីឆ្នាំ២០២២ ដោយសម្ពាធទៅលើថ្លៃជីកសិកម្ម ប្រេងឥន្ធនៈ និងថ្លៃដឹកជញ្ជូន បានធូរស្រាល។ ទន្ទឹមនេះ អតិផរណាស្នូលក៏បានថយចុះមកត្រឹម ២% ពី ៤,៤% ផងដែរ។

**កំណើនរូបិយវត្ថុទូទៅបានកើន ១២,៥% ស្របតាមស្ថានភាពសេដ្ឋកិច្ច (ក្រាហ្វ ១.២២)។** កំណើននេះត្រូវបានគាំទ្រដោយកំណើននៃប្រាក់បញ្ញើជារៀល (១៤,១%) ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស (១៣%) និងរូបិយវត្ថុក្នុងចរាចរណ៍ (៥,៩%)។ គួររំលេចថា កំណើននៃប្រាក់បញ្ញើសរុបក្នុងឆ្នាំ២០២៣ (១៣,១%) មានកម្រិតខ្ពស់ជាងឆ្នាំ២០២២ (៩,៣%) បើទោះជាឆ្នាំ២០២៣ ជាឆ្នាំមានការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រក៏ដោយ។ ការណ៍នេះបានបង្ហាញពីជំនឿទុកចិត្តរបស់សាធារណជនចំពោះសេដ្ឋកិច្ច និងប្រព័ន្ធធនាគារកម្ពុជាកាន់តែមានភាពរឹងមាំជាងមុន។

**ដុល្លារូបនីយកម្មហិរញ្ញវត្ថុនៅតែមានកម្រិតខ្ពស់ ទោះជាមានកិច្ចខិតខំប្រឹងប្រែងពីធនាគារជាតិនៃកម្ពុជា នៅក្នុងការលើកកម្ពស់ប្រាក់រៀល។** ដុល្លារូបនីយកម្ម

**១.២១ ការរួមចំណែកក្នុងអតិផរណា**

(គិតជាភាគរយ, ឆ្នាំ២០១៨ - ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**១.២២ រូបិយវត្ថុទូទៅ M2**

(ឆ្នាំ២០១៨ - ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ហិរញ្ញវត្ថុវាស់វែងដោយប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស ធៀបនឹងរូបិយវត្ថុទូទៅ បន្តមានកម្រិតខ្ពស់លើស ៨០% ដែលជាកម្រិតមួយថេរ អស់រយៈពេលជាងមួយទសវត្សរ៍មកហើយ ខណៈដែលប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស ធៀបនឹងប្រាក់បញ្ញើសរុប បានថយចុះបន្តិចក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប៉ុន្តែនៅតែមានកម្រិតខ្ពស់ប្រមាណ ៩០% (ក្រាហ្វ ១.២៣)។ ការណ៍នេះសបញ្ជាក់ថា ដើម្បីកាត់បន្ថយកម្រិតដុល្លាររូបនីយកម្ម កិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ មានសារៈសំខាន់ណាស់ ដោយសារភាពប្រទាក់ក្រឡាគ្នារវាងដុល្លាររូបនីយកម្មនៅក្នុងវិស័យហិរញ្ញវត្ថុ និងវិស័យរូបវន្ត។

### គ. វិស័យសារពើពន្ធ

**ការថមថយចំណូល គួបផ្សំនឹងការកើនឡើងនៃចំណាយ បានធ្វើឱ្យសារពើពន្ធរួមរបស់រាជរដ្ឋាភិបាលបន្តមានឱនភាពក្នុងកម្រិតខ្ពស់ជាងមុន។** ឱនភាពសារពើពន្ធបានបន្តកើនឡើង ពី ០,៩% នៃផ.ស.ស. ក្នុងឆ្នាំ២០២២ ដល់ ២,៦% នៃផ.ស.ស. នៅឆ្នាំ២០២៣ (ក្រាហ្វ ១.២៤)។ ឱនភាពបានកើតមានអស់រយៈពេល៤ឆ្នាំជាប់គ្នា ចាប់តាំងពីឆ្នាំ២០២០ នៅពេលប្រទេសកម្ពុជាទទួលរងផលប៉ះពាល់ពីវិបត្តិកូវីដ-១៩។

**ប្រាក់ចំណូលបានធ្លាក់ចុះ ៤,៧% ជាចម្បងបណ្ដាលមកពីការធ្លាក់ចុះនៃចំណូលពន្ធ** (ក្រាហ្វ ១.២៥)។ ប្រាក់ចំណូលរបស់រាជរដ្ឋាភិបាល មានចំនួន ២៥,២ ទ្រីលានរៀល (៦,១ ប៊ីលានដុល្លារអាមេរិក) ក្នុងនោះ ចំណូលពីការប្រមូលពន្ធរួមចំណែក ៨៤,២% ឬស្មើនឹង ២១,២ ទ្រីលានរៀល (៥,២ ប៊ីលានដុល្លារអាមេរិក)។ ការធ្លាក់ចុះចំណូលពន្ធនេះ បណ្ដាលមកពីការថមថយនៃការប្រើប្រាស់ក្នុងស្រុក និងការធ្លាក់ចុះការនាំចូល ស្របពេលដែលការកើនឡើងនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក៏បានរួមចំណែកខ្លះផងដែរ។ ជារួម ចំណូលពន្ធបានធ្លាក់ចុះ ៤,៣% ដោយក្នុងនោះពន្ធលើទំនិញ និងសេវាបានធ្លាក់ចុះ ១១,៧% និងពន្ធលើពាណិជ្ជកម្ម

**១.២៣ ដុល្លាររូបនីយកម្ម**

(គិតជាភាគរយ, ឆ្នាំ២០១៨-២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**១.២៤ គណនីសារពើពន្ធ**

(ជាភាគរយនៃផ.ស.ស., ឆ្នាំ២០១៨-២០២៣)




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**១.២៥ ការរួមចំណែកក្នុងកំណើនប្រាក់ចំណូល**

(ជាភាគរយ ឆ្នាំ២០១៨-២០២៣)




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អន្តរជាតិធ្លាក់ចុះ ១,២% ខណៈដែលពន្ធលើប្រាក់ចំណូល ប្រាក់ចំណេញ និងដើមទុនបានកើនឡើង ៦,៩%។

**ចំណាយលើការរៀបចំព្រឹត្តិការណ៍កីឡាស៊ីហ្គេម អាស៊ានប៉ារ៉ាហ្គេម និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ព្រមទាំងការចំណាយលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ បានធ្វើឱ្យប្រាក់ចំណាយសរុបរបស់រាជរដ្ឋាភិបាលកើនឡើង។** ក្នុងឆ្នាំ២០២៣ រាជរដ្ឋាភិបាលបានចំណាយ ២៩,៧ ទ្រីលានរៀល (៧,២ ប៊ីលានដុល្លារអាមេរិក) ដែលកើនឡើង ៩,៨% ធៀបនឹងឆ្នាំមុន (ក្រាហ្វ ១.២៦)។ ចំណាយចរន្តបានកើន ១០,១% ក្នុងនោះប្រាក់ឈ្នួលកើន ៧,៩% អំណោយដល់អង្គភាពទូទៅផ្សេងទៀតកើន ៦៥,៩% និងអត្ថប្រយោជន៍សង្គមកើន ១០% ដោយសាររាជរដ្ឋាភិបាល នៅបន្តអនុវត្តកម្មវិធីជួយដល់គ្រួសារងាយរងគ្រោះពីវិបត្តិកូវីដ-១៩ និងពីការកើនឡើងនៃអតិផរណា។ ទន្ទឹមនេះ ការប្រើប្រាស់ទំនិញ និងសេវាបានធ្លាក់ចុះ ៩,៦% ខណៈដែលចំណាយមូលធនបានកើនឡើង ៩,៩% ដល់ ៨,៤ ទ្រីលានរៀល ។

**បំណុលរបស់រាជរដ្ឋាភិបាល ធៀបនឹងផ.ស.ស. បានកើនឡើងបន្តិច ហើយ ៩៩% នៃបំណុលសរុបជាបំណុលក្រៅប្រទេស[៦]។** បំណុលក្រៅប្រទេសរបស់រាជរដ្ឋាភិបាលបានកើន ១២,២% ដល់ ១១,២ ប៊ីលានដុល្លារអាមេរិក ស្មើនឹង២៦,២% នៃផ.ស.ស. នៅឆ្នាំ២០២៣ កើនពី ២៥% នៃផ.ស.ស. នៅឆ្នាំ២០២២ សម្រាប់ផ្តល់ហិរញ្ញប្បទានដល់គម្រោងវិនិយោគសាធារណៈ ក្នុងវិស័យអាទិភាពមួយចំនួន (ក្រាហ្វ ១.២៧)។ ចិនជាប្រទេសផ្តល់ប្រាក់កម្ចីច្រើនជាងគេ ដែលមានសមាមាត្រ ៣៦,៨% នៃបំណុលក្រៅប្រទេសសរុបរបស់រាជរដ្ឋាភិបាល បន្ទាប់មក គឺកម្ចីពហុភាគី (៣៥,៧%) ប្រទេសជប៉ុន (១១,២%) និងប្រទេសកូរ៉េ (៥,១%) (ក្រាហ្វ ១.២៨)។ ជារួម បំណុលក្រៅប្រទេសរបស់រាជរដ្ឋាភិបាលនៅតែមានចីរភាព ដោយស្ថិតក្នុងកម្រិតទាបជាងកម្រិតពិដាន ៤០%។ ដូចនេះ រាជរដ្ឋាភិបាលអាចមានលទ្ធភាពខ្ចី ដើម្បីផ្តល់ហិរញ្ញប្បទាន

**១.២៦ ការរួមចំណែកក្នុងកំណើនប្រាក់ចំណាយ**

(ជាភាគរយ, ឆ្នាំ២០១៨-២០២៣)




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**១.២៧ បំណុលរដ្ឋាភិបាលក្រៅប្រទេស**

(ជាភាគរយនៃផ.ស.ស ឆ្នាំ២០១៨-២០២៣)




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**១.២៨ សមាមាត្របំណុលរដ្ឋាភិបាលក្រៅប្រទេស បែងចែកតាមប្រទេសចម្បងៗ**

(ជាភាគរយ, គិតត្រឹមឆ្នាំ២០២៣)




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

---

[៦] ធៀបទៅនឹងទិន្នន័យក្នុងរបាយការណ៍ស្ថិរភាពហិរញ្ញវត្ថុ ឆ្នាំ២០២២ បំណុលក្រៅប្រទេសរបស់រាជរដ្ឋាភិបាលធៀបនឹង ផ.ស.ស. មានកម្រិតតិចជាងមុន ដោយសាររបាយការណ៍នេះប្រើប្រាស់ទិន្នន័យផ.ស.ស. តាមឆ្នាំគោលថ្មី ឆ្នាំ២០១៤ ដែលមានទំហំធំ ជាង ផ.ស.ស. ឆ្នាំគោលចាស់ ប្រមាណ ៣០%។

ដល់គម្រោងអភិវឌ្ឍន៍ចាំបាច់បន្ថែមទៀត។ ប៉ុន្តែ ដោយសារកម្ពុជាស្ថិតក្នុងដំណាក់កាលឈានទៅកាន់ការចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច រាជរដ្ឋាភិបាលត្រូវមានការប្រុងប្រយ័ត្នជាងមុន ដោយសារលទ្ធភាពទទួលបានកម្ចីសម្បទានដែលមានអត្រាការប្រាក់ទាបនឹងមានតិចជាងមុន។

## ១.៣ សន្និដ្ឋាន

សេដ្ឋកិច្ចកម្ពុជាបានបន្តងើបឡើងពីវិបត្តិកូវីដ-១៩ ប៉ុន្តែការងើបឡើងនេះមានភាពខុសគ្នាទៅតាមវិស័យ ហើយកំណើនផ.ស.ស. នៅមានកម្រិតទាបជាងគ្រាមុនវិបត្តិកូវីដ-១៩។ វិស័យសេវាកម្មដែលទាក់ទងនឹងវិស័យទេសចរណ៍បន្តងើបឡើងវិញ ប៉ុន្តែកំណើននៃវិស័យអចលនទ្រព្យថយចុះបន្តិច។ លើសពីនេះ កំណើនក្នុងវិស័យកម្មន្តសាលក៏ទទួលរងសម្ពាធដោយសារភាពទន់ខ្សោយនៃតម្រូវការខាងក្រៅ។ នៅក្នុងស្ថានភាពប្រឈមនេះ សមតុល្យជញ្ជីងទូទាត់ និងសារពើពន្ធគិតជាភាគរយនៃ ផ.ស.ស. មានឱនភាពបន្តិច ប៉ុន្តែអត្រាប្តូរប្រាក់រៀលបន្តមានស្ថិរភាព។ ទន្ទឹមនេះ អតិផរណាបានធ្លាក់ចុះ និងទុនបម្រុងអន្តរជាតិបានកើនឡើង ដែលជារូមបង្ហាញពីភាពធន់និងស្ថិរភាពនៃម៉ាក្រូសេដ្ឋកិច្ច។ ដើម្បីផ្តល់ហិរញ្ញប្បទានដល់គម្រោងវិនិយោគសាធារណៈ បំណុលរាជរដ្ឋាភិបាលធៀបទៅនឹង ផ.ស.ស. បានបន្តកើនឡើងបន្តិច ប៉ុន្តែរក្សាបាននូវចីរភាព។

# II ប្រព័ន្ធធនាគារៈ សមិទ្ធកម្ម និងស្ថិរភាព

ប្រព័ន្ធធនាគារបន្តរក្សាបានភាពធន់និងមានភាពរឹងមាំ ដោយបានផ្តល់មូលនិធិចាំបាច់សម្រាប់គាំទ្រការងើបឡើងវិញនៃសេដ្ឋកិច្ចពីវិបត្តិកូវីដ-១៩ ទោះជាមានការកើនឡើងហានិភ័យឥណទាន។ គ្រឹះស្ថានធនាគារពាណិជ្ជមានសមាមាត្រធំជាងគេក្នុងប្រព័ន្ធធនាគារ និងបានកើនដល់ប្រមាណ ៩១% នៃទ្រព្យសកម្មសរុប នៅឆ្នាំ២០២៣ បន្ទាប់មកគឺគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (MDI) និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ (MFI)។ កំណើនទ្រព្យសកម្ម និងឥណទាន បានថមថយមក ៨,២% និង ៤,២% រៀងគ្នា នៅឆ្នាំ២០២៣។ ទោះជាកំណើនឥណទានធនាគារនៅមានស្ថានភាពល្អក្នុងកម្រិត ១៦,៤% កំណើននេះជាឥទ្ធិពលនៃការរួមបញ្ចូលគ្នារវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមួយ និងធនាគារពាណិជ្ជមួយ។ ប្រសិនបើធ្វើការកែតម្រូវទិន្នន័យលើការរួមបញ្ចូលគ្នានេះ ឥណទានធនាគារនៅគ្រប់វិស័យបានថយល្បឿនគួរឱ្យកត់សម្គាល់ ដោយសារកម្រិតអត្រាការប្រាក់ខ្ពស់ កម្រិតបំណុលកើនឡើង និងការផ្តល់ឥណទានប្រកបដោយភាពប្រុងប្រយ័ត្នរបស់គ្រឹះស្ថានធនាគារ។ ឥណទានធនាគារសរុបកើនដល់ ២១១ ទ្រីលានរៀល (៥១,៦ ប៊ីលានដុល្លារអាមេរិក) ដែលភាគច្រើនត្រូវបានផ្តល់ទៅឱ្យវិស័យឯកជន។ ឥណទានទៅកាន់ការជួញដូរដុំនិងរាយមានសមាមាត្រប្រមាណ ២៦,៧% នៃឥណទានធនាគារសរុប ខណៈដែលសមាមាត្រឥណទានអចលនទ្រព្យ និងសំណង់បានកើនដល់ ២០,៣%។ កំណើនឥណទានទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួនរបស់អង្គភាពគ្រួសារបានថយចុះយ៉ាងខ្លាំង ប៉ុន្តែឥណទានបុគ្គលបានកើនឡើងជាថ្មីម្តងទៀតជាលទ្ធផលនៃការរួមបញ្ចូលគ្នារវាងធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។ យ៉ាងណាមិញ អនុបាតឥណទានមិនដំណើរការបានកើនពី ២,៩% ក្នុងឆ្នាំ២០២២ ដល់ ៥,១% ក្នុងឆ្នាំ២០២៣ ដែលបង្ហាញអំពីការព្រួយបារម្ភនៃការថយចុះគុណភាពទ្រព្យសកម្ម ក្រោយពីការបញ្ចប់វិធានការអនុគ្រោះបទប្បញ្ញត្តិលើការរៀបចំឥណទានរបស់ធនាគារជាតិនៃកម្ពុជា។ ចំពោះស្ថានភាពសន្ទនីយភាព អនុបាតក្របខ័ណ្ឌសន្ទនីយភាពរបស់ធនាគារបន្តមានភាពល្អនិងមានកម្រិតខ្ពស់ជាងកម្រិតកំណត់ដោយបទប្បញ្ញត្តិ ១០០% ទោះជា សូចនាករសន្ទនីយភាពផ្សេងទៀតបានបង្ហាញពីការថមថយបន្តិច។ ប្រាក់ចំណេញសុទ្ធរបស់ធនាគារបានធ្លាក់ចុះ ៤៥% ដោយសារចំណាយលើការប្រាក់និងសំវិធានធនខ្ពស់។ ទោះយ៉ាងណា អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់ធនាគារមានកម្រិតខ្ពស់ ២២,៣% លើសពីកម្រិត កំណត់ដោយបទប្បញ្ញត្តិ ១៥% ដែលឆ្លុះបញ្ចាំងពីលទ្ធភាពស្រូបយកការខាតបង់របស់ធនាគារ និងការពារនូវឥទ្ធិពលនៃការប៉ះទង្គិចណាមួយដោយមិនបានរំពឹងទុក។ នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ទ្រព្យសកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ បានថយចុះស្មើរពាក់កណ្តាល បន្ទាប់ពីការរួមបញ្ចូលគ្នា ដែលនាំឱ្យឥណទានធ្លាក់ចុះ ៤៦% ផងដែរ។ គុណភាពឥណទានបានថយចុះបន្តិច ប៉ុន្តែស្ថិតនៅកម្រិតអាចគ្រប់គ្រងបាន ជាមួយនឹងការធ្វើសំវិធានធនគ្រប់គ្រាន់និងភាពរឹងមាំនៃដើមទុនឆ្លុះបញ្ចាំងតាមរយៈអនុបាតភាពគ្រប់គ្រាន់នៃដើមទុនខ្ពស់ ២២,៩% សម្រាប់ MDI និង ៣១,៦% សម្រាប់ MFI។ ទោះយ៉ាងណា ការធ្វើសំវិធានធនគ្រប់គ្រាន់ និងការផ្តល់ឥណទានប្រកបដោយភាពប្រុងប្រយ័ត្នបានរួមចំណែកដល់ការធ្លាក់ចុះនៃប្រាក់ចំណេញសុទ្ធរបស់វិស័យមីក្រូហិរញ្ញវត្ថុ។ សម្រាប់ធនាគារឯកទេស កំណើនឥណទានបានថយចុះមកត្រឹម ១,៦% ខណៈដែល អនុបាតឥណទានមិនដំណើរការកើនដល់ ១២,១% និងអនុបាតភាពគ្រប់គ្រាន់នៃដើមទុនបន្តមានភាពរឹងមាំ ៣៩%។

## ២.១ ទិដ្ឋភាពប្រព័ន្ធធនាគារ

**វិស័យធនាគារដែលបានដើរតួនាទីស្នូលនៃប្រព័ន្ធហិរញ្ញវត្ថុកម្ពុជាត្រូវបានពង្រឹងបន្ថែមទៀត ដោយសារការរួមបញ្ចូលគ្នារវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើធំមួយជាមួយធនាគារមួយ។** ធនាគារពាណិជ្ជមានសមាមាត្រធំជាងគេក្នុងប្រព័ន្ធធនាគារនៅកម្ពុជា ដោយធនាគារពាណិជ្ជចំនួន ៥៨ មានទ្រព្យសកម្ម ៣១៤,៣ ទ្រីលានរៀល (៧៦,៩ ប៊ីលានដុល្លារអាមេរិក) គិតត្រឹមខែធ្នូ ឆ្នាំ២០២៣ ប្រហែល ៩១% នៃប្រព័ន្ធធនាគារកម្ពុជា[៧] ហើយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ៤ មានសមាមាត្រ ៥,៤%។ ការធ្វើទំនើបកម្ម និងការរួមបញ្ចូលគ្នាជាបន្តបន្ទាប់នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ភីអិលស៊ី ដែលជាគ្រឹះស្ថានដ៏ធំមួយចូលទៅក្នុងធនាគារពាណិជ្ជ នៅចុងឆ្នាំ២០២៣ បានកាត់បន្ថយសមាមាត្រនៃ MDI ជាងពាក់កណ្តាលធៀបនឹងឆ្នាំមុន ប៉ុន្តែបានបង្កើនសមាមាត្រទ្រព្យសកម្មក្នុងធនាគារពាណិជ្ជបន្ថែមទៀត[៨]។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៨៣ (មិនទទួលប្រាក់បញ្ញើ) និងធនាគារឯកទេស ៩ មានសមាមាត្រទ្រព្យសកម្ម ២,២% និង០,៨% នៃប្រព័ន្ធធនាគារសរុប រៀងគ្នា ហើយ ១% ទៀតត្រូវបានរួមចំណែកដោយ គ្រឹះស្ថានភតិសន្យា ១៦ និងគ្រឹះស្ថានឥណទានជនបទ ១១៤។ នៅឆ្នាំ២០២៣ អាជ្ញាប័ណ្ណរបស់គ្រឹះស្ថានឥណទានជនបទ ១០៥ ត្រូវបានដកហូត ដើម្បីពង្រឹងការអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន និងដើម្បីបង្កើនភាពរឹងមាំនៃវិស័យឥណទានជនបទ។

**តារាង ២.១៖ រចនាសម្ព័ន្ធប្រព័ន្ធធនាគារកម្ពុជា**
(ខែធ្នូ ឆ្នាំ២០២៣)

| គ្រឹះស្ថាន | ចំនួន | ទ្រព្យសកម្ម (ទ្រីលានរៀល) | សមាមាត្រ (% នៃទ្រព្យសកម្មសរុប) |
|---|---|---|---|
| ធនាគារពាណិជ្ជ | ៥៨ | ៣១៤,៣ | ៩១,០% |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | ៤ | ១៨,៦ | ៥,៤% |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ | ៨៣ | ៧,៥ | ២,២% |
| ធនាគារឯកទេស | ៩ | ២,៦ | ០,៨% |
| គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ | ១៦ | ២,០ | ០,៦% |
| គ្រឹះស្ថានឥណទានជនបទ | ១១៤ | ០,៣ | ០,១% |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[៧] ប្រព័ន្ធធនាគារ៖ ធនាគារពាណិជ្ជ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ធនាគារឯកទេស គ្រឹះស្ថានភតិសន្យា និងគ្រឹះស្ថានឥណទានជនបទ ស្របតាម បទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។ ដូចដែលបានរៀបរាប់នៅក្នុងជំពូកទី ៣ ទំហំនៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារ (ជាចម្បងក្រុមហ៊ុនធានារ៉ាប់រង) គឺមិនទាន់អាចប្រៀបធៀបបាន ហើយទាំងទីផ្សារភាគហ៊ុន និងមូលបត្របំណុលនៅតែស្ថិតក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍ។ ខណៈពេលដែលការផ្តល់ប្រាក់កម្ចីពីធនាគារស្រមោល (អ្នកអភិវឌ្ឍន៍អចលនទ្រព្យ) ហាក់ដូចជាមានទំហំតូច ហើយទិន្នន័យមិនអាចរកបានដើម្បីកំណត់ទំហំពិតប្រាកដនៃការប៉ះពាល់នោះទេ។

[៨] នៅឆ្នាំ២០២៣ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ភីអិលស៊ី ដែលជា MDI ធំជាងគេតាមទំហំទ្រព្យសកម្ម ត្រូវបានបញ្ចូលជាមួយធនាគារ គូកមីន ខេមបូឌា ភីអិលស៊ី ដើម្បីក្លាយជាធនាគារខេប៊ីប្រាសាក់។ ការរួមបញ្ចូលគ្នានេះមានផលប៉ះពាល់តែមួយដងលើអនុបាតច្រើន ទាំងសម្រាប់ធនាគារ និង MDIs។

ប្រព័ន្ធធនាគារបានបន្តអភិវឌ្ឍ និងកាន់តែរីក-ចម្រើន ទោះជាកំណើនបានថមថយស្របពេលមានការថយចុះនៃកំណើនឥណទាន។ នៅចុងឆ្នាំ២០២៣ ទ្រព្យសកម្មសរុបនៃវិស័យធនាគារ[៩] ឈានដល់ ៣៨៣,១ ទ្រីលានរៀល ជាមួយកំណើនប្រចាំឆ្នាំ ៨,២% (ក្រាហ្វ ២.១)។ ជាការកត់សម្គាល់ កំណើនឥណទានបានធ្លាក់ចុះពី ១៩% ក្នុងឆ្នាំ២០២២ មក ៤,២% នៅឆ្នាំ២០២៣ ដោយសារអត្រាការប្រាក់ខ្ពស់ កម្រិតបំណុលកើនឡើង និងការផ្តល់ឥណទានប្រកបដោយភាពប្រុងប្រយ័ត្នរបស់ធនាគារដែលបានដាក់សម្ពាធលើកំណើនឥណទាន។ ម៉្យាងវិញទៀត កំណើនប្រាក់បញ្ញើ (១៣%) មានភាពប្រសើរឡើង បើធៀបនឹងឆ្នាំមុន (៩,២%) ដែលអាចបណ្តាលមកពីការផ្តល់អត្រាការប្រាក់ខ្ពស់ របស់គ្រឹះស្ថានក្នុងការទាក់ទាញអតិថិជន។

ស្របពេលដែលមានការថយចុះខ្លាំងនៃកំណើនឥណទាន គម្លាតឥណទានធៀបនឹង ផ.ស.ស. បានរួមតូចផងដែរ (ក្រាហ្វ ២.២)។ នៅក្នុងលក្ខខណ្ឌ ដែលឥណទានធៀបនឹងផ.ស.ស.[១០] នៅមានកម្រិតខ្ពស់ ទោះជាសមាមាត្របានថយចុះបន្តិចមក ១៣៣% ក្នុងឆ្នាំ២០២៣។ ទោះយ៉ាងណា គម្លាតឥណទានធៀបនឹងផ.ស.ស.[១១] បានធ្លាក់ចុះយ៉ាងឆាប់រហ័សពីកម្រិត ២៩% នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២២ ដល់ ១១,៥% នៅបំណាច់ឆ្នាំ២០២៣។ បើទោះជា គម្លាតឥណទានរួមតូចក៏ដោយ គម្លាតនេះនៅតែលើសពីកម្រិត ១០% របស់គោលការណ៍បាសែល ដែលត្រូវតែធានាឱ្យមានការត្រួតពិនិត្យយ៉ាងហ្មត់ចត់ ដើម្បីធានាថាធនាគារផ្តល់ឥណទានប្រកបដោយភាពប្រុងប្រយ័ត្ន ហើយគុណភាពឥណទាននៅតែមានសុខភាពល្អ។

២.១ ប្រព័ន្ធធនាគារនៅកម្ពុជា
(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

២.២ ឥណទានធៀបផ.ស.ស. និងកំណើនឥណទាន
(គិតជាភាគរយ, ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[៩] សម្រាប់ក្រាហ្វ ២.១ ដល់ ២.៣ ប្រព័ន្ធធនាគាររាប់បញ្ចូល គ្រឹះស្ថានធនាគារពាណិជ្ជ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ និងគ្រឹះស្ថានធនាគារឯកទេស (លើកលែងតែទិន្នន័យប្រាក់បញ្ញើដែលរាប់បញ្ចូលតែធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើប៉ុណ្ណោះ)។ គ្រឹះស្ថានផ្សេងៗទៀតដូចជា គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ និងគ្រឹះស្ថានឥណទានជនបទ មិនត្រូវបានរាប់បញ្ចូលនៅទីនេះទេ ដោយសារទិន្នន័យនៅមិនទាន់មានគ្រប់គ្រាន់ ហើយសមាមាត្រនៃគ្រឹះស្ថានទាំងពីរក្នុងប្រព័ន្ធមានទំហំតូច ដូចដែលបានបង្ហាញនៅក្នុងតារាង ២.១។

[១០] នៅទីនេះ ឥណទានរាប់បញ្ចូលឥណទានរបស់ធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ។ ក្នុងជំពូកនេះ ផ.ស.ស. ដែលត្រូវបានប្តូរឆ្នាំមូលដ្ឋានមកឆ្នាំ២០១៤ របស់វិទ្យាស្ថានជាតិស្ថិតិ ត្រូវបានប្រើប្រាស់ក្នុងការគណនា។

[១១] គម្លាតឥណទានធៀបនឹងផ.ស.ស. ជាភាពខុសគ្នារវាងអនុបាតឥណទានធៀបនឹងផ.ស.ស. និងនិន្នាការរយៈពេលវែងរបស់អនុបាតនេះ ដែលត្រូវបានវាស់ដោយ one-sided HP filter ជាមួយនឹងប៉ារ៉ាម៉ែត្រ ៤០០.០០០។

វិស័យធនាគារនៅតែមានទំហំធំបើធៀបនឹង ផ.ស.ស.។ ទ្រព្យសកម្មវិស័យធនាគារមាន សមាមាត្រប្រមាណ ១៩៥% នៃផ.ស.ស. នៅឆ្នាំ២០២៣។ ទន្ទឹមនេះ ឥណទាននិងប្រាក់បញ្ញើសរុបរបស់វិស័យធនាគារមានសមាមាត្រ ១៣៣% និង ១១២% នៃផ.ស.ស. រៀងគ្នា (ក្រាហ្វ ២.៣)។ អនុបាតទាំងនេះមានកម្រិតថេរ ដោយសារការថមថយកំណើនទ្រព្យសកម្ម និងឥណទាន។ ទន្ទឹមនេះ កំណើនប្រាក់បញ្ញើបានកើនលើសពីកំណើនឥណទាន ដែលបណ្តាលឱ្យគម្លាតសមាមាត្រឥណទាននិងប្រាក់បញ្ញើធៀបនឹង ផ.ស.ស. បានរួមតូច។

ការកើនឡើងនៃអន្តរការីហិរញ្ញវត្ថុ ឌីជីថលូបនីយកម្ម និងការពង្រីកបណ្តាញសាខារបស់ធនាគារបានជួយជំរុញបរិយាបន្នហិរញ្ញវត្ថុ។ ការប៉ាន់ស្មានថ្មីៗ[១២] បានបង្ហាញថា ប្រជាជនកម្ពុជាប្រហែល ៦៧% បានទទួលសេវាហិរញ្ញវត្ថុផ្សេងៗ។ ប៉ុន្មានឆ្នាំកន្លងមកនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានឥណទានជនបទបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវាហិរញ្ញវត្ថុដល់ប្រជាពលរដ្ឋនៅជនបទ ដូចជាការផ្តល់ឥណទានទៅកាន់វិស័យកសិកម្ម និងសហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) ជាដើម។ លើសពីនេះទៅទៀត ធនាគារក៏បានបន្តពង្រីកសាខារបស់ខ្លួនបន្ថែមទៅកាន់តំបន់ជនបទផងដែរ។

## ២.២ គ្រឹះស្ថានធនាគារពាណិជ្ជ

### ក. អន្តរការីយកម្មឥណទាន និងហានិភ័យឥណទាន

**ធនាគារពាណិជ្ជបានពង្រីកការផ្តល់ឥណទានស្ទើរតែទាំងស្រុងទៅកាន់វិស័យឯកជន ដោយវិស័យសាជីវកម្មជាអ្នកនាំមុខ បន្ទាប់មកគឺអង្គភាពគ្រួសារ។** កំណើនឥណទានរបស់ធនាគារដល់វិស័យឯកជននៅតែមានចំនួនពីរខ្ទង់ ដោយបានថយចុះពី ១៨,៣% ក្នុងឆ្នាំ២០២២ មកត្រឹម ១៤,៩% ក្នុងឆ្នាំ២០២៣ (ក្រាហ្វ ២.៤)។ កំណើនពីរខ្ទង់នៃឥណទានធនាគារពាណិជ្ជ (១៤,៩%) គឺច្រើនជាងកំណើនឥណទាននៃប្រព័ន្ធធនាគារ

២.៣ ប្រព័ន្ធធនាគារនៅកម្ពុជា
(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)



ប្រភព៖ ធនាគារជាតិនៃកម្ពុជា

២.៤ ការផ្តល់ឥណទានដោយធនាគារពាណិជ្ជ
(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)



ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[១២] របាយការណ៍មូលនិធិអភិវឌ្ឍន៍ទុនរបស់អង្គការសហប្រជាជាតិ ក្រោមចំណងជើង "បរិយាបន្នហិរញ្ញវត្ថុកម្ពុជា ឆ្នាំ២០២១"។

ទាំងមូល (៤,២%) ដោយសារតែការរួមបញ្ចូលគ្នានៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ[១៣] ជាមួយធនាគារពាណិជ្ជនៅចុងឆ្នាំ២០២៣ ដែលបណ្តាលឱ្យមានការផ្លាស់ប្តូរទំហំឥណទានពីវិស័យមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមកវិស័យធនាគារ[១៤]។

ការបែងចែកការផ្តល់ឥណទានដល់វិស័យសាធារណៈ និងវិស័យឯកជនបង្ហាញថា ឥណទានធនាគារស្ទើរតែទាំងស្រុងត្រូវបានផ្តល់ទៅកាន់វិស័យឯកជន ដោយសមាមាត្រនៃការផ្តល់ឥណទានដល់វិស័យសាធារណៈមានកម្រិតតិចជាង ០,១% ក្នុងឆ្នាំ២០២៣។ លើសពីនេះ ឥណទានសម្រាប់វិស័យសាធារណៈ ភាគច្រើនត្រូវបានផ្តល់ឱ្យសហគ្រាសរដ្ឋ (SOEs)។ ការណ៍នេះមានន័យថា វិស័យឯកជនសឹងតែទាំងស្រុងជាអ្នកទទួលបានឥណទានធនាគារ ដោយធនាគារបានដើរតួនាទីយ៉ាងសកម្មក្នុងការជួយគាំទ្រកំណើនសេដ្ឋកិច្ចតាមរយៈការផ្តល់ឥណទានទៅកាន់វិស័យឯកជន។

**នៅក្នុងវិស័យឯកជន ឥណទានភាគច្រើនត្រូវបានផ្តល់ឱ្យក្រុមហ៊ុនសាជីវកម្ម និងអង្គភាពគ្រួសារ។** ជាពិសេស ក្រុមហ៊ុនសាជីវកម្ម (រួមទាំងអាជីវកម្មគ្រប់ប្រភេទ និងទំហំ) បានទទួលឥណទានជាប្រាក់រៀល ១៦៣,៣ ទ្រីលាននៃឥណទានសរុបក្នុងឆ្នាំ២០២៣ (៧៧,៤% នៃឥណទានវិស័យឯកជន) កើន ១៥%។ ម្យ៉ាងវិញទៀត ឥណទានសរុបសម្រាប់អង្គភាពគ្រួសារបានកើនឡើងដល់ ៤៧,៨ ទ្រីលានរៀល ដែលស្មើនឹង ២២,៦% នៃឥណទានធនាគារទៅកាន់វិស័យឯកជន។ សមាមាត្រនៃការផ្តល់ឥណទានទៅកាន់អង្គភាពគ្រួសារបានរួមតូចពីកម្រិតខ្ពស់ជាងគេ ២៣,៤% ក្នុងឆ្នាំ២០២១ បន្ទាប់ពីមានភាពប្រសើរក្នុងកម្រិត ១៦,៦% នៅឆ្នាំ២០១៧ (ក្រាហ្វ ២.៥)។

**២.៥ ឥណទានធនាគារទៅកាន់វិស័យឯកជន**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ការផ្តល់ឥណទានជាប្រាក់រៀលរបស់ធនាគារបានស្ថិតលើកម្រិតដែលកំណត់ ១០% ទោះបីការផ្តល់**

[១៣] សូមពិនិត្យមើលកំណត់ចំណាំនៅបាតទំព័រទី៨។

[១៤] ការរួមបញ្ចូលគ្នារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់និងធនាគារគូកមីនបានជះឥទ្ធិពលដល់សូចនាករទាំងអស់ទាំងសម្រាប់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដែលទាមទារឱ្យមានការប្រុងប្រយ័ត្នក្នុងការបកស្រាយនិន្នាការ និងជាពិសេសការប្រៀបធៀបទិន្នន័យជាមួយនឹងឆ្នាំ២០២២។

**ឥណទានភាគច្រើននៅតែបន្តជាដុល្លារអាមេរិក។** សម្រាប់ការវិភាគតាមរូបិយប័ណ្ណ ឥណទានជាប្រាក់ដុល្លារអាមេរិក មានទំហំ ៨៨,៥% នៃឥណទានសរុបក្នុងឆ្នាំ២០២៣ ជាមួយនឹងសមាមាត្រនៃឥណទានជាប្រាក់រៀល ប្រហែល ១១,៥% (ក្រាហ្វ ២.៦)។ ក្នុងគោលបំណងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលក្នុងសេដ្ឋកិច្ចដែលមានកម្រិតដុល្លារូបនីយកម្មខ្ពស់ ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសនៅឆ្នាំ២០១៦ ដោយតម្រូវឱ្យធនាគារផ្តល់ឥណទានជាប្រាក់រៀលយ៉ាងហោចណាស់ ១០% នៃសំពៀតឥណទានសរុប។ ដូច្នេះ សមាមាត្រនៃឥណទានជាប្រាក់រៀលក្នុងឥណទានសរុបមានភាពប្រសើរឡើងជាបណ្តើរៗ ចាប់តាំងពីឆ្នាំ២០១៦មក បើទោះជា មានការថមថយបន្តិចក្នុង អំឡុងឆ្នាំ២០២១-២០២២ ដែលបង្ហាញថា កម្រិតឥណទានជាប្រាក់រៀលមានសក្តានុពលខ្ពស់ជាងកម្រិតកំណត់ដែលបានរំពឹងទុកនៅឆ្នាំ២០២០។

ការបែងចែកឥណទានតាមវិស័យសេដ្ឋកិច្ច ជារួមមានលក្ខណៈពិពិធកម្ម ប៉ុន្តែឥណទានធនាគារពាក់កណ្តាលត្រូវបានផ្តល់ទៅវិស័យធំៗពីរ គឺ វិស័យឥណទានទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន សំណង់និងអចលនទ្រព្យ និងវិស័យជួញដូរដុំនិងរាយ។ ឥណទានធនាគារទៅកាន់វិស័យជួញដូររាយបន្តមានទំហំធំជាងគេ ដោយមានចំនួន ៣៧,១ ទ្រីលានរៀល និងសមាមាត្រ ១៧,៦% នៃឥណទានធនាគារសរុបនៅឆ្នាំ២០២៣។ ខណៈដែលមានមតិមួយចំនួនបានយល់ឃើញថា វិស័យអចលនទ្រព្យ ឬវិស័យសំណង់ គឺជាវិស័យដែលទទួលបានឥណទានធនាគារច្រើនជាងគេ ជាក់ស្តែង វិស័យជួញដូរដុំនិងរាយមានសមាមាត្រឥណទានធំជាងគេ (ក្រាហ្វ ២.៧)។ គួរកត់សម្គាល់ថា ធនាគារបានផ្តល់ឥណទានមួយផ្នែកសម្រាប់សកម្មភាពសំណង់ និងអចលនទ្រព្យប៉ុណ្ណោះ ខណៈដែលហិរញ្ញប្បទានចម្បងនៃវិស័យនេះ គឺបានមកពីការវិនិយោគផ្ទាល់បរទេស។

**ឥណទានទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួនសម្រាប់អង្គភាពគ្រួសារមានចំនួន ២៨,២ ទ្រីលានរៀល ដែលជាវិស័យធំទី២ និងមានសមាមាត្រ ១៣,៤% នៃឥណទាន**

**២.៦ ឥណទានធនាគារតាមប្រភេទរូបិយប័ណ្ណ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**២.៧ ឥណទានធនាគារតាមវិស័យ តម្លៃនិងសមាមាត្រ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**សរុបក្នុងឆ្នាំ២០២៣។** ការផ្តល់ឥណទានដល់សកម្មភាពអចលនទ្រព្យមាន ១០,៥% នៃឥណទានសរុប។ ឥណទានត្រូវបានផ្តល់ទៅកាន់ ៤ វិស័យ ក្នុងសមាមាត្រប្រហាក់ប្រហែលគ្នា (សំណង់ បុគ្គល ការជួញដូរដុំ និងកសិកម្ម) ដោយសារវិស័យនីមួយៗមានសមាមាត្រយ៉ាងតិច ៩% ឬខ្ពស់ជាងនេះ។ ឥណទានទៅកាន់វិស័យសណ្ឋាគារ និងភោជនីយដ្ឋានមានសមាមាត្រ ៤% ហើយវិស័យនេះបានរងផលប៉ះពាល់យ៉ាងខ្លាំងពីការបិទខ្ទប់នៃវិបត្តិកូវីដ-១៩កន្លងមក និងការធ្លាក់ចុះចំនួនភ្ញៀវទេសចរ។

**ការផ្តល់ឥណទានជារួមទៅកាន់វិស័យនានាបានថមថយកំណើន ទោះជាការរួមបញ្ចូលគ្នាបានធ្វើឱ្យកំណើនឥណទានក្នុងវិស័យមួយចំនួនស្ទុះឡើងវិញ។** កំណើនឥណទានបានថយចុះគួរឱ្យកត់សម្គាល់នៅក្នុងវិស័យមួយចំនួនដូចជា ឥណទានសម្រាប់ការជួញដូរដុំ និងការទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួនក្នុងអត្រាទាប ៣,៦% និង ២,៧% រៀងគ្នា ខណៈដែលកំណើនឥណទានទៅកាន់វិស័យសណ្ឋាគារនិងភោជនីយដ្ឋានថយមកត្រឹម ០,២% (ក្រាហ្វ ២.៨)។ ដោយឡែក កំណើនឥណទានសម្រាប់វិស័យ ការជួញដូររាយ កសិកម្ម និងបុគ្គលមានភាពរឹងមាំ។ ទោះយ៉ាងណា កំណើនទាំងនេះត្រូវបានជំរុញជាចម្បងដោយការរួមបញ្ចូលគ្នា ដូច្នេះមិនគួរត្រូវបានចាត់ទុកថាជាសញ្ញានៃការផ្តល់ឥណទានខ្ពស់នោះទេ។ ជាក់ស្តែង បន្ទាប់ពីកែតម្រូវលើការរួមបញ្ចូលគ្នា កំណើនឥណទានទៅកាន់វិស័យនានាភាគច្រើនមានកម្រិតទាប ដោយសារអត្រាការប្រាក់ខ្ពស់ កម្រិតបំណុលខ្ពស់ និងកំណើនយឺតនៃសកម្មភាពសេដ្ឋកិច្ចក្នុងវិស័យមួយចំនួន។

**២.៨ កំណើនឥណទានធនាគារតាមវិស័យសេដ្ឋកិច្ច**

(ឆ្នាំលើឆ្នាំ, ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**សមាមាត្រនៃឥណទានទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួននិងអចលនទ្រព្យបានកើនឡើងជាលំដាប់។** ទោះជាមានភាពខុសគ្នានៃល្បឿន និងទំហំឥណទានទៅកាន់វិស័យផ្សេងៗ និន្នាការរយៈពេលវែងក្នុងការផ្តល់ឥណទានឆ្លុះបញ្ចាំងពីការប្រែប្រួលនៃសមាមាត្រឥណទានតាមវិស័យ ដោយវិស័យមួយចំនួនទទួលបានសមាមាត្រឥណទានច្រើនជាងមុនក្នុងរយៈប៉ុន្មានឆ្នាំចុងក្រោយ (ក្រាហ្វ ២.៩)។ បើធៀបនឹងឆ្នាំ២០២២ សមាមាត្រនៃឥណទានទៅកាន់ការជួញដូររាយ និងបុគ្គលមានភាពប្រសើរឡើង ខណៈដែលឥណទានទៅកាន់ការជួញដូរដុំនិងការទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួនបានធ្លាក់ចុះ ដោយសារការរួមបញ្ចូលគ្នា។[១៥]

**២.៩ សមាមាត្រឥណទានធនាគារតាមវិស័យសេដ្ឋកិច្ច**
(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)



ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ធនាគារប្រាំធំជាងគេមានទំហំឥណទានជាងពាក់កណ្តាលនៃឥណទានធនាគារសរុប។** សមាមាត្រឥណទានរបស់ធនាគារប្រាំធំជាងគេបានកើនដល់ ៥១,១% នៃឥណទានសរុបទៅកាន់វិស័យឯកជនក្នុងឆ្នាំ២០២៣ ខណៈដែលសមាមាត្រនៃធនាគារបីធំជាងគេមាន ៣៧,៩% (ក្រាហ្វ ២.១០)។ ធនាគារធំលំដាប់ទី៦ ដល់ ទី១៥ មានសមាមាត្រឥណទាន ២១,៧% ខណៈដែលធនាគារ ៩៤ ទៀត មានសមាមាត្រ ២៧,២% នៃឥណទានធនាគារសរុប។[១៦] ក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ សមាមាត្រឥណទានរបស់ធនាគារប្រាំធំជាងគេបានថយចុះបន្តិចពី ៥៣,១% ក្នុងឆ្នាំ២០១៩ មក ៥១,១% ក្នុងឆ្នាំ២០២៣ ដែលបានកាត់បន្ថយការប្រមូលផ្តុំឥណទានក្នុងចំណោមធនាគារធំៗ ទោះជាមានការកើនឡើងនៅក្នុងឆ្នាំ២០២៣ ដោយសារការរួមបញ្ចូលគ្នា។ ជាងនេះទៀត ធនាគារខ្នាតតូចអាចទទួលបានសមាមាត្រឥណទានខ្លះក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ ដោយសារចំនួនធនាគារបានកើនឡើង។ លើសពីនេះ ការផ្លាស់ប្តូរចនាសម្ព័ន្ធក្នុងវិស័យធនាគារ ជាពិសេសការកើនឡើងនៃឌីជីថលូប-

**២.១០ សមាមាត្រឥណទានតាមគ្រឹះស្ថានធនាគារ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)



ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[១៥] គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ភីអិលស៊ី ដែលត្រូវបានរួមបញ្ចូលគ្នាជាមួយធនាគារ គូកមីន ខេមបូឌា ភីអិលស៊ី មិនមានឥណទានដែលត្រូវបានចាត់ថ្នាក់ជាឥណទានទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួនទេ ប៉ុន្តែមានសមាមាត្រដ៏ច្រើនលើឥណទានបុគ្គល។

[១៦] ដោយសារចំនួនធនាគារមានការប្រែប្រួលក្នុងប៉ុន្មានឆ្នាំមកនេះ 'ផ្សេងទៀត' នៅក្នុងក្រាហ្វនឹងមានចំនួនធនាគារខុសៗគ្នាជារៀងរាល់ឆ្នាំ។ នៅឆ្នាំ២០២៣ ដោយសារមានធនាគារចំនួន៥៨ កំពុងដំណើរការ ធនាគារផ្សេងទៀតរួមមាន ៩៤ធនាគារ។

នីយកម្មហិរញ្ញវត្ថុ អាចនឹងបន្ថែមសម្ពាធលើការប្រកួតប្រជែងក្នុងវិស័យធនាគារ។

**កំណើនឥណទានទៅកាន់អង្គភាពគ្រួសារភាគច្រើនបណ្តាលមកពីការរួមបញ្ចូលគ្នា។** ឥណទាន ធនាគារទៅកាន់អង្គភាពគ្រួសារបានកើនឡើង ១៤,៧% ក្នុងឆ្នាំ ២០២៣ ដែលនេះជាកំណើនយឺតបំផុតក្នុងរយៈពេលជាច្រើនឆ្នាំ ហើយស្រដៀងនឹងឆ្នាំ២០២២។ ជារួម កំណើននេះបណ្តាលមកពីការរួមបញ្ចូលគ្នា ដែលមានការផ្ទេរទ្រព្យសកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដ៏ធំបំផុតទៅកាន់ធនាគារ ហើយបានធ្វើឱ្យឥណទានបុគ្គលរបស់ធនាគារកើនឡើង (ក្រាហ្វ ២.១១)។ សរុបមក ឥណទានទៅកាន់អង្គភាពគ្រួសារបានកើនឡើងដល់ ៤៧,៨ ទ្រីលានរៀល ក្នុងឆ្នាំ២០២៣ ដែលធ្វើឱ្យវិស័យអង្គភាពគ្រួសារទទួលបានសមាមាត្រឥណទានធនាគារប្រមាណ ២២,៦% នៃឥណទានធនាគារសរុប។ នៅក្នុងឥណទានទៅកាន់អង្គភាពគ្រួសារ សមាមាត្រឥណទានប្រមាណ ៥៩,១% នៃឥណទាននេះផ្តល់ទៅកាន់អ្នកទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន ខណៈដែលឥណទានបុគ្គល រួមទាំងប័ណ្ណឥណទាន និងផ្សេងៗមានសមាមាត្រ ៤០,៩% នៃឥណទានទៅកាន់អង្គភាពគ្រួសារ។

**ឥណទានទៅកាន់សកម្មភាពអចលនទ្រព្យនិងសំណង់ មានសមាមាត្រជិតមួយភាគប្រាំនៃឥណទានសរុបរបស់ធនាគារ។** ឥណទានធនាគារសម្រាប់សកម្មភាពអចលនទ្រព្យ និងសំណង់បានកើនឡើង ២២,២% និង ១៤,២% នៅឆ្នាំ២០២៣ រៀងគ្នា (ក្រាហ្វ ២.១២)។ ចាប់តាំងពីឆ្នាំ២០១៧ ឥណទានទៅកាន់វិស័យសំណង់មានសមាមាត្រខ្ពស់ជាងឥណទានទៅកាន់វិស័យអចលនទ្រព្យ ប៉ុន្តែកំណើនខ្ពស់នៃឥណទានទៅកាន់វិស័យអចលនទ្រព្យបានបង្កើនសមាមាត្រនៃឥណទាននេះដែលជាលទ្ធផលឥណទានទៅកាន់វិស័យអចលនទ្រព្យ និងសំណង់មានសមាមាត្រប្រហែល ១០% នៃឥណទានធនាគារសរុប។

វិធីសាស្ត្រមួយក្នុងការវាយតម្លៃកម្រិតពាក់ព័ន្ធរបស់ធនាគារទៅនឹងវិស័យអចលនទ្រព្យ គឺដោយដាក់

**២.១១ ឥណទានធនាគារទៅកាន់អង្គភាពគ្រួសារ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**២.១២ ឥណទានទៅវិស័យសំណង់និងអចលនទ្រព្យ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

បញ្ចូលគ្នានូវឥណទានទៅកាន់ i/- វិស័យអចលនទ្រព្យ ii/- វិស័យសំណង់ និង iii/- ឥណទានទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួនរបស់អង្គភាពគ្រួសារ។ តាមរយៈការបូកឥណទានទៅកាន់វិស័យទាំងបីនេះបញ្ចូលគ្នា កម្រិតពាក់ព័ន្ធរបស់ធនាគារទៅនឹងវិស័យអចលនទ្រព្យមានសមាមាត្រប្រមាណ ១/៣ នៃសំពៀតឥណទានសរុប (ក្រាហ្វ ២.១៣)។ ទោះយ៉ាងណាហានិភ័យនៃវិស័យទាំងបីនេះមានលក្ខណៈខុសៗគ្នា។ ជាឧទាហរណ៍ សំពៀតឥណទានទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួនមានឥណទានតូចៗ ដែលផ្តល់ទៅកាន់អង្គភាពគ្រួសារច្រើន ហើយដូច្នេះមានលក្ខណៈពិពិធកម្ម។ កត្តានេះបានធ្វើឱ្យអនុបាតឥណទានមិនដំណើរការមានកម្រិតទាបបំផុត សម្រាប់ឥណទានទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន ធៀបនឹងឥណទានទៅកាន់វិស័យនានា។ ជាងនេះទៅទៀត ទោះជាឥណទានធនាគារទៅកាន់វិស័យពាក់ព័ន្ធនឹងអចលនទ្រព្យមានទំហំធំ ហានិភ័យឥណទាននៅតែអាចគ្រប់គ្រងបាន ដែលចំណុចនេះនឹងត្រូវលើកឡើងនៅក្នុងផ្នែកបន្ទាប់ស្តីពីគុណភាពទ្រព្យសកម្ម។

ដោយសារការងើបឡើងវិញយឺតនៃវិស័យសំណង់ និងអចលនទ្រព្យ នៅក្រោយវិបត្តិកូវីដ-១៩ ការផ្គត់ផ្គង់លើសតម្រូវការក្នុងទីផ្សារ និងការថយចុះនៃតម្រូវការ ថ្លៃលំនៅឋានបានស្ថិតនៅក្រោមសម្ពាធ បណ្តាលឱ្យមានការកើនឡើងនៃហានិភ័យឥណទាន ដែលអាចប៉ះពាល់ដល់ធនាគារមួយចំនួន ជាពិសេសគ្រឹះស្ថានដែលផ្តល់ឥណទានច្រើនទៅកាន់វិស័យនេះ។ ជាទូទៅ ទីផ្សារអចលទ្រព្យទទួលបានឥណទានមួយផ្នែកពីធនាគារ ខណៈដែលការវិនិយោគពីក្រៅប្រទេសលើវិស័យនេះមានសមាមាត្រធំ។ ទោះជាទីផ្សារអចលនទ្រព្យពាណិជ្ជកម្មហាក់កំពុងថមថយ សមាមាត្រឥណទានធនាគារទៅកាន់វិស័យនេះមានប្រមាណ ១៦,៨% នៃឥណទានទៅកាន់សកម្មភាពអចលនទ្រព្យ។

**ការងើបឡើងយឺតក្រោយវិបត្តិកូវីដ-១៩ និងការបញ្ចប់វិធានការអនុគ្រោះបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា បានធ្វើឱ្យគុណភាពទ្រព្យសកម្មថមថយ។**

**២.១៤ ឥណទានមិនដំណើរការរបស់ធនាគារពាណិជ្ជ**

(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

អនុបាតឥណទានមិនដំណើរការរបស់ធនាគារពាណិជ្ជដែលជាសូចនាករសំខាន់បង្ហាញអំពីគុណភាពទ្រព្យសកម្មបានកើនឡើងពី ២,៩% ក្នុងឆ្នាំ២០២២ ដល់ ៥,១% ក្នុងឆ្នាំ២០២៣ (ក្រាហ្វ ២.១៩)។ អនុបាតឥណទានមិនដំណើរការបានកើនឡើង ស្របពេលដែលទំហំឥណទានមិនដំណើរការបានកើនឡើងទ្វេដងក្នុងឆ្នាំ២០២៣ ហើយកំណើនឥណទានបានថមថយ។ អនុបាត ៥,១% ជាកម្រិតខ្ពស់ជាងគេក្នុងមួយទសវត្សរ៍ចុងក្រោយ ហើយស្មើរតែបីដងនៃកម្រិតមុនវិបត្តិកូវីដ-១៩។ អនុបាតឥណទានមិនដំណើរការសុទ្ធ (ដកសំវិធានធនជាក់លាក់) បានកើនឡើងពី ១,៣% ទៅ ២,៥% ក្នុងឆ្នាំ២០២៣ ដែលទាបជាងអនុបាតឥណទានមិនដំណើរការដុល។ ដោយសារវិធីសាស្រ្តគណនាផ្សេងគ្នា និងនិយមន័យតាមបទប្បញ្ញត្តិដែលបានអនុវត្តនៅប្រទេសផ្សេងៗគ្នា ការប្រៀបធៀបអនុបាតនេះជាមួយប្រទេសផ្សេងទៀតត្រូវមានការពិចារណាលើកត្តានិយមន័យនិងការគណនាផងដែរ។

អនុបាតឥណទានមិនដំណើរការបានកើនឡើងដូចការរំពឹងទុក។ អនុបាតនេះមានកម្រិតទាបក្នុងអំឡុងវិបត្តិកូវីដ-១៩ នៅពេលដែលវិធានការអនុគ្រោះបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជាបានអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរៀបចំឥណទានឡើងវិញក្នុងអំឡុងឆ្នាំ២០២០-២០២១ ដោយមិនផ្លាស់ប្តូរចំណាត់ថ្នាក់ឥណទាន ដែលនាំឱ្យមានការពន្យារពេលការកើនឡើងនៃឥណទានមិនដំណើរការ។[១៧] ទោះយ៉ាងណា នៅពេលដែលវិធានការអនុគ្រោះបទប្បញ្ញត្តិត្រូវបានបញ្ចប់ឥណទានមិនដំណើរការនឹងត្រូវកើនឡើង។ លើសពីនេះ អត្រាការប្រាក់ខ្ពស់ កម្រិតបំណុលខ្ពស់ និងការងើបឡើងវិញយឺតនៃការរំពឹងទុកក្នុងវិស័យមួយចំនួនបានរួមចំណែកដល់ការកើនឡើងនៃឥណទានមិនដំណើរការ។

ឥណទានមិនដំណើរការនៅក្នុងវិស័យនានាបានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងឆ្នាំ២០២៣។ ឥណទានមិនដំណើរការសម្រាប់ការជួញដូររាយមានទំហំ

[១៧] ឧទាហរណ៍ គ្រឹះស្ថានធនាគារបានរៀបចំឥណទានឡើងវិញ ជាមធ្យម ប្រមាណ ១០,៤% នៃឥណទានសរុប ចាប់ពីខែមេសា ឆ្នាំ២០២០ ដល់ ខែធ្នូ ឆ្នាំ២០២១។ នៅចុងខែធ្នូ ឆ្នាំ២០២២ ឥណទានរៀបចំឡើងវិញមានសមាមាត្រ ៥,៧% នៃឥណទានសរុប។

ខ្ពស់ជាងគេ (២,២ ទ្រីលានរៀល) បន្ទាប់មកគឺវិស័យសំណង់ (១,២ ទ្រីលានរៀល) និងវិស័យកសិកម្ម (១,១ ទ្រីលានរៀល) (ក្រាហ្វ ២.១៥)។ ទំហំឥណទានមិនដំណើរការនៅក្នុងវិស័យនានាផ្សេងទៀតបានកើនឡើងទ្វេដងក្នុងឆ្នាំ២០២៣ រួមទាំងនៅក្នុងវិស័យជួញដូរដុំនិងរាយ ការទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន បុគ្គល សំណង់ និងកសិកម្ម។ លើកលែងតែឥណទានមិនដំណើរការនៃអាជីវកម្មធនធានរ៉ែបានថយចុះ ២៨%។

**អនុបាតឥណទានមិនដំណើរការតាមវិស័យមានការកើនឡើងនៅក្នុងវិស័យសំខាន់ៗ។** គុណភាពឥណទានទៅកាន់វិស័យសណ្ឋាគារនិងភោជនីយដ្ឋានបានធ្លាក់ចុះបន្ថែមទៀតនៅឆ្នាំ២០២៣ ដោយអនុបាតឥណទានមិនដំណើរការមានកម្រិត ១២% នៅឆ្នាំ២០២៣ ដែលជាកម្រិតខ្ពស់ជាងគេក្នុងចំណោមវិស័យផ្សេងទៀត។ ការកើនឡើងនេះបណ្តាលមកពីការងើបឡើងវិញយឺតក្នុងវិស័យទេសចរណ៍ ដែលទទួលរងផលប៉ះពាល់ពីវិបត្តិកូវីដ-១៩ និងការធ្លាក់ចុះនៃសេដ្ឋកិច្ចចិន ដែលជាប្រភពសំខាន់នៃភ្ញៀវទេសចរអន្តរជាតិមុនវិបត្តិកូវីដ-១៩[18] (ក្រាហ្វ ២.១៦)។ កម្រិតអនុបាតឥណទានមិនដំណើរការនៃវិស័យជួញដូរដុំនិងរាយ និងការដឹកជញ្ជូន បានកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ។ សម្រាប់អង្គភាពគ្រួសារអនុបាតឥណទានមិនដំណើរការនៃឥណទានបុគ្គលមានកម្រិតខ្ពស់ជាងឥណទានទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន។ យ៉ាងណាមិញ អនុបាតឥណទានមិនដំណើរការនៃអាជីវកម្មរ៉ែ និងវិស័យទូរគមនាគមន៍បានថយចុះ។ ជារួម អនុបាតឥណទានមិនដំណើរការដុលបានកើនដល់ ៥,១% ដោយសារតែការកើនឡើងនៃអនុបាតតាមវិស័យភាគច្រើន ប៉ុន្តែស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន។

**២.១៥ ឥណទានមិនដំណើរការតាមវិស័យ**



ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**២.១៦ អនុបាតឥណទានមិនដំណើរការតាមវិស័យ**

(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)



ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[18] ខណ:ដែលចំនួនភ្ញៀវទេសចរបានកើនឡើងគួរឱ្យកត់សម្គាល់នៅឆ្នាំ២០២៣ ចំណូលពីវិស័យទេសចរណ៍បានងើបឡើងក្នុងល្បឿនមធ្យម ដោយភ្ញៀវទេសចរបានប្រែប្រួលជាមួយនឹងការធ្វើដំណើរឆ្លងព្រំដែនតាមផ្លូវគោកមានសមាមាត្រធំជាង។

**សំវិធានធនជាក់លាក់បានកើនឡើងស្ទើរតែទ្វេដង ស្របតាមការកើនឡើងនៃអនុបាតឥណទានមិនដំណើរការ។** ក្នុងឆ្នាំ២០២៣ សំវិធានធនជាក់លាក់បានកើនដល់ ៥,៩ ទ្រីលានរៀល ដោយក្នុងនោះសំវិធាន-ធនបន្ថែមមានចំនួន ២,៨ ទ្រីលានរៀល ដែលជាការកើនឡើងខ្ពស់បំផុតក្នុងរយៈពេលប្រាំពីរឆ្នាំចុងក្រោយនេះ (ក្រាហ្វ ២.១៧)។ ទោះជាមានការកើនឡើងយ៉ាងច្រើននៅក្នុងបទប្បញ្ញត្តិជាក់លាក់ក៏ដោយ អនុបាតសំវិធានធនជាក់លាក់ធៀបនឹងឥណទានមិនដំណើរការបានធ្លាក់ចុះពី ៥៦% នៅឆ្នាំ២០២២ មក ៥២,៣% នៅឆ្នាំ២០២៣ ដោយសារការកើនឡើងនៃឥណទានមិនដំណើរការ។

**២.១៧ ឥណទានមិនដំណើរការ និងសំវិធានធន**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ខ. មូលនិធិ និងសន្ទនីយភាព

**ស្ថានភាពសន្ទនីយភាពដែលឆ្លុះបញ្ចាំងតាមរយៈអនុបាតគ្របខ័ណ្ឌសន្ទនីយភាព (LCR) របស់គ្រឹះស្ថានធនាគារបន្តមានភាពរឹងមាំ។** អនុបាត LCR វាស់វែងភាពគ្រប់គ្រាន់ទ្រព្យសកម្ម ដែលមានគុណភាពខ្ពស់ និងងាយបំប្លែងជាសាច់ប្រាក់របស់គ្រឹះស្ថានធនាគារក្នុងស្ថានភាពតានតឹងផ្នែកសន្ទនីយភាពរយៈពេល ៣០ ថ្ងៃ ហើយត្រូវបានដាក់ចេញក្នុងខែកញ្ញា ឆ្នាំ២០១៦ ជាមួយកម្រិតកំណត់ដោយបទប្បញ្ញត្តិ ៦០%។ អនុបាត LCR ត្រូវបានអនុវត្តជាដំណាក់កាលដោយឈានដល់ ១០០% ក្នុងឆ្នាំ២០២០ និងត្រូវបានរក្សានៅអត្រានេះមកទល់សព្វថ្ងៃ ស្របតាមគោលការណ៍បាសែលបី។ ក្រោយពី បានថយចុះបន្តិចក្នុងរយៈពេលពីរឆ្នាំមុន អនុបាត LCR របស់គ្រឹះស្ថានធនាគារពាណិជ្ជ បានកើនមកវិញដល់ ១៦៦,៦% ក្នុងឆ្នាំ២០២៣ (ក្រាហ្វ ២.១៨) ខ្ពស់ជាងកម្រិតកំណត់ដោយបទប្បញ្ញត្តិ (១០០%) ដែលឆ្លុះបញ្ចាំងពីភាពគ្រប់គ្រាន់នៃសន្ទនីយភាពទប់ទល់នឹងភាពតានតឹងផ្នែកសន្ទនីយភាពរយៈពេលខ្លី។

**២.១៨ អនុបាតគ្របខ័ណ្ឌសន្ទនីយភាព របស់គ្រឹះស្ថានធនាគារពាណិជ្ជ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

លើសពីអនុបាត LCR សូចនាករសន្ទនីយភាពមួយចំនួនរបស់គ្រឹះស្ថានធនាគារមាននិន្នាការចម្រុះ។ ឧទាហរណ៍ អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើបានថយចុះមក ១១២,២% នៅឆ្នាំ២០២៣ ដោយសារកំណើនប្រាក់បញ្ញើ (២១,៣%) លឿនជាងកំណើនឥណទាន (១៤,៩%)។ ជាមួយគ្នានេះ អនុបាតទ្រព្យសកម្មងាយបំប្លែងជាសាច់ប្រាក់ធៀបនឹងទ្រព្យអកម្មរយៈពេលខ្លី ដែលឆ្លុះបញ្ចាំងពីលទ្ធភាពក្នុងការសងបំណុលរយៈពេលខ្លី ដោយប្រើប្រាស់ទ្រព្យសកម្មងាយបំប្លែងជាសាច់ប្រាក់ មានភាពប្រសើរឡើងពី ២២,៣% ដល់ ២៥% នៅឆ្នាំ២០២៣ (ក្រាហ្វ ២.១៩)។ យ៉ាងណាមិញ អនុបាតទ្រព្យសកម្មដែលងាយបំប្លែងជាសាច់ប្រាក់ធៀបនឹងទ្រព្យសកម្មសរុប និងអនុបាតទ្រព្យសកម្មដែលងាយបំប្លែងជាសាច់ប្រាក់ធៀបនឹងប្រាក់បញ្ញើ បានថយចុះធៀបនឹងឆ្នាំ២០២២។

២.១៩ **អនុបាតសន្ទនីយភាពសម្រាប់គ្រឹះស្ថានធនាគារពាណិជ្ជ**

(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**សមាមាត្រនៃប្រាក់បញ្ញើអតិថិជន ដែលជាប្រភពទុនដ៏សំខាន់បានកើនឡើង។** ក្នុងចំណោមប្រភពមូលនិធិរបស់ធនាគារ ប្រាក់បញ្ញើអតិថិជនមានសមាមាត្រប្រហែល ៦៦,៤% ខណៈដែលមូលនិធិកម្ចី ទាំងរយៈពេលខ្លី និងរយៈពេលវែង មានសមាមាត្រ ១៣% និងដើមទុន ២០,៦% រៀងគ្នា (ក្រាហ្វ ២.២០)។ សមាមាត្រនៃប្រាក់បញ្ញើបានកើនឡើង ខណៈដែលមូលនិធិកម្ចី (និងដើមទុន) បានធ្លាក់ចុះបន្តិចបើធៀបនឹងឆ្នាំ២០២២ ជាចម្បងដោយសារ អត្រាការប្រាក់ខ្ពស់បន្តិចដែលបានធ្វើឱ្យមានភាពលំបាកក្នុងការខ្ចីប្រាក់ពីបរទេស និងបានលើកទឹកចិត្តធនាគារឱ្យបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការប្រមូលប្រាក់បញ្ញើ។ ធៀបនឹងប្រាក់បញ្ញើសរុប ប្រាក់បញ្ញើមានកាលកំណត់មានសមាមាត្រ ៥៦,៨% បន្ទាប់មកគណនីសន្សំ ២៤,៥% ប្រាក់បញ្ញើតាមតម្រូវការ ១៦,៩% និងផ្សេងទៀត ១,៨% ហើយជាពិសេស សមាមាត្រនៃប្រាក់បញ្ញើមានកាលកំណត់មានការកើនឡើង ស្របពេលដែលអត្រាការប្រាក់មានកម្រិតខ្ពស់។ ប្រាក់បញ្ញើរបស់អតិថិជនសរុបបានកើនដល់ ១៨៨,១ ទ្រីលានរៀលក្នុង

២.២០ **ប្រភពមូលនិធិរបស់គ្រឹះស្ថានធនាគារ**

(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ឆ្នាំ២០២៣ ដោយបានកើន ២១,៣% ធៀបនឹង ៨,៥% ក្នុងឆ្នាំ២០២២។

**សមាមាត្រប្រាក់បញ្ញើជាប្រាក់រៀលបានកើនឡើងបន្តិច ប៉ុន្តែប្រាក់បញ្ញើភាគច្រើនបន្តជាប្រាក់ដុល្លារអាមេរិកដូចទៅនឹងឥណទាន។** ប្រាក់បញ្ញើជាដុល្លារអាមេរិកនៅតែជាជម្រើសចម្បងសម្រាប់អតិថិជន ដោយមានសមាមាត្រ ៨៨,៦% នៃប្រាក់បញ្ញើសរុបក្នុងឆ្នាំ២០២៣។ ទោះជាដុល្លារូបនីយកម្មមានកម្រិតខ្ពស់ សមាមាត្រនៃប្រាក់បញ្ញើជាប្រាក់រៀលកើនបន្តិចពី ១១,២% ក្នុងឆ្នាំ២០២២ ដល់ ១១,៤% ក្នុងឆ្នាំ២០២៣ (ក្រាហ្វ ២.២១)។ គោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជាក្នុងការតម្រូវឱ្យធនាគារផ្តល់ឥណទានយ៉ាងហោចណាស់ ១០% នៃសំពៀតឥណទានសរុប បានលើកទឹកចិត្តឱ្យធនាគារបង្កើនប្រាក់បញ្ញើជាប្រាក់រៀលបន្ថែមទៀត ដោយឥណទានជាប្រាក់រៀលមានចំនួន ២៤,៦ ទ្រីលានរៀល និងប្រាក់បញ្ញើជារៀលមានចំនួន ២១,៤ ទ្រីលានរៀល ក្នុងឆ្នាំ២០២៣ ដូច្នេះ គម្លាតរវាងឥណទាន និងប្រាក់បញ្ញើជារៀលបានរួមតូចជាងមុនបើធៀបនឹងឆ្នាំមុន។

ឥណប្រតិទាននៃឥណទាន និងប្រាក់បញ្ញើរបស់គ្រឹះស្ថានធនាគារនៅឆ្នាំ២០២៣ បង្ហាញថា ជាទូទៅប្រាក់បញ្ញើមានកម្រិតខ្ពស់ជាងឥណទានក្នុងឥណប្រតិទានរយៈពេលខ្លី ខណៈដែលឥណទានលើសពីប្រាក់បញ្ញើក្នុងឥណប្រតិទានលើសពីមួយឆ្នាំ (ក្រាហ្វ ២.២២)។ ជាក់ស្តែង កម្រិតជាក់លាក់នៃភាពមិនស៊ីគ្នានៃឥណប្រតិទានគឺជារឿងធម្មតា ដោយធនាគារបានបំប្លែងទ្រព្យអកម្មរយៈពេលខ្លីទៅជាទ្រព្យសកម្មរយៈពេលវែង។ ទោះយ៉ាងណាប្រសិនបើទំហំនៃភាពមិនស៊ីគ្នាកាន់តែខ្ពស់ ធនាគារអាចប្រឈមនឹងហានិភ័យសន្ទនីយភាព ជាពិសេសប្រសិនបើពួកគេពឹងផ្អែកច្រើនលើមូលនិធិដែលមានរយៈពេលខ្លីមិនសូវមានស្ថិរភាព និងមិនមែនជាប្រភពទុនស្នូល។

**២.២១ ប្រាក់បញ្ញើអតិថិជន**

(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**២.២២ ឥណទាន និងប្រាក់បញ្ញើតាមឥណប្រតិទាន**

(ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## គ. លទ្ធភាពស្វែងរកប្រាក់ចំណេញ និងភាពគ្រប់គ្រាន់នៃដើមទុន

**ប្រាក់ចំណេញសុទ្ធបន្តមានភាពវិជ្ជមាន ប៉ុន្តែមានការធ្លាក់ចុះដោយសារការកើនឡើងនៃសំវិធានធន និងចំណាយលើការប្រាក់។** លទ្ធភាពស្វែងរកប្រាក់ចំណេញរបស់ធនាគារពាណិជ្ជបានធ្លាក់ចុះនៅឆ្នាំ២០២៣ ដោយប្រាក់ចំណេញសុទ្ធធ្លាក់ចុះ ៥៥,៤% មកត្រឹម ២ ទ្រីលានរៀល (ក្រាហ្វ ២.២៣)។ ការកើនឡើងចំណាយលើការប្រាក់ និងសំវិធានធនបានប៉ះពាល់ដល់ប្រាក់ចំណេញរបស់ធនាគារ។ ចំណាយលើការប្រាក់បានកើនឡើង ៧០% នៅឆ្នាំ២០២៣ ក្នុងបរិការណ៍ដែលអត្រាការប្រាក់ខ្ពស់បានជះឥទ្ធិពលដល់អត្រាការប្រាក់បញ្ញើ[១៩] និងដល់ការប្រកួតប្រជែងក្នុងការស្វែងរកប្រាក់បញ្ញើ។ ចំណាយលើសំវិធានធនបានកើនឡើង ៦៨% ទន្ទឹមនឹងការកើនឡើងឥណទានមិនដំណើរការ និងការបញ្ចប់វិធានការអនុគ្រោះបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា ដែលតម្រូវឱ្យគ្រឹះស្ថានធ្វើចំណាត់ថ្នាក់ឥណទានឱ្យបានត្រឹមត្រូវ និងធ្វើសំវិធានធនជាក់លាក់ឱ្យបានគ្រប់គ្រាន់។ ចំពោះផ្នែកប្រាក់ចំណូល ចំណូលលើការប្រាក់បន្តមានកំណើនខ្ពស់ ២៨,៩% ក្នុងឆ្នាំ២០២៣ ខណៈដែលកំណើនប្រាក់ចំណូលមិនមែនការប្រាក់បានថយចុះមកត្រឹម ៧% ធៀបនឹង ១២,៥% ក្នុងឆ្នាំ២០២២។

**២.២៣ លទ្ធភាពស្វែងរកប្រាក់ចំណេញរបស់គ្រឹះស្ថានធនាគារពាណិជ្ជ**

(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ការថយចុះនៃប្រាក់ចំណេញសុទ្ធរបស់ធនាគារពាណិជ្ជបានធ្វើឱ្យអនុបាតប្រាក់ចំណេញសុទ្ធធៀបនឹងទ្រព្យសកម្ម (ROA) និងធៀបនឹងមូលនិធិភាគទុនិក (ROE) ថយចុះក្នុងឆ្នាំ២០២៣ (ក្រាហ្វ ២.២៤)។ ROE បានថយចុះពី ៧,១% ក្នុងឆ្នាំ២០២២ ដល់ ៣,៤% នៅឆ្នាំ២០២៣។ ដូចគ្នានេះដែរ ROA បានធ្លាក់ចុះ ០,៧២ ពិន្ទុភាគរយ នាំឱ្យ ROA មានកម្រិត ០,៦៤% ក្នុងឆ្នាំ២០២៣។ ការថយចុះនេះរួមចំណែក ដោយសារកំណើនខ្ពស់របស់ទ្រព្យសកម្ម (១៦,៤%) និងមូលនិធិភាគទុនិក

**២.២៤ ប្រាក់ចំណេញធៀបទ្រព្យសកម្ម និងមូលនិធិភាគទុនិករបស់គ្រឹះស្ថានធនាគារ**

(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

---

[១៩] ដោយគ្រឹះស្ថានធនាគារភាគច្រើនផ្តល់ឥណទានដែលមានអត្រាការប្រាក់ថេរ ឥទ្ធិពលនៃការកើនឡើងអត្រាការប្រាក់ទីផ្សារមកលើឥណទានមានភាពយឺត។ ដោយឡែក អត្រាការប្រាក់បញ្ញើ ជារឿយៗតែងប្រែប្រួលទៅតាមអត្រាការប្រាក់ទីផ្សារ។

(១២,៨%) ខណៈដែលប្រាក់ចំណេញសុទ្ធបានថយចុះ (-៤៥,៤%)។

ប្រសិទ្ធភាពប្រតិបត្តិការបានធ្លាក់ចុះ ស្របពេលដែលចំណាយប្រតិបត្តិការមានការកើនឡើង។ ប្រសិទ្ធភាពប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារពាណិជ្ជ ដែលត្រូវបានវាស់ដោយចំណាយប្រតិបត្តិការធៀបនឹងចំណូលប្រតិបត្តិការដុលសរុប មានភាពអន់ថយជាងមុន[២០]នៅឆ្នាំ២០២៣ ដោយបានកើនដល់ ៥២% (ក្រាហ្វ ២.២៥)។ ភាពអន់ថយនេះ គឺដោយសារតែការកើនចំណាយប្រតិបត្តិការ ១៤,៩% ខណៈដែលប្រាក់ចំណូលប្រតិបត្តិការសរុបកើន ៣,៥%។ ទោះជាភាគបែងមានទំហំធំ (ចំណូលប្រតិបត្តិការ) ការកើនឡើងខ្លាំងនៃចំណាយប្រតិបត្តិការបាននាំឱ្យមានការកើនឡើងបន្តិចនៃអនុបាតប្រសិទ្ធភាពប្រតិបត្តិការ។ ម្យ៉ាងទៀត ការកើនឡើងនៃចំណាយអាចបណ្ដាលមកពីការពង្រីកសាខារបស់ធនាគារ និងអភិវឌ្ឍហិរញ្ញវត្ថុឌីជីថល ដែលទាមទារការវិនិយោគកាន់តែច្រើនជាមុន។

**២.២៥ អនុបាតប្រសិទ្ធភាពចំណាយរបស់គ្រឹះស្ថានធនាគារ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ភាពគ្រប់គ្រាន់នៃដើមទុនរបស់ធនាគារនៅបន្តស្ថិតក្នុងកម្រិតខ្ពស់លើសពីកម្រិតកំណត់ដោយបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។** ធនាគារពាណិជ្ជបន្តរក្សាកម្រិតដើមទុនខ្ពស់ ជាមួយនឹងអនុបាតភាពគ្រប់គ្រាន់នៃដើមទុន (CAR) ២២,៥% ក្នុងឆ្នាំ២០២៣ ខ្ពស់ជាង ២២,២% នៅឆ្នាំ២០២២ (ក្រាហ្វ ២.២៦)។ ការកើនឡើងតិចតួចនៃអនុបាតនេះ ជាចម្បងដោយសារកំណើនយឺតនៃទ្រព្យសកម្មថ្លឹងតាមហានិភ័យ (១៤,៤%) ក្នុងឆ្នាំ២០២៣ បើធៀបនឹងដើមទុន (១៦,១%) ដែលឆ្លុះបញ្ចាំងពីការផ្ដល់ឥណទានរបស់ធនាគារប្រកបដោយភាពប្រុងប្រយ័ត្ន និងការពង្រឹងស្ថានភាពដើមទុន។ ជារួម CAR ដែលជាសូចនាករនៃលទ្ធភាពស្រូបយកការខាតបង់ មានកម្រិតលើសពីបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា ១៥%។ ជាក់ស្ដែង អនុបាតដើមទុនថ្នាក់ទីមួយ មានកម្រិត ១៩,៨% គឺលើសពីកម្រិតអប្បបរមានៃបទប្បញ្ញត្តិដែលត្រូវមាន។ ក្នុងឆ្នាំ២០២៣ ធនាគារ

**២.២៦ ភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[២០] ការកើនឡើងនៃអនុបាតប្រសិទ្ធភាពចំណាយបង្ហាញពីការអន់ថយនៃប្រសិទ្ធភាពប្រតិបត្តិការ ដោយធនាគារបង្កើនចំណាយប្រតិបត្តិការ ដើម្បីរកប្រាក់ចំណូល។

ត្រូវបានកំណត់ឱ្យរក្សាទ្រនាប់ដើមទុនខនស៊ើវេសិន (CCB) ១,២៥%នៃទ្រព្យសកម្មថ្លឹងតាមហានិភ័យ ដោយការដំឡើង CCB ដល់ ២,៥% នៅខែធ្នូ ឆ្នាំ២០២៣ ត្រូវបានពន្យារពេលមួយឆ្នាំ។

ការបែងចែកប្រភេទដើមទុនបានបង្ហាញថា ដើមទុនថ្នាក់ទីមួយ និងដើមទុនថ្នាក់ទីពីរ មានកំណើនវិជ្ជមាន (១៧% និង ១០,២% រៀងគ្នា) ហើយដើមទុនថ្នាក់ទីមួយមានកំណើនខ្ពស់ជាង។ ជាលទ្ធផល សមាមាត្រនៃដើមទុនថ្នាក់ទីមួយ មានភាពប្រសើរឡើងបន្ថែមទៀតដល់ ៨៨% នៅក្នុងមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។ កម្រិតនៃភាពគ្រប់គ្រាន់នៃដើមទុន ដែលត្រូវបានគាំទ្រជាចម្បងដោយដើមទុនថ្នាក់ទីមួយ បានបន្តភាពធន់ក្នុងប្រព័ន្ធធនាគារក្នុងការទប់ទល់នឹងស្ថានភាពស្រ្តេសខ្លាំង ដែលបង្ហាញអំពីភាពរឹងមាំរបស់ធនាគារក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះបើទោះជាបានឆ្លងកាត់វិបត្តិកូវីដ-១៩។

អនុបាតដើមទុនធៀបនឹងឥណទានសុទ្ធបានកើនឡើងដល់ ២៨,៨% នៅឆ្នាំ២០២៣ ដែលឆ្លុះបញ្ចាំងពីកម្រិតទ្រនាប់ដើមទុនដែលគ្រឹះស្ថានធនាគារអាចប្រើ-ប្រាស់បាន ក្នុងករណីដែលឥណទានមួយចំនួនប្រែក្លាយជាឥណទានមិនដំណើរការ។ ម្យ៉ាងវិញទៀត អនុបាតឥណទានមិនដំណើរការសុទ្ធ ធៀបនឹងដើមទុន ដែលជាសូចនាករបង្ហាញពីកម្រិតដើមទុនរបស់ ធនាគារដែលត្រូវខាតបង់ដោយសារឥណទានមិនដំណើរការ បានកើនឡើងទ្វេដង ក្នុងឆ្នាំ២០២៣ ដោយសារកំណើនខ្ពស់នៃឥណទានមិនដំណើរការ (ក្រាហ្វ ២.២៧)។ ទោះជាឥណទានមិនដំណើរការបានកើនឡើងបន្ទាប់ពីវិបត្តិកូវីដ-១៩ អនុបាតភាពគ្រប់គ្រាន់នៃដើមទុនជារួមរបស់គ្រឹះស្ថានធនាគារបន្តមានភាពរឹងមាំ និងខ្ពស់ជាងកម្រិតបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។

**លទ្ធផលនៃការធ្វើស្រ្តេសតេស្តលើដើមទុនបានបង្ហាញថា ធនាគារជាទូទៅមានភាពធន់ បើទោះជា មានភាពខុសគ្នាខ្លះតាមគ្រឹះស្ថាននីមួយៗ។** ការធ្វើស្រ្តេសតេស្តរបស់ធនាគារជាតិនៃកម្ពុជាមានគោលបំណងសាកល្បងលើភាពធន់របស់ធនាគារ នៅក្រោមការ

**២.២៧ ភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារ**

(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

កំណត់សេណារីយ៉ូស្រ្តេសខ្លាំង ដើម្បីបញ្ជាក់ពីភាពគ្រប់គ្រាន់នៃដើមទុនរបស់ធនាគារ។ ជាឧទាហរណ៍ នៅក្រោមសេណារីយ៉ូស្រ្តេសមួយដែលអនុបាតឥណទានមិនដំណើរការ សម្រាប់ធនាគារនីមួយៗត្រូវបានដំឡើង ៥ ពិន្ទុភាគរយ[២១] ធនាគារភាគច្រើននៅតែអាចរក្សាអនុបាតភាពគ្រប់គ្រាន់នៃដើមទុនលើសពី ១៥% (លើកលែងតែធនាគារមួយចំនួនតូចដែលអាចមានអនុបាតភាពគ្រប់គ្រាន់នៃដើមទុនលើសពី ១៩%) ដែលបញ្ជាក់ថាធនាគារជាទូទៅ មានដើមទុនរឹងមាំក្នុងការទប់ទល់នឹងការថយចុះនៃគុណភាពទ្រព្យសកម្ម។

## ២.៣ វិស័យមីក្រូហិរញ្ញវត្ថុ[២២]

ខណៈដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ (MFI) បន្តលូតលាស់ ទ្រព្យសកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (MDI) បានថយចុះស្ទើរតែពាក់កណ្តាលក្នុងឆ្នាំ២០២៣ ក្រោយពីការរួមបញ្ចូលគ្នារវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមួយជាមួយនឹងធនាគារពាណិជ្ជ។ គិតត្រឹមចុងឆ្នាំ២០២៣ វិស័យមីក្រូហិរញ្ញវត្ថុរួមមាន MDI ចំនួន ៤ និង MFI ចំនួន ៨៣ ដែលមានសាខាសរុបចំនួន ៩១២ កំពុងដំណើរការនៅទូទាំងប្រទេស។ ទ្រព្យសកម្មសរុបក្នុងវិស័យមីក្រូហិរញ្ញវត្ថុបានថយចុះ ៩១,១% មកត្រឹម ២៦,១ ទ្រីលានរៀល (៦,៤ ប៊ីលានដុល្លារអាមេរិក) ជាចម្បងដោយសារគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ដែលជា MDI ធំជាងគេ ដែលមានសមាមាត្រទ្រព្យសកម្មក្នុងវិស័យស្មើនឹង ៤៥% បានរួមបញ្ចូលគ្នាក្លាយជាធនាគារពាណិជ្ជ។ ជាលទ្ធផល ទ្រព្យសកម្មរបស់ MDI បានថយចុះខ្លាំង -៥០,៨% មកត្រឹម ១៨,៦ ទ្រីលានរៀល (៤,៦ ប៊ីលានដុល្លារអាមេរិក)។ ដោយឡែក ទ្រព្យសកម្មរបស់ MFI បន្តមានកំណើនពីរខ្ទង់ក្នុងអត្រា ១៤,៧% ដល់ ៧,៥ ទ្រីលានរៀល (១,៨ ប៊ីលានដុល្លារអាមេរិក) ប៉ុន្តែអត្រាកំណើននេះបានថមថយធៀបនឹងឆ្នាំ២០២២ (២៧,៨%)

**២.២៨ ទ្រព្យសកម្មនៃវិស័យមីក្រូហិរញ្ញវត្ថុ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[២១] គិតត្រឹមខែធ្នូ ឆ្នាំ២០២៣ អនុបាត NPLR មានកម្រិត ៥,១%។

[២២] វិស័យមីក្រូហិរញ្ញវត្ថុរួមមាន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ។

ក្នុងពេលដែលឥណទានមិនដំណើរការបានកើនឡើង និងអត្រាការប្រាក់មានកម្រិតខ្ពស់ (ក្រាហ្វ ២.២៨)។

### ក. សមិទ្ធកម្មនៃឥណទាន

**វិស័យមីក្រូហិរញ្ញវត្ថុផ្តល់ឥណទានជាចម្បងដល់អាជីវកម្មខ្នាតតូចនិងគ្រួសារ និងអង្គភាពគ្រួសារ ជាពិសេសនៅតាមទីជនបទ។** សម្រាប់ MDI ឥណទានទៅកាន់វិស័យកសិកម្មមានសមាមាត្រ ២៩% នៃឥណទានសរុប បន្ទាប់មកគឺ អង្គភាពគ្រួសារ ២៨,៣% ពាណិជ្ជកម្មនិងការជួញដូរ ២៣,១% សេវាកម្ម ៩,៧% សំណង់ ៥,៤% និងក្រៅពីនេះគឺឥណទានផ្សេងៗទៀត។ គួររំលេចថា សមាមាត្រឥណទានទៅកាន់វិស័យកសិកម្មបានកើនឡើងគួរឱ្យកត់សម្គាល់ពី ១៩,៦% នៅឆ្នាំ២០២២ ដល់ ២៩% នៅឆ្នាំ២០២៣ ខណៈដែលសមាមាត្រឥណទានទៅកាន់អង្គភាពគ្រួសារថយចុះពី ៣៣,២% មក ២៨,៣%។ ទន្ទឹមនេះ សមាមាត្រឥណទានទៅកាន់វិស័យផ្សេងទៀត ក្រៅពីវិស័យសំណង់ និងកម្មន្តសាល ក៏បានថយចុះផងដែរ បើធៀបនឹងឆ្នាំ២០២២ (ក្រាហ្វ ២.២៩)។

សម្រាប់ MFI ឥណទានទៅកាន់អង្គភាពគ្រួសារមានសមាមាត្រធំជាងគេ ៣៧,៩% នៃឥណទានសរុប ដែលបានកើនពី ៣៣,១% នៅឆ្នាំ២០២២ ហើយសមាមាត្រធំបន្ទាប់គឺ សេវាកម្ម ១៥,៤% ពាណិជ្ជកម្មនិងការជួញដូរ ១៣,៩% សំណង់ ១០,៥% កសិកម្ម ៦,៣% និង កម្មន្តសាល ៥,៨%។ បើធៀបនឹងឆ្នាំ២០២២ ឥណទានទៅកាន់អង្គភាពគ្រួសារ សេវាកម្ម និងកម្មន្តសាល មានសមាមាត្រធំជាងមុន ខណៈដែលសមាមាត្រឥណទានទៅកាន់វិស័យផ្សេងទៀតបានរួមតូច (ក្រាហ្វ ២.៣០)។

**ការរួមចំណែកក្នុងកំណើនឥណទានតាមវិស័យបានបង្ហាញថា ការថយចុះនៃឥណទានរបស់ MDI ត្រូវបានជំរុញដោយឥណទានទៅកាន់អង្គភាពគ្រួសារ ពាណិជ្ជកម្ម និងសេវាកម្ម។** ឥណទានក្នុងវិស័យមីក្រូហិរញ្ញវត្ថុបានថយចុះ -៤៦% នៅឆ្នាំ២០២៣ ធៀបនឹងកំណើន ២២,៧% នៅឆ្នាំ២០២២។ ការថយចុះឥណទាននេះគឺបណ្តាលមកពីឥទ្ធិពលមូលដ្ឋាន (base effect) នៃ

២.២៩ សមាមាត្រឥណទានតាមវិស័យរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភពៈ ធនាគារជាតិនៃកម្ពុជា

២.៣០ សមាមាត្រឥណទានតាមវិស័យរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ (ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភពៈ ធនាគារជាតិនៃកម្ពុជា

ការចាកចេញរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ពីវិស័យមីក្រូហិរញ្ញវត្ថុ ហើយកំណើនឥណទានត្រូវបានរំពឹងថានឹងងើបឡើងវិញនៅឆ្នាំក្រោយ។ ឥណទានរបស់ MDI មានកំណើនអវិជ្ជមានក្នុងអត្រា -៥៦% ដែលរួមចំណែកជាចម្បងដោយការថយចុះឥណទានទៅកាន់អង្គភាពគ្រួសារ -២០,៨% នៃកំណើនឥណទានសរុប ពាណិជ្ជកម្ម -១៤,៥% និងសេវាកម្មនៅ -៩% (ក្រាហ្វ ២.៣១)។

**កំណើនឥណទាន MFI ត្រូវបានគាំទ្រដោយឥណទានទៅកាន់អង្គភាពគ្រួសារ កម្មន្តសាល និងសេវាកម្ម។** កំណើនឥណទាន MFI នៅឆ្នាំ២០២៣ មានអត្រា ១២,៩% ថមថយធៀបនឹងអត្រា ៣៤,២% នៅឆ្នាំ២០២២។ កំណើននេះជាចម្បងរួមចំណែកដោយឥណទានទៅកាន់អង្គភាពគ្រួសារ ៩,៧% នៃកំណើនឥណទានសរុប កម្មន្តសាល ២,៥% និងសេវាកម្ម ២,២%។ ដោយឡែក ឥណទានទៅកាន់វិស័យសំណង់ ពាណិជ្ជកម្ម កសិកម្ម និងការដឹកជញ្ជូន បានរួមចំណែកអវិជ្ជមានដល់កំណើនឥណទានក្នុងអត្រា -១,១% -០,៥២% -០,៣៧% និង -០,៣% រៀងគ្នា (ក្រាហ្វ ២.៣២)។ ការថយចុះឥណទានក្នុងវិស័យទាំងនោះអាចបណ្ដាលមកពីការកើនឡើងនៃថ្លៃដើមមូលនិធិ គួបផ្សំនឹងការងើបឡើងយឺតនៃសកម្មភាពសេដ្ឋកិច្ច។ ជារួម វិស័យមីក្រូហិរញ្ញវត្ថុដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្ដល់ហិរញ្ញប្បទានទៅកាន់សហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) និងអង្គភាពគ្រួសារនៅតាមទីជនបទ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងសកម្មភាព MSMEs ។

## ខ. គុណភាពឥណទាន

**គុណភាពឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបន្តថយចុះ ប៉ុន្តែស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន ជាមួយនឹងសំវិធានធនគ្រប់គ្រាន់។** ឥណទានហួសកាលកំណត់ទូទាត់សងរយៈពេល ៣០ថ្ងៃ របស់ MDI បានកើនឡើងពី ៤៦០ ប៊ីលានរៀល នៅឆ្នាំ២០២២ ដល់ ៥២៩ ប៊ីលានរៀល នៅឆ្នាំ២០២៣ ជាមួយនឹងកំណើន ១៥%។ ជាលទ្ធផល

**២.៣១ ការរួមចំណែកក្នុងកំណើនឥណទានតាមវិស័យរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ**

(ភាគរយ, ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**២.៣២ ការរួមចំណែកក្នុងកំណើនឥណទានតាមវិស័យរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ**

(ភាគរយ, ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

អនុបាតឥណទានមិនដំណើរការបានកើនពី ១,៥% ដល់ ៣,៦% នៅគ្រាដូចគ្នា ដែលជាកម្រិតទាបនិងអាចគ្រប់គ្រងបាន។ ម្យ៉ាងទៀត MDI បន្តរក្សាសំវិធានធនគ្រប់គ្រាន់សម្រាប់ទប់ទល់នឹងការធ្លាក់ចុះគុណភាពឥណទាន ដោយអនុបាតសំវិធានធនជាក់លាក់ធៀបនឹងឥណទានមិនដំណើរការរបស់ MDI មានកម្រិត ៨៨% នៅឆ្នាំ២០២៣ (ក្រាហ្វ ២.៣៣)។

ជាមួយគ្នានេះ ឥណទានហួសកាលកំណត់ទូទាត់សងរយៈពេល ៣០ថ្ងៃ របស់ MFI បានកើនឡើង ៥៩,៣% ដល់ ៨២៩ ប៊ីលានរៀល ដែលល្បឿនកំណើនបានស្ទុះឡើងធៀបនឹងឆ្នាំ២០២២ (៣៥,៦%)។ សន្ទុះកំណើននេះបាននាំឱ្យអនុបាតឥណទានមិនដំណើរការកើនឡើងពី ៩,១% ដល់ ១២,៩%។ ទោះជា អនុបាតឥណទានមិនដំណើរការបានកើនឡើង ៣,៨% MFI ក៏បានធ្វើសំវិធាន-ធនដែលចាំបាច់សម្រាប់ការខាតបង់រំពឹងទុកពីឥណទានហួសកាលកំណត់ទូទាត់សងទាំងនោះ ជាមួយនឹងអនុបាតសំវិធានធនជាក់លាក់ធៀបឥណទានមិនដំណើរការមានកម្រិត ៥៥,៦% (ក្រាហ្វ ២.៣៤)។ ការថយចុះគុណភាពឥណទានរបស់ MFI ទាមទារឱ្យមានការតាមដានយ៉ាងយកចិត្តទុកដាក់ ហើយធនាគារជាតិនៃកម្ពុជានឹងបន្តត្រួតពិនិត្យ MFI យ៉ាងខ្ជាប់ខ្ជួន ដើម្បីធានាថាគ្រឹះស្ថានទាំងនោះផ្តល់ឥណទានប្រកបដោយភាពប្រុងប្រយ័ត្ន ធ្វើសំវិធានធនគ្រប់គ្រាន់ និងអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិត្រឹមត្រូវ។

## គ. ស្ថានភាពសន្ទនីយភាព និងមូលនិធិ

**ស្ថានភាពសន្ទនីយភាពរបស់ MDI បន្តមានភាពរឹងមាំនិងអាចធន់នឹងហានិភ័យសន្ទនីយភាពដែលអាចកើតមានឡើង ក្នុងពេលដែលសេដ្ឋកិច្ចកំពុងស្ថិតក្នុងដំណាក់កាលងើបឡើងវិញ។** កម្រិតសន្ទនីយភាពរបស់ MDI ដែលវាស់ដោយអនុបាតគ្របខណ្ឌសន្ទនីយភាពយោងតាមគោលការណ៍បាសែលបី បានកើនពី ១៥៧% នៅឆ្នាំ២០២២ ដល់ ២៨៦% នៅឆ្នាំ២០២៣ ដែលបន្តស្ថិតក្នុងកម្រិតខ្ពស់ជាងកម្រិតអប្បបរមាបទប្បញ្ញត្តិ (១០០%) (ក្រាហ្វ ២.៣៥)។ កម្រិតខ្ពស់នៃទ្រព្យសកម្មសន្ទនីយ

២.៣៣ **គុណភាពឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

២.៣៤ **គុណភាពឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

២.៣៥ **អនុបាតគ្របខណ្ឌសន្ទនីយភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ**
(ភាគរយ, ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ធៀបនឹងលំហូរចេញនៃសាច់ប្រាក់ដែលរំពឹងទុកនៅក្នុងខែណាមួយ គឺជាស្ថានភាពល្អសម្រាប់ MDI ដើម្បីការពារពីហានិភ័យសន្ទនីយភាព ប៉ុន្តែការរក្សាទ្រព្យសកម្មសន្ទនីយច្រើនក៏អាចរារាំងដល់ការផ្តល់ហិរញ្ញប្បទានបន្ថែមដល់សេដ្ឋកិច្ចដើម្បីគាំទ្រកំណើនផងដែរ។ ដូច្នេះ MDI គួររក្សាសន្ទនីយភាពក្នុងកម្រិតសមស្រប ដែលអាចឱ្យគ្រឹះស្ថានទាំងនោះអាចរក្សាទ្រនាប់សន្ទនីយភាពដើម្បីការពារហានិភ័យ ព្រមទាំងប្រើប្រាស់សន្ទនីយភាពដើម្បីផ្តល់ឥណទានដែលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព។

**ប្រាក់បញ្ញើបន្តជាប្រភពមូលនិធិចម្បងរបស់ MDI។** សមាមាត្រប្រាក់បញ្ញើអតិថិជនធៀបនឹងប្រភពមូលនិធិសរុបមានអត្រា ៥២% ថយចុះបន្តិចធៀបនឹងឆ្នាំ២០២២ (៥៤,១%)។ ប្រភពមូលនិធិពីរទៀតរួមមាន មូលនិធិកម្ចីដែលមានសមាមាត្រ ២៩,៣% និងដើមទុនដែលមានសមាមាត្រ ១៨,៧% (ក្រាហ្វ ២.៣៦)។ ប្រាក់បញ្ញើអតិថិជននៅឆ្នាំ២០២៣ មានចំនួន ៩,៤ ទ្រីលានរៀល (២,៣ ប៊ីលានដុល្លារអាមេរិក) ថយចុះ -៥២,៨% ធៀបនឹងឆ្នាំ២០២២ បន្ទាប់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ត្រូវបានរួមបញ្ចូលជាធនាគារពាណិជ្ជ។ ក្នុងប្រាក់បញ្ញើសរុប ប្រាក់បញ្ញើមានកាលកំណត់មានសមាមាត្រ ៨៤,៦% ដែលបង្ហាញពីប្រភពមូលនិធិមានស្ថិរភាព។

**២.៣៦ ប្រភពមូលនិធិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ**

(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**មូលនិធិកម្ចីរបស់ MDI ភាគច្រើនមានរយៈពេលវែង និងស្ថិរភាព ដែលបានជួយ MDI គ្រប់គ្រងហានិភ័យសន្ទនីយភាព។** គិតត្រឹមឆ្នាំ២០២៣ មូលនិធិកម្ចីសរុបរបស់ MDI មានចំនួន ៥,៣ ទ្រីលានរៀល (១,៣ ប៊ីលានដុល្លារអាមេរិក) ថយចុះ -៤៩,២% ធៀបនឹងឆ្នាំ២០២២។ មូលនិធិកម្ចីភាគច្រើនរបស់ MDI ជាកម្ចីរយៈពេលវែងដែលមានសមាមាត្រ ៨១,៨% នៃមូលនិធិកម្ចីសរុប ខណៈដែលសមាមាត្រមូលនិធិកម្ចីរយៈពេលខ្លីបានថយចុះពី ៨,៨% នៃមូលនិធិកម្ចីសរុប មក ៥,៤% នៅឆ្នាំ២០២៣ (ក្រាហ្វ ២.៣៧)។

**២.៣៧ មូលនិធិកម្ចីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ**

(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**រចនាសម្ព័ន្ធនៃប្រភពមូលនិធិរបស់ MFI ត្រូវបានបែងចែកជាដើមទុន និងមូលនិធិកម្ចី។** ពីដំបូង មូលនិធិ

ចម្បងរបស់ MFI មានប្រភពមកពីអង្គការក្រៅរដ្ឋាភិបាល ទាំងនៅក្នុងស្រុកនិងបរទេស ម្ចាស់ជំនួយ ធនាគារអភិវឌ្ឍន៍ពហុភាគី និងឧបត្ថម្ភធនរបស់រាជរដ្ឋាភិបាល។ ការពឹងផ្អែកលើប្រភពមូលនិធិបែបប្រពៃណីនេះ បានក្លាយជាឧបសគ្គដល់ការលូតលាស់នៃវិស័យនេះ ដែលជំរុញឱ្យ MFI ងាកទៅរកប្រភពមូលនិធិផ្សេងទៀត ដូចជាដើមទុន និងមូលនិធិកម្ចីសម្រាប់ការអភិវឌ្ឍនិងពង្រីកបណ្តាញប្រតិបត្តិការ។ គិតត្រឹមឆ្នាំ២០២៣ មូលនិធិកម្ចីរបស់ MFI មានសមាមាត្រ ៦៧,៦% នៃប្រភពមូលនិធិសរុប បន្ទាប់មកដើមទុនមានសមាមាត្រ ៣២,៤% (ក្រាហ្វ ២.៣៨)។

**ការវិភាគលើប្រភេទមូលនិធិកម្ចីរបស់ MFI បានបង្ហាញពីការពឹងផ្អែកលើមូលនិធិកម្ចីរយៈពេលវែង។** មូលនិធិកម្ចីរបស់ MFI បានកើនឡើង ១៧,៥% ដល់ ៤,៩ ទ្រីលានរៀល (១,២ ប៊ីលានដុល្លារអាមេរិក)។ មូលនិធិកម្ចីរយៈពេលវែង ដែលមានសមាមាត្រ ៧០,៥% នៃមូលនិធិកម្ចីសរុប បានកើនដល់ ៣,៤ ទ្រីលានរៀល (៨៤៤ លានដុល្លារអាមេរិក) ជាមួយនឹងអត្រាកំណើន ២០% ធៀបនឹងឆ្នាំ២០២២។ ដោយឡែក មូលនិធិកម្ចីរយៈពេលខ្លីកើនត្រឹម ១០,៨% ដល់ ១,៣ ទ្រីលានរៀល (៣៣០ លានដុល្លារអាមេរិក) ដោយសមាមាត្រមូលនិធិកម្ចីរយៈពេលខ្លីបានរួមតូចបន្តិចពី ២៩,៣% នៅឆ្នាំ២០២២ មក ២៧,៦% នៅឆ្នាំ២០២៣ (ក្រាហ្វ ២.៣៩)។ ជារួម MFI កំពុងបង្កើនមូលនិធិកម្ចីរយៈពេលវែង ដើម្បីអាចគ្រប់គ្រងសន្ទនីយភាព និងការប្រែក្លាយតណប្រតិទានរវាងទ្រព្យអកម្មនិងទ្រព្យសកម្មបានប្រសើរជាងមុន។

## ឃ. លទ្ធភាពស្វែងរកប្រាក់ចំណេញ និងភាពគ្រប់គ្រាន់នៃដើមទុន

**វិស័យមីក្រូហិរញ្ញវត្ថុបានបង្ហាញពីការធ្លាក់ចុះនៃលទ្ធភាពស្វែងរកប្រាក់ចំណេញ ក្នុងពេលដែលថ្លៃដើមមូលនិធិនៅមានកម្រិតខ្ពស់ និងកំណើនសំវិធានធន។** MDI សម្រេចបានប្រាក់ចំណេញសុទ្ធចំនួន ៣៦៦ ប៊ីលានរៀល (៨៩,៦ លានដុល្លារអាមេរិក) ក្នុងឆ្នាំ២០២៣ ថយចុះ -៧០% ធៀបនឹងឆ្នាំ២០២២ ដែលបណ្តាលមកពីឥទ្ធិពលនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ក្លាយជាធនាគារ

**២.៣៨ ប្រភពមូលនិធិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ (ឆ្នាំ២០១៧ - ឆ្នាំ២០២៣)**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**២.៣៩ មូលនិធិកម្ចីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ (ឆ្នាំ២០១៧ - ឆ្នាំ២០២៣)**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ពាណិជ្ជ គួបផ្សំនឹងកំណើនចំណាយសំវិធានធននិងកម្រិតខ្ពស់នៃថ្លៃដើមមូលនិធិ។ ចំណូលពីការប្រាក់សុទ្ធបានថយចុះ -៥៦% ដោយសារឥទ្ធិពលមូលដ្ឋាន និងការជះឥទ្ធិពលនៃអត្រាការប្រាក់ខ្ពស់មកពីការអនុវត្តនយោបាយរូបិយវត្ថុរឹតត្បិតរបស់ប្រទេសសេដ្ឋកិច្ចអភិវឌ្ឍន៍មកលើប្រភពមូលនិធិរបស់ MDI លឿនជាងមកលើការផ្តល់ឥណទានរបស់ MDI។ ទន្ទឹមនេះ សំវិធានធនសុទ្ធបានកើនឡើង ១៧,៥% ដែលបង្ហាញពីការបន្តខិតខំប្រឹងប្រែងរបស់គ្រឹះស្ថានក្នុងការធ្វើសំវិធានធនគ្រប់គ្រាន់ដើម្បីទប់ទល់នឹងចំណាយដែលអាចកើតឡើងពីឥណទានមិនដំណើរការ (ក្រាហ្វ ២.៤០)។

**កំណើនចំណាយសំវិធានធនបាននាំឱ្យប្រាក់ចំណេញរបស់ MFI ទាបជាងមុន។** បន្ទាប់ពីមានសន្ទុះងើបឡើងវិញនៅឆ្នាំ២០២២ ប្រាក់ចំណេញសុទ្ធបានថយចុះ -៨២% មកត្រឹម ១៨,៩ ប៊ីលានរៀល (៤,៦ លានដុល្លារអាមេរិក) ដោយសារកំណើនចំណាយសំវិធានធនក្នុងអត្រា ៩០% និងចំណាយប្រតិបត្តិការក្នុងអត្រា ៧,៧%។ យ៉ាងណាមិញ ចំណូលពីការប្រាក់ និង មិនមែនការប្រាក់សុទ្ធ បានកើនឡើង ១២,៥% និង ២១,៣% រៀងគ្នា (ក្រាហ្វ ២.៤១)។ ទោះជា ការកើនឡើងនៃចំណាយសំវិធានធនបានដាក់សម្ពាធលើលទ្ធភាពស្វែងរកប្រាក់ចំណេញរបស់ MFI ការធ្វើសំវិធានធនរបស់ MFI នឹងជួយឱ្យគ្រឹះស្ថានទទួលស្គាល់ចំណាយជាមុនសម្រាប់ការរំពឹងទុកពីការខាតបង់ដោយសារឥណទានមិនដំណើរការ។ ដោយសេដ្ឋកិច្ចបន្តងើបឡើងវិញ លទ្ធភាពស្វែងរកប្រាក់ចំណេញរបស់ MFI ត្រូវបានរំពឹងថានឹងមានចីរភាពឡើងវិញ ស្របពេលដែលចំណូលពីការប្រាក់និងមិនមែនការប្រាក់បន្តមានកំណើនរឹងមាំ។

**២.៤០ រចនាសម្ព័ន្ធប្រាក់ចំណេញរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ**

(លានរៀល, ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**២.៤១ រចនាសម្ព័ន្ធប្រាក់ចំណេញរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ**

(លានរៀល, ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

សូចនាករជាទូទៅដែលត្រូវបានប្រើដើម្បីវាយតម្លៃប្រាក់ចំណេញ គឺ ROA និង ROE។ ROA សម្រាប់ MDI និង MFI បានថយចុះពី ៣,៣% និង ១,៦% នៅក្នុងឆ្នាំ២០២២ មក ២% និង ០,៣% រៀងគ្នា នៅឆ្នាំ២០២៣។ ទន្ទឹមនេះ ROE សម្រាប់ MDI និង MFI បានថយចុះពី ១៦,២% និង ៤,៨% មក ៩% និង ០,៨% រៀងគ្នា (ក្រាហ្វ ២.៤២)។ ការថមថយនៃអនុបាតនេះ បណ្តាលមកពីការធ្លាក់ចុះនៃប្រាក់ចំណូលសុទ្ធ (ដូចបានពិភាក្សាក្នុងផ្នែកខាងលើ)។

ប្រសិទ្ធភាពប្រតិបត្តិការរបស់ MDI បានថយចុះ ដែលឆ្លុះបញ្ចាំងតាមរយៈកម្រិតខ្ពស់ជាងមុននៃអនុបាតចំណាយប្រតិបត្តិការធៀបនឹងចំណូលប្រតិបត្តិការពី ៤០,៧% ក្នុងឆ្នាំ២០២២ ដល់ ៤៩,៤% ក្នុងឆ្នាំ២០២៣។ ដោយឡែក ប្រសិទ្ធភាពប្រតិបត្តិការរបស់ MFI មានភាពប្រសើរបន្តិច ដោយអនុបាតប្រសិទ្ធភាពចំណាយថយចុះពី ៦១,៦%មក ៥៨,១%ដែលបង្ហាញពីការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព ក្នុងការបង្កើតប្រាក់ចំណូលជាមួយនឹងចំណាយតិចជាងមុន។ យ៉ាងណាមិញ បើប្រៀបធៀបកម្រិតអនុបាតរវាង MDI និង MFI ប្រសិទ្ធភាពចំណាយរបស់ MDI បន្តមានភាពប្រសើរជាង MFI (ក្រាហ្វ ២.៤៣)។

**ស្ថានភាពដើមទុនរបស់វិស័យមីក្រូហិរញ្ញវត្ថុបន្តមានភាពរឹងមាំ ដែលឆ្លុះបញ្ចាំងពីភាពធន់នៃវិស័យនេះទៅនឹងហានិភ័យដែលអាចកើតមានឡើង។** ដើមទុនបទប្បញ្ញត្តិរបស់ MDI បានថយចុះជិតពាក់កណ្តាលនៅឆ្នាំ២០២៣ មកត្រឹម ៣,៦ ទ្រីលានរៀល (៨៨៣ លានដុល្លារអាមេរិក) ក្រោយពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់បានក្លាយជាធនាគារពាណិជ្ជ។ ទោះយ៉ាងណា CAR បន្តមានភាពរឹងមាំ ២២,៩% ខ្ពស់ជាងកម្រិតកំណត់បទប្បញ្ញត្តិ ១៥% (ក្រាហ្វ ២.៤៤)។ ដើមទុនបទប្បញ្ញត្តិភាគច្រើនជាដើមទុនថ្នាក់ទីមួយ ដែលមានគុណភាពល្អ ជាមួយនឹងអនុបាតដើមទុនថ្នាក់ទីមួយធៀបនឹងទ្រព្យសកម្មថ្លឹងតាមទម្ងន់ហានិភ័យមានកម្រិត ១៨,៧%។ ទ្រនាប់ដើមទុននេះគួបផ្សំនឹងសំវិធានធនគ្រប់គ្រាន់ដែលបានលើកឡើងក្នុង

**២.៤២ ប្រាក់ចំណេញធៀបទ្រព្យសកម្ម និងមូលនិធិភាគទុនិក**

(ភាគរយ, ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**២.៤៣ អនុបាតប្រសិទ្ធភាពចំណាយ**

(ភាគរយ, ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**២.៤៤ ស្ថានភាពដើមទុនរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ**

(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ផ្នែកលទ្ធភាពស្វែងរកប្រាក់ចំណេញ បង្ហាញពីភាពធន់របស់ MDI ក្នុងការទប់ទល់នឹងការខាតបង់ទាំងរំពឹងទុក និងមិនបានគ្រោងទុក។

សម្រាប់ MFI ដើមទុនបទប្បញ្ញត្តិបានកើនឡើង ១៦,៥% ដល់ ២,៣ ទ្រីលានរៀល (៥៧២ លានដុល្លារអាមេរិក) ខណៈដែលទ្រព្យសកម្មថ្លឹងតាមទម្ងន់ហានិភ័យបានកើនឡើងលឿនជាងបន្តិច ១៦,៧% ដល់ ៧,៤ ទ្រីលានរៀល (១,៨ ប៊ីលានដុល្លារអាមេរិក)។ ជាលទ្ធផល អនុបាតភាពគ្រប់គ្រាន់នៃដើមទុនមានស្ថិរភាពនៅកម្រិត ៣១,៦% ខ្ពស់ជាងកម្រិតកំណត់បទប្បញ្ញត្តិ ១៥% (ក្រាហ្វ ២.៤៥)។ ប្រហាក់ប្រហែលគ្នានឹង MDI ដែរ MFI រក្សាបានភាពរឹងមាំនៃដើមទុន និងធ្វើសំវិធានធនគ្រប់គ្រាន់ ដែលចាំបាច់សម្រាប់ទប់ទល់នឹងវិបត្តិដែលអាចកើតឡើងដោយមិនបានគ្រោងទុក ដោយសារភាពមិនច្បាស់លាស់នៃស្ថានភាពសេដ្ឋកិច្ចអន្តរជាតិ និងក្នុងស្រុក។

**២.៤៥ ស្ថានភាពដើមទុនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ២.៤ គ្រឹះស្ថានធនាគារឯកទេស

**ទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារឯកទេសបានថយចុះបន្តិច ដោយសារការថមថយកំណើនឥណទាន។** គិតត្រឹមចុងឆ្នាំ២០២៣ ធនាគារឯកទេសមានចំនួន ៩ គ្រឹះស្ថាន មានទ្រព្យសកម្ម ២,៦ ទ្រីលានរៀល (៦៤៥,២ លានដុល្លារអាមេរិក) ដែលមានសមាមាត្រ ០,៨% នៃទ្រព្យសកម្មសរុបនៅក្នុងប្រព័ន្ធធនាគារ។ ធៀបនឹងឆ្នាំ២០២២ ទ្រព្យសកម្មធនាគារឯកទេសបានថយចុះ -៣,២% (ក្រាហ្វ ២.៤៦)។

**២.៤៦ ទ្រព្យសកម្មគ្រឹះស្ថានធនាគារឯកទេស**
(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ធនាគារឯកទេសផ្ដល់ឥណទានជាចម្បងទៅកាន់បុគ្គល។** ឥណទានបុគ្គលមានសមាមាត្រ ៧៤,៥% នៃឥណទានសរុប បន្ទាប់មកការទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួនមានសមាមាត្រ ១១,១% ការជួញដូររាយ ៣,២% ការជួញដូរដុំ ២,៣% និងផ្សេងៗទៀត ៨,៩% (ក្រាហ្វ ២.៤៧)។ ធៀបនឹងឆ្នាំ២០២២ សមាមាត្រនៃឥណទានបុគ្គលបានថយចុះពី ៨២,៧% មក ៧៤,៥% ខណៈដែលសមាមាត្រនៃការទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួនបានកើនពី ៣,២% ដល់ ១១,១%។ ទោះយ៉ាងណា សមាមាត្រនៃ

**២.៤៧ សមាមាត្រឥណទានតាមវិស័យ**
(គិតត្រឹមខែធ្នូ ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ឥណទានទៅកាន់វិស័យផ្សេងៗទៀតបន្តមានទំហំតូច ដោយឥណទានបុគ្គលនៅតែមានសមាមាត្រធំជាងគេ។

**ឥណទានធនាគារឯកទេសបានថមថយកំណើនគួរឱ្យកត់សម្គាល់នៅឆ្នាំ២០២៣។** កំណើនឥណទានបានថយចុះពី ១៥,២% នៅឆ្នាំ២០២២ ដល់ ១,៦% នៅឆ្នាំ២០២៣ ជាមួយនឹងឥណទាន ២,៣ ទ្រីលានរៀល (៥៥៦ លានដុល្លារអាមេរិក)។ កំណើនឥណទានត្រូវបានរួមចំណែកដោយ ការទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន ៨,១% នៃកំណើន និងឥណទានទៅវិស័យកសិកម្ម ០,៨% ខណៈដែលឥណទានទៅកាន់វិស័យផ្សេងទៀតមានកំណើនអវិជ្ជមាន ជាពិសេសឥណទានបុគ្គល -៧% (ក្រាហ្វ ២.៤៨)។

**ស្ថានភាពដើមទុនរបស់ធនាគារឯកទេសបន្តមានភាពរឹងមាំ ដែលជាទ្រនាប់ការពារក្នុងពេលដែលឥណទានមិនដំណើរការកំពុងកើនឡើង។** អនុបាតឥណទានមិនដំណើរការបានកើនពី ៨,៥% នៅឆ្នាំ២០២២ ដល់ ១២,១% នៅឆ្នាំ២០២៣ ដែលកម្រិតមួយខ្ពស់ជាងគេក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ។ ទោះយ៉ាងណាឥណទានរបស់ធនាគារឯកទេសមានទំហំតូច បើធៀបនឹងធនាគារពាណិជ្ជ ដូច្នេះកម្រិតអនុបាតនេះនៅអាចគ្រប់គ្រងបាន។ ម្យ៉ាងទៀត នៅឆ្នាំ២០២៣ ធនាគារឯកទេសមានដើមទុនខ្ពស់ ដោយអនុបាតភាពគ្រប់គ្រាន់នៃដើមទុនមានអត្រា ៣៩% កើនឡើងពី ៣១,៤% នៅឆ្នាំ២០២២ និងស្ថិតនៅកម្រិតខ្ពស់ជាងកម្រិតបទប្បញ្ញត្តិអប្បបរមា ១៥% (ក្រាហ្វ ២.៤៩)។ ទ្រនាប់ដើមទុននេះនឹងអាចឱ្យធនាគារឯកទេសទប់ទល់នឹងការខាតបង់ដែលអាចកើតមានដោយសារឥណទានមិនដំណើរការ។

**២.៤៨ ការរួមចំណែកក្នុងកំណើនឥណទានតាមវិស័យ**
(ភាគរយ, ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**២.៤៩ អនុបាតភាពគ្រប់គ្រាន់នៃដើមទុន និងឥណទានមិនដំណើរការ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ២.៥ សន្និដ្ឋាន

ការវិភាគផ្អែកលើទិន្នន័យគិតត្រឹមខែធ្នូ ឆ្នាំ២០២៣ បង្ហាញថា ប្រព័ន្ធធនាគារបន្តមានភាពធន់ និងបានបន្តផ្តល់ហិរញ្ញប្បទានចាំបាច់ ដើម្បីគាំទ្រដល់ការងើបឡើងវិញនៃសេដ្ឋកិច្ចបន្ទាប់ពីវិបត្តិកូវីដ-១៩។ ទោះយ៉ាងណាកំណើនឥណទានបានថមថយគួរឱ្យកត់សម្គាល់នៅឆ្នាំ២០២៣ ថ្វីបើទិន្នន័យធនាគារមិនបានឆ្លុះបញ្ចាំងពី

និន្នាការនេះ ដោយការរួមបញ្ចូលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាមួយនឹងធនាគារពាណិជ្ជបាននាំឱ្យកំណើនឥណទានធនាគារមានសន្ទុះក្នុងរយៈពេលខ្លី។ ការថមថយតម្រូវការឥណទានកើតមានឡើងនៅតាមវិស័យភាគច្រើន ដែលបណ្តាលមកពីកម្រិតខ្ពស់នៃអត្រាការប្រាក់ ការកើនឡើងបំណុល និងការងើបឡើងវិញយឺតនៃវិស័យសេដ្ឋកិច្ចមួយចំនួន។ គ្រឹះស្ថានធនាគារបានផ្តល់ឥណទានប្រកបដោយភាពប្រុងប្រយ័ត្ន ក្នុងពេលដែលគុណភាពឥណទានបានធ្លាក់ចុះ ដែលបានទាមទារឱ្យមានការធ្វើសំវិធានធនបន្ថែម។ កំណើនចំណាយការប្រាក់និងសំវិធានធនបានដាក់សម្ពាធមកលើលទ្ធភាពស្វែងរកប្រាក់ចំណេញរបស់គ្រឹះស្ថានធនាគារ។ យ៉ាងណាមិញស្ថានភាពសន្ទនីយភាពមានភាពប្រសើរ ហើយដើមទុនក៏មានភាពគ្រប់គ្រាន់ផងដែរ។ ការធ្វើស្ត្រេសតេស្តបានបង្ហាញថា គ្រឹះស្ថានធនាគារនៅតែមានលទ្ធភាពគ្រប់គ្រាន់ដើម្បីទប់ទល់នឹងការថយចុះគុណភាពទ្រព្យសកម្មក្រោមសេណារីយ៉ូស្ត្រេសផ្សេងៗ។ ខណៈដែលអនុបាត NPLR របស់ MFI និងធនាគារឯកទេសមានកម្រិតខ្ពស់ជាងធនាគារពាណិជ្ជ អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានទាំងនេះ ជារួម បន្តមានកម្រិតខ្ពស់។

បន្ថែមទៅលើវិស័យធនាគារដែលធនាគារជាតិនៃកម្ពុជាបន្តតាមដានយ៉ាងយកចិត្តទុកដាក់ ហានិភ័យក៏អាចកើតមានឡើងពីក្រុមហ៊ុនដែលមានសកម្មភាពមួយចំនួនប្រហាក់ប្រហែលនឹងធនាគារ ដូចជា ក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យ ឬហាងបញ្ចាំ ជាដើម។ ក្រុមហ៊ុនទាំងនេះមិនស្ថិតក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា និងមានព័ត៌មានតិចតួចពាក់ព័ន្ធនឹងប្រតិបត្តិការស្ថានភាពហិរញ្ញវត្ថុ ឬលទ្ធភាពសងបំណុលរបស់អតិថិជនពួកគេ។ ដូចនេះ អាជ្ញាធរបទប្បញ្ញត្តិពាក់ព័ន្ធត្រូវពង្រឹងការប្រមូលទិន្នន័យ ក៏ដូចជាក្របខ័ណ្ឌបទប្បញ្ញត្តិត្រួតពិនិត្យក្រុមហ៊ុនទាំងនេះ សំដៅទប់ស្កាត់ហានិភ័យដែលអាចមានឥទ្ធិពលមកលើប្រព័ន្ធហិរញ្ញវត្ថុទាំងមូល។

# III វិស័យហិរញ្ញវត្ថុមិនមែនធនាគារ

*ទីផ្សារមូលបត្របានបន្តអភិវឌ្ឍជាមួយនឹងការចុះបញ្ជីក្រុមហ៊ុនថ្មីៗបន្ថែមទៀត ទាំងនៅក្នុងទីផ្សារមូលបត្រកម្មសិទ្ធិ និងទីផ្សារមូលបត្របំណុល។ ខណៈដែលសន្ទស្សន៍ផ្សារហ៊ុនកម្ពុជា (CSX) បានធ្លាក់ចុះបន្តិច មូលធនូបនីយកម្មទីផ្សារបានកើនឡើងគួរឱ្យកត់សម្គាល់ បន្ទាប់ពីក្រុមហ៊ុនថ្មីពីរត្រូវបានចុះបញ្ជីនៅក្នុងទីផ្សារ។ ចំណែកឯសកម្មភាពជួញដូរភាគហ៊ុនបានធ្លាក់ចុះខ្លាំង ទាំងតម្លៃនិងបរិមាណនៃការជួញដូរជាមធ្យមប្រចាំថ្ងៃ ទោះជាចំនួនគណនីជួញដូរបានកើនឡើងជាលំដាប់ក៏ដោយ។ ទីផ្សារមូលបត្របំណុលបានបន្តទាក់ទាញការចុះបញ្ជីថ្មីដោយក្រុមហ៊ុនផ្សេងៗដែលអាចទទួលបានប្រភពមូលនិធិជាប្រាក់រៀល។ គិតត្រឹមឆ្នាំ២០២៣ សញ្ញាប័ណ្ណសាជីវកម្មសរុបដែលមិនទាន់ដល់ឥណប្រតិទានមានចំនួន ៥១៨,២ ប៊ីលានរៀល (១២៦,៩ លានដុល្លារអាមេរិក) ដែលក្នុងនោះក្រុមហ៊ុនទូរគមនាគមន៍មានសមាមាត្រជិត ៩០% នៃទំហំសញ្ញាប័ណ្ណសាជីវកម្មសរុប។ ចំណែកឯវិស័យធានារ៉ាប់រងបានបន្តរីកចម្រើន ប៉ុន្តែក្នុងល្បឿនយឺត ដោយបុព្វលាភធានារ៉ាប់រងសរុបមានចំនួន ១,៤ ទ្រីលានរៀល (៣៣៩,៦ លានដុល្លារអាមេរិក) នៅឆ្នាំ២០២៣។*

## ៣.១ ទីផ្សារទ្រព្យសកម្ម

### ក. ទីផ្សារមូលបត្រកម្មសិទ្ធិ

**សន្ទស្សន៍ផ្សារមូលបត្រកម្ពុជា (CSX) បានធ្លាក់ចុះបន្តិច ខណៈដែលមូលធនូបនីយកម្មទីផ្សារបានកើនឡើងគួរឱ្យកត់សម្គាល់ធៀបនឹងឆ្នាំមុន។** នៅចុងឆ្នាំ២០២៣ សន្ទស្សន៍ផ្សារមូលបត្រកម្ពុជាមានកម្រិត ៤៧២,៧ សន្ទស្សន៍ ដែលបានថយចុះ -២,៣% ពី ៤៨៣,៧ សន្ទស្សន៍ កាលពីឆ្នាំ២០២២ (ក្រាហ្វ ៣.១)។ ចំណែកឯមូលធនូបនីយកម្មរួមទាំងទីផ្សារគោល និងទីផ្សារកំណើនបានកើនឡើង ៧១,២% ពី ៧,៥ ទ្រីលានរៀល (១,៩ ប៊ីលានដុល្លារអាមេរិក) នៅឆ្នាំ២០២២ ដល់ ១២,៨ ទ្រីលានរៀល (៣,២ ប៊ីលានដុល្លារអាមេរិក) ដែលជាចម្បងដោយសារការចុះបញ្ជីថ្មីរបស់ក្រុមហ៊ុនខេមជ្វីអេសអេម (CGSM) និងក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន (MJQE) ដែលមានមូលធនូបនីយកម្មប្រមាណ ៥,៤ ទ្រីលានរៀល (១,២ ប៊ីលានដុល្លារអាមេរិក)។

មូលធនូបនីយកម្មទីផ្សាររបស់ក្រុមហ៊ុន ខេមជ្វី-អេសអេម មានសមាមាត្រធំជាងគេនៅក្នុងទីផ្សារភាគហ៊ុន (៤០,២% នៃមូលធនូបនីយកម្មទីផ្សារសរុប) បន្ទាប់មកធនាគារអេស៊ីលីដា (៣៤%) កំពង់ផែស្វយ័តក្រុងព្រះ-សីហនុ (៨,៩%) ក្រុមហ៊ុនម៉េងលី ជេ. គួច អេឌ្យូខេសិន

**៣.១ សន្ទស្សន៍ផ្សារមូលបត្រកម្ពុជា**
(ខែមករា ឆ្នាំ២០២២ - ខែធ្នូ ឆ្នាំ២០២៣)




ប្រភព៖ ផ្សារមូលបត្រកម្ពុជា

**៣.២ ទំហំមូលធនូបនីយកម្មទីផ្សារ**
(ឆ្នាំ២០១៨ - ២០២៣)




ប្រភព៖ ផ្សារមូលបត្រកម្ពុជា

(៥,៤%) និងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (៤,៩%) (ក្រាហ្វ ៣.២)។

**សកម្មភាពជួញដូរប្រចាំថ្ងៃនៅក្នុងទីផ្សារមូលបត្រកម្មសិទ្ធិ បានធ្លាក់ចុះគួរឱ្យកត់សម្គាល់នៅឆ្នាំ២០២៣ ទាំងទំហំទឹកប្រាក់ និងបរិមាណភាគហ៊ុន។** ជាក់ស្តែង តម្លៃនៃការជួញដូរជាមធ្យមប្រចាំថ្ងៃ បានធ្លាក់ចុះក្នុងអត្រា ៦២% ពី ២,១ ប៊ីលានរៀល (០,៥ លានដុល្លារអាមេរិក) នៅឆ្នាំ២០២២ មកត្រឹម ៨២៨,២ លានរៀល (០,២ លានដុល្លារអាមេរិក) ហើយបរិមាណជួញដូរជាមធ្យមប្រចាំថ្ងៃមានចំនួនត្រឹម ១២៨.១៥៦ ភាគហ៊ុន ដែលបានធ្លាក់ចុះ -៤២,៨% (ក្រាហ្វ ៣.៣)។ ការធ្លាក់ចុះនេះមួយផ្នែកអាចបណ្តាលមកពីការជួញដូរតាមការចរចាមានតិចជាងមុន និងការរំពឹងទុកទាបលើការបែងចែកភាគលាភ។

ចំនួនគណនីជួញដូរ ទាំងជនជាតិខ្មែរនិងបរទេស បានកើនឡើង ៣២,៨% ដល់ ៤៨.០១៦ គណនី ដែលក្នុងនោះ វិនិយោគិនកម្ពុជាមានសមាមាត្រជិត ៩០% (ក្រាហ្វ ៣.៤)។ ចំនួនគណនីជួញដូរត្រូវបានរំពឹងថានឹងបន្តកើនឡើង ដោយសារស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងសក្តានុពលសម្រាប់កំណើនសេដ្ឋកិច្ច។ ស្របតាមនិន្នាការកើនឡើងយ៉ាងឆាប់រហ័សនៃឌីជីថលូបនីយកម្មនៅក្នុងប្រព័ន្ធទូទាត់ ផ្សារមូលបត្រកម្ពុជាបានធ្វើទំនើបកម្មគួរឱ្យកត់សម្គាត់ តាមរយៈការដាក់ឱ្យប្រើប្រាស់កម្មវិធីទូរស័ព្ទចល័ត CSX Trade ការធ្វើបច្ចុប្បន្នកម្មលើកម្មវិធីផ្សារហ៊ុន ដែលជាមគ្គុទ្ទេសក៍សម្រាប់ការវិនិយោគ និងការអនុញ្ញាតឱ្យមានការបើកគណនីតាមអនឡាញ ដែលបានផ្តល់បរិយាកាសជួញដូរឱ្យកាន់តែមានភាពងាយស្រួល ព្រមទាំងបានគាំទ្រដល់ការបង្កើនជំនឿទុកចិត្ត និងការចាប់អារម្មណ៍របស់សាធារណជន មកលើផ្សារមូលបត្រកម្ពុជា។

**៣.៣ ទំហំនិងតម្លៃជួញដូរប្រចាំថ្ងៃជាមធ្យម**
(ឆ្នាំ២០១៨ - ២០២៣)




ប្រភពៈ ផ្សារមូលបត្រកម្ពុជា

**៣.៤ ចំនួនគណនីជួញដូរ**
(ឆ្នាំ២០១៨ - ២០២៣)




ប្រភពៈ ផ្សារមូលបត្រកម្ពុជា

## ខ. ទីផ្សារមូលបត្របំណុល

### ខ.១ មូលបត្ររដ្ឋ

**មូលបត្ររដ្ឋត្រូវបានបោះផ្សាយចំនួន ២៣៧,២ ប៊ីលានរៀល (៥៧,៥ លានដុល្លារអាមេរិក) នៅឆ្នាំ២០២៣**

(ក្រាហ្វ ៣.៥) **ដោយមានឥណប្រតិទានចាប់ពី ១ឆ្នាំ រហូតដល់ ៥ឆ្នាំ។** អត្រាគូប៉ុងនៃមូលបត្ររដ្ឋមានកម្រិតចាប់ពី ៣,៤៨% ដល់ ៤,៥% ដោយធ្វើការទូទាត់ប្រចាំឆមាស។ ទន្ទឹមនេះ មូលបត្ររដ្ឋសរុបចំនួន ៧២ ប៊ីលានរៀល (១៧,៥ លានដុល្លារអាមេរិក) បានដល់ឥណប្រតិទាននៅឆ្នាំ២០២៣។ ការបោះផ្សាយមូលបត្ររដ្ឋនេះ ជាជំហានដ៏សំខាន់មួយក្នុងការរួមចំណែកដល់ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុរបស់កម្ពុជា និងការកៀរគរហិរញ្ញប្បទានជារូបិយវត្ថុជាតិ។ ឧបករណ៍នេះក៏អាចជួយសម្រួលដល់ប្រតិបត្តិការនយោបាយរូបិយវត្ថុផ្អែកលើយន្តការទីផ្សារ និងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលផងដែរ។

**៣.៥ ការបោះផ្សាយមូលបត្ររដ្ឋ**

(លានរៀល, ខែកញ្ញា ឆ្នាំ២០២២ - ខែធ្នូ ឆ្នាំ២០២៣)




ប្រភព៖ ផ្សារមូលបត្រកម្ពុជា

## ខ.២ សញ្ញាប័ណ្ណសាជីវកម្ម

**ទីផ្សារមូលបត្របំណុលសាជីវកម្មបានបន្តទាក់ទាញក្រុមហ៊ុនថ្មីៗ ក្នុងការស្វែងរកប្រភពហិរញ្ញប្បទានជារូបិយវត្ថុក្នុងស្រុក។** នៅចុងឆ្នាំ២០២៣ ទីផ្សារមូលបត្របំណុលសាជីវកម្មមានក្រុមហ៊ុនសរុបចំនួន ៦ ដែលមានមូលបត្របំណុលចំនួន ៥១៨,២ ប៊ីលានរៀល (១២៦,៩ លានដុល្លារអាមេរិក) កើនឡើង ០,៦% ធៀបនឹងឆ្នាំមុន។ ក្រុមហ៊ុនទូរគមនាគមន៍ចំនួនពីរ (ក្រុមហ៊ុនតែលកូថេក និងក្រុមហ៊ុនខេមជ្ជីអេសអេម) មានសមាមាត្រចំនួន ៣៩,៧% នៃទីផ្សារមូលបត្របំណុលសាជីវកម្មសរុប បន្ទាប់មកក្រុមហ៊ុនរ៉ូយ៉ាល់ រេលវេ (២៧,១%) ក្រុមហ៊ុនអអិមអេ (ខេមបូឌា) (១៦,១%) សាលាអន្តរជាតិស៊ីអាយអេហ្វីស (១៦%) និងក្រុមហ៊ុនអចលនទ្រព្យហ្គោលដេនទ្រី (១,២%) (ក្រាហ្វ ៣.៦)។ ការបោះផ្សាយសញ្ញាប័ណ្ណសាជីវកម្មនេះឆ្លុះបញ្ចាំងពីតួនាទីរបស់ទីផ្សារមូលបត្របំណុលក្នុងការផ្តល់ហិរញ្ញប្បទានរយៈពេលវែងបន្ថែមទៀត ទៅកាន់សាជីវកម្មក្នុងវិស័យផ្សេងៗ។

**៣.៦ មូលធនូបនីយកម្មទីផ្សារមូលបត្របំណុលសាជីវកម្ម**

(ឆ្នាំ២០២៣)




ប្រភព៖ ផ្សារមូលបត្រកម្ពុជា

ចំពោះឥណប្រតិទាន មូលបត្របំណុលសាជីវកម្ម នៅក្នុងទីផ្សារមានពីរប្រភេទ រួមមានរយៈពេល ៥ឆ្នាំ និង ១០ឆ្នាំ (តារាង ៣.១)។ អត្រាគូប៉ុងសម្រាប់មូលបត្របំណុលសាជីវកម្មរយៈពេល ៥ឆ្នាំ មានកម្រិតចាប់ពី ៤,៥% ទៅអត្រាហិរញ្ញប្បទានអូវើណាយដោយមានការធានា(SOFR) + ៣,៥%។ ចំណែកឯអត្រាគូប៉ុងសម្រាប់មូលបត្របំណុលសាជីវកម្មរយៈពេល ១០ឆ្នាំមានចន្លោះពី ៧% ដល់ SOFR + ៣,៧៥%។

**តារាង ៣.១៖ អត្រាគូប៉ុងមូលបត្របំណុល**

| អ្នកបោះផ្សាយ | ឈ្មោះមូលបត្របំណុល | អត្រាគូប៉ុង | |
|---|---|---|---|
| | | ៥ឆ្នាំ | ១០ឆ្នាំ |
| ក្រុមហ៊ុន អ អិម អេ (កម្ពុជា) | សញ្ញាប័ណ្ណសាជីវកម្ម អ អិម អេ ខេមបូឌា | ៥,៥% | |
| ក្រុមហ៊ុន តែល កូថេក | សញ្ញាប័ណ្ណ តែលកូថេក | ៤,៥% | |
| | សញ្ញាប័ណ្ណ តែលកូថេក | SOFR* + ២,៥% | |
| ក្រុមហ៊ុនរ៉ូយ៉ាល់ អេលវេ | សញ្ញាប័ណ្ណសាជីវកម្ម រ៉ូយ៉ាល់ អេលវេ | | ៧% |
| | សញ្ញាប័ណ្ណមានបុគ្គលធានា រ៉ូយ៉ាល់ អេលវេ ១ | SOFR* + ៣,៥% ឬ ៥% ក្នុងមួយឆ្នាំ** | |
| | សញ្ញាប័ណ្ណមានបុគ្គលធានា រ៉ូយ៉ាល់ អេលវេ ២ | | SOFR+៣,៥% ឬ ៥% ក្នុងមួយឆ្នាំ** ហើយនៅឆ្នាំទី៦-១០: SOFR+៣,៧៥% ឬ ៥% ក្នុងមួយឆ្នាំ** |
| ក្រុមហ៊ុន ហ្គោលដេន ទ្រី | សញ្ញាប័ណ្ណបៃតង ហ្គោលដេន ទ្រី | ៧% | |
| សាលាអន្តរជាតិ ស៊ីអាយអេ ហ្វឺស | សញ្ញាប័ណ្ណមានបុគ្គលធានា ស៊ីអាយអេ ហ្វឺស ១ | ៦,៣% | |
| ក្រុមហ៊ុន ខេម ជីអេសអេម | សញ្ញាប័ណ្ណនិរន្តរភាព ខេម ជីអេសអេម | | SOFR + ៣% ឬ ៥,៥% ក្នុងមួយឆ្នាំ** |

ប្រភព៖ ផ្សារមូលបត្រកម្ពុជា

សម្គាល់៖ * SOFR សំដៅលើ Secured Overnight Financing Rate និង ** យកអត្រាណាដែលខ្ពស់ជាង

## ៣.២ វិស័យធានារ៉ាប់រង

ទ្រព្យសកម្មសរុបនៃវិស័យធានារ៉ាប់រងមានកំណើនខ្ពស់ **ទោះជាបុព្វលាភធានារ៉ាប់រងបានថមថយកំណើនក៏ដោយ។** ទ្រព្យសកម្មសរុបនៃវិស័យធានារ៉ាប់រងបានកើនឡើង ១០,៦% ដល់ជាង ៤,៤ ទ្រីលានរៀល (១,១ ប៊ីលានដុល្លារអាមេរិក) (ក្រាហ្វ ៣.៧)។ លើសពីនេះ ចំនួនកិច្ចសន្យាធានារ៉ាប់រងបានកើនឡើង ២,៩% ដល់ ១,៣ លានកិច្ចសន្យា។ ចំណែកឯអនុបាតការផ្តល់សំណងបានថយចុះបន្តិចពី ១៤% នៅឆ្នាំ២០២២ មកត្រឹម ១៣,៦%។

**៣.៧ ទ្រព្យសកម្មសរុបនៃវិស័យធានារ៉ាប់រង**

(ឆ្នាំ២០១៩ - ២០២៣)




ប្រភព៖ និយ័តករធានារ៉ាប់រងកម្ពុជា

**បុព្វលាភធានារ៉ាប់រងសរុបបានថមថយកំណើនដោយសារបុព្វលាភធានារ៉ាប់រងអាយុជីវិតបានធ្លាក់ចុះបន្តិច។** បុព្វលាភធានារ៉ាប់រងសរុបបានថយចុះពី ១០,៧% នៅឆ្នាំ២០២២ មកត្រឹម ២,៣% នៅឆ្នាំ២០២៣ ដែលមានចំនួនសរុបជិត ១,៤ ទ្រីលានរៀល (៣៣៩,៦ លានដុល្លារអាមេរិក) (ក្រាហ្វ ៣.៨)។ កំណើនយឺតនេះជាចម្បងបណ្តាលមកពីការធ្លាក់ចុះនៃបុព្វលាភធានារ៉ាប់រងអាយុជីវិត ខណៈដែលបុព្វលាភធានារ៉ាប់រងទូទៅ និងធានារ៉ាប់រងខ្នាតតូច បន្តកើនឡើង។ បុព្វលាភធានារ៉ាប់រងអាយុជីវិតមានសមាមាត្រ ៥៥,៩% បន្ទាប់មកធានារ៉ាប់រងទូទៅ ៤២% និងធានារ៉ាប់រងខ្នាតតូច ២,១%។

**៣.៨ បុព្វលាភធានារ៉ាប់រងសរុប**

(ឆ្នាំ២០១៩ - ២០២៣)




ប្រភព៖ និយ័តករធានារ៉ាប់រងកម្ពុជា

បុព្វលាភធានារ៉ាប់រងអាយុជីវិតបានថយចុះបន្តិច ២,១% មក ៧៧៩,៨ ប៊ីលានរៀល (១៨៩,៧

លានដុល្លារអាមេរិក) ដែលរួមចំណែកជាចម្បងដោយកិច្ចសន្យាទាយជ្ជទាន (រួមចំណែក -២,៨ ពិន្ទុភាគរយនៃកំណើនសរុប) និងធានារ៉ាប់រងអាយុជីវិតផ្សេងៗ (-០,៣ ពិន្ទុភាគរយ)។ កិច្ចសន្យាទាយជ្ជទានមានចំណែកធំជាងគេនៃបុព្វលាភធានារ៉ាប់រងអាយុជីវិតសរុប ដែលស្មើនឹង ៧៨,៧% បន្ទាប់មកគឺធានារ៉ាប់រងអាយុជីវិតមានកាលកំណត់ (២០,៧%) (ក្រាហ្វ ៣.៩)។ លើសពីនេះ ចំនួនកិច្ចសន្យាធានារ៉ាប់រងអាយុជីវិតបានកើនឡើង ៧,៤% ពី ៥៣៥.៨៧១ ដល់ ៥៧៥.៦៥៣ កិច្ចសន្យា។ ចំណែកឯអនុបាតការផ្តល់សំណងបានថយចុះបន្តិចពី ៧,៣% នៅឆ្នាំ២០២២ មក ៧% ដោយការផ្តល់សំណងសរុបនៃធានារ៉ាប់រងអាយុជីវិតបានថយចុះ ៥,៨% មកត្រឹម ៥៥ ប៊ីលានរៀល (១៣,៤ លានដុល្លារអាមេរិក)។

បុព្វលាភដុលធានារ៉ាប់រងទូទៅបានកើនឡើង ៧,៩% ដល់ ៥៨៦,៧ ប៊ីលានរៀល (១៤២,៨ លានដុល្លារអាមេរិក) ដែលគាំទ្រជាចម្បងដោយធានារ៉ាប់រងទ្រព្យសម្បត្តិឬអគ្គិភ័យ (រួមចំណែក ២,៧ ពិន្ទុភាគរយនៃកំណើនសរុប) និងធានារ៉ាប់រងយានយន្ត (២,៦ ពិន្ទុភាគរយ)។ ធានារ៉ាប់រងទ្រព្យសម្បត្តិឬអគ្គិភ័យមានចំណែកធំជាងគេនៅក្នុងបុព្វលាភធានារ៉ាប់រងទូទៅ ដែលស្មើនឹង ៣៤,២% បន្ទាប់មកគឺធានារ៉ាប់រងសុខភាព (២២,១%) និងធានារ៉ាប់រងយានយន្ត (១៦,៨%) (ក្រាហ្វ ៣.១០)។ អនុបាតការផ្តល់សំណងបានថយចុះពី ២៣,៨% នៅឆ្នាំ២០២២ មកត្រឹម ២២,៣% ខណៈការផ្តល់សំណងសរុបនៃធានារ៉ាប់រងទូទៅកើនឡើងបន្តិច ០,៩% ដល់ ១៣០,៦ ប៊ីលានរៀល (៣១,៨ លានដុល្លារអាមេរិក)។

បុព្វលាភដុលធានារ៉ាប់រងខ្នាតតូចបន្តកើនឡើងខ្ពស់ ២៤,៧% ដល់ ២៩,៣ ប៊ីលានរៀល (៧,១ លានដុល្លារអាមេរិក) ដែលគាំទ្រជាចម្បងដោយធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល។ ផលិតផលធានារ៉ាប់រងខ្នាតតូចរួមមានធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល (៤៣,៨% នៃធានារ៉ាប់រងខ្នាតតូចសរុប) ធានារ៉ាប់រងអាយុជីវិតមានកាលកំណត់ (១៤,៣%) ធានារ៉ាប់រងសុខភាព (១១,៦%) និងធានារ៉ាប់រងផ្សេងៗ (៣០,៣%) (ក្រាហ្វ ៣.១១)។ អនុបាតការផ្តល់

**៣.៩ សមាសធាតុបុព្វលាភធានារ៉ាប់រងអាយុជីវិត**
(ឆ្នាំ២០២៣)




ប្រភព៖ និយ័តករធានារ៉ាប់រងកម្ពុជា

**៣.១០ សមាសធាតុបុព្វលាភធានារ៉ាប់រងទូទៅ**
(ឆ្នាំ២០២៣)




ប្រភព៖ និយ័តករធានារ៉ាប់រងកម្ពុជា

**៣.១១ សមាសធាតុបុព្វលាភធានារ៉ាប់រងខ្នាតតូច**
(ឆ្នាំ២០២៣)




ប្រភព៖ និយ័តករធានារ៉ាប់រងកម្ពុជា

សំណាងមានកម្រិត ១៥,៥% ហើយការផ្តល់សំណាងសរុបនៃធានារ៉ាប់រងខ្នាតតូចបានកើនឡើង ២១,១% ដល់ ៤,៥ ប៊ីលានរៀល (១,១ លានដុល្លារអាមេរិក)។

## ៣.៣ សេចក្តីសន្និដ្ឋាន

វិស័យហិរញ្ញវត្ថុមិនមែនធនាគារបន្តរីកចម្រើនជាលំដាប់ ដោយបានរួមចំណែកអភិវឌ្ឍវិស័យហិរញ្ញវត្ថុឱ្យកាន់តែមានពិពិធកម្ម និងមានភាពទូលំទូលាយ។ ទាំងទីផ្សារមូលបត្រកម្មសិទ្ធិនិងបំណុល បានទាក់ទាញការចុះបញ្ជីកាន់តែច្រើនពីក្រុមហ៊ុនក្នុងវិស័យផ្សេងៗ ដើម្បីស្វែងរកប្រភពហិរញ្ញប្បទានក្រៅពីឥណទានធនាគារ។ លើសពីនេះ ទ្រព្យសកម្មសរុបនៃវិស័យធានារ៉ាប់រងបានបង្ហាញពីកំណើនល្អ ទោះជាបុព្វលាភធានារ៉ាប់រងបានថមថយកំណើន។ ជាមួយគ្នានេះ កិច្ចខិតខំប្រឹងប្រែងក្នុងការប្រមូល និងចែករំលែកទិន្នន័យគឺជាការចាំបាច់ ដើម្បីកែលម្អក្របខ័ណ្ឌត្រួតពិនិត្យសម្រាប់ទប់ស្កាត់ឱ្យបានល្អប្រសើរនូវហានិភ័យនានាដែលអាចរាលដាលទៅដល់ប្រព័ន្ធហិរញ្ញវត្ថុទាំងមូល។ ក្នុងន័យនេះ ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរពាក់ព័ន្ធ នឹងបន្តធានាស្ថិរភាពនិងភាពធន់នៃការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជា។

# IV ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់

*ធនាគារជាតិនៃកម្ពុជាបាននិងកំពុងចាប់យកឱកាសពីការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីអភិវឌ្ឍ និងធ្វើទំនើបកម្មប្រព័ន្ធទូទាត់ ស្របតាមយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល។ ការប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិកបានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលឆ្លុះបញ្ចាំងពីកំណើននៃការប្រើប្រាស់ និងជំនឿទុកចិត្តរបស់សាធារណជន។ ជាក់ស្តែង ចំនួនគណនីកាបូបអេឡិចត្រូនិកបានឡើងដល់ ១៩,៧ លាន ហើយតម្លៃនៃការទូទាត់តាមឌីជីថលបានកើនដល់ជិត ១២ដងនៃផលិតផលក្នុងស្រុកសរុប។ លើសពីនេះ ប្រតិបត្តិការទូទាត់តាមរយៈប្រព័ន្ធបាគង និងឃ្យូអរកូត បានកើនឡើងគួរឱ្យកត់សម្គាល់ ព្រមទាំងបានរួមចំណែកលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលផងដែរ។ ធនាគារជាតិនៃកម្ពុជាបានតភ្ជាប់ប្រព័ន្ធទូទាត់ឆ្លងដែនជាមួយប្រទេសដៃគូ និងក្រុមហ៊ុនផ្តល់សេវាទូទាត់អន្តរជាតិក្នុងតំបន់ជាបន្តបន្ទាប់ ក្នុងគោលបំណងរួមចំណែកជំរុញសមាហរណកម្មសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុក្នុងស្រុកនៅក្នុងតំបន់។*

ស្របតាមការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ និងសេដ្ឋកិច្ចឌីជីថល ធនាគារជាតិនៃកម្ពុជាបានលើកកម្ពស់នវានុវត្តន៍ក្នុងសេវាកម្មហិរញ្ញវត្ថុឌីជីថល ដើម្បីកាត់បន្ថយចំណាយ ជំរុញអន្តរប្រតិបត្តិការ និងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។ ប្រព័ន្ធទូទាត់និងផាត់ទាត់ត្រូវបានអភិវឌ្ឍជាបន្តបន្ទាប់ក្នុងមួយទសវត្សរ៍ចុងក្រោយនេះ ទាំងសម្រាប់ការទូទាត់រាយ និងតម្លៃធំ ដើម្បីគាំទ្រដល់សេវាហិរញ្ញវត្ថុ ឌីជីថលដែលកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស រួមមានប្រព័ន្ធផាត់ទាត់ជាតិ (NCS) ប្រព័ន្ធធនាគារអនឡាញ (OBS) ប្រព័ន្ធសេវាទូទាត់រហ័ស (FAST) ប្រព័ន្ធរីថៃលផេ ប្រព័ន្ធបាគង ស្តង់ដារខេអេចឃ្យូអរកូត និងប្រព័ន្ធខេមបូឌានស៊ែស្វីច (CSS) (ក្រាហ្វ ៤.១)។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់តម្លៃធំបាគង ដើម្បីសម្រួលដល់ប្រតិបត្តិការអន្តរធនាគារ និងទីផ្សារហិរញ្ញវត្ថុ។

**៤.១ ប្រព័ន្ធទូទាត់សងប្រាក់របស់ធនាគារជាតិនៃកម្ពុជា**
(ឆ្នាំ២០១២ - ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ការប្រើប្រាស់ប្រព័ន្ធទូទាត់ឌីជីថលបានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយបានក្លាយជាប្រក្រតីកម្មថ្មីនៅក្នុងសេដ្ឋកិច្ច ដែលបង្ហាញពីការទទួលយក និងជំនឿទុកចិត្តរបស់សាធារណជន។ ចំនួនប្រជាជនវ័យក្មេងច្រើន គួបផ្សំនឹងការកើនឡើងយ៉ាងឆាប់រហ័សនៃការប្រើប្រាស់ទូរស័ព្ទចល័ត និងអ៊ីនធឺណិត បានប្រែក្លាយកម្ពុជាពីការពឹងផ្អែកខ្លាំងលើប្រតិបត្តិការសាច់ប្រាក់ ឆ្ពោះទៅរកការទូទាត់ដែលមិនប្រើក្រដាសប្រាក់។ ជាក់ស្តែង ចំនួនប្រតិបត្តិការទូទាត់តាមប្រព័ន្ធឌីជីថល សរុបបានកើនឡើង ៥៩,៨% ដល់ ១,៨ ប៊ីលានប្រតិបត្តិការ នៅឆ្នាំ២០២៣ ហើយទំហំនៃការទូទាត់តាមប្រព័ន្ធឌីជីថលបានកើនដល់ ២.០២១,៣ ទ្រីលានរៀល (៤៩១,៨ ប៊ីលានដុល្លារអាមេរិក) ដែលបានកើនឡើង ២៤,២% ស្មើនឹងជិត ១២ដងនៃផ.ស.ស. (ក្រាហ្វ ៩.២)។

៩.២ ទំហំទឹកប្រាក់នៃការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក
(ឆ្នាំ២០១៩ - ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជាពិសេស គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ក៏បានធ្វើទំនើបកម្មសេវាទូទាត់ឌីជីថល ដើម្បីគាំទ្រដល់កំណើនតម្រូវការរបស់អតិថិជន ព្រមទាំងអនុញ្ញាតឱ្យប្រជាជនកាន់តែច្រើនអាចទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ។ អតិថិជនកាន់តែច្រើន រួមទាំងប្រជាជននៅតំបន់ជនបទ អាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុផ្សេងៗនៅលើទូរស័ព្ទចល័ត ដូចជាការផ្ទេរប្រាក់ ការទូទាត់វិក្កយបត្រ និងការបញ្ចូលទឹកប្រាក់ក្នុងលេខទូរស័ព្ទ ជាដើម ដោយភាពងាយស្រួល ឆាប់រហ័ស និងសុវត្ថិភាព។ នៅឆ្នាំ ២០២៣ ចំនួនគណនីកាបូបអេឡិចត្រូនិកបានកើនឡើងដល់ ១៩,៧ លានគណនី ក្នុងនោះ ១០,២ លានគណនី ចុះឈ្មោះនៅតាមគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ និង ៩,៥ លានគណនីបានចុះឈ្មោះនៅគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ (ក្រាហ្វ ៩.៣)។ ទំហំសរុបនៃការទូទាត់

៩.៣ ចំនួនគណនីកាបូបអេឡិចត្រូនិក
(ឆ្នាំ២០១៩ - ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ដោយប្រើគណនី កាបូបអេឡិចត្រូនិក បានកើនឡើង ៧៦,៤% ដល់ ៤៥៨,៩ ទ្រីលានរៀល (១១១,៧ ប៊ីលានដុល្លារអាមេរិក) ហើយចំនួនប្រតិបត្តិការបានកើនឡើង ៧៣,៥% ដល់ ៨១១ លានប្រតិបត្តិការ (ក្រាហ្វ ៤.៤)។

**ការប្រើប្រាស់សេវាធនាគារចល័តបានបង្កើនល្បឿនជាលំដាប់ ខណៈដែលទំហំនៃសេវាធនាគារអ៊ីនធឺណិតបានធ្លាក់ចុះបន្តិច។** កំណើននៃការប្រើប្រាស់ទូរស័ព្ទចល័ត និងអ៊ីនធឺណិតគួបផ្សំនឹងការផ្តល់សេវាហិរញ្ញវត្ថុឌីជីថលដែលមានភាពងាយស្រួល បានអនុញ្ញាតឱ្យអតិថិជនកាន់តែច្រើនអាចធ្វើប្រតិបត្តិការធនាគារឌីជីថលយ៉ាងទូលំទូលាយ ដូចជា ការទូទាត់សងឥណទាន ការផ្ទេរប្រាក់ ការទូទាត់វិក្កយបត្រ ការបញ្ចូលទឹកប្រាក់ក្នុងលេខទូរស័ព្ទ ការបើកប្រាក់បៀវត្សរ៍ ការពិនិត្យសមតុល្យ ជាដើម។ ខណៈដែលទំហំនៃសេវាធនាគារអ៊ីនធឺណិតបានធ្លាក់ចុះ -៧% មកត្រឹម ៧៤,៥ ទ្រីលានរៀល (១៨,១ ប៊ីលានដុល្លារអាមេរិក) ចំនួនប្រតិបត្តិការបានកើនឡើងដល់ ៤,៧ លានប្រតិបត្តិការ។ ទន្ទឹមនេះ ទំហំនៃការទូទាត់តាមសេវាធនាគារចល័តបានកើនឡើង ១១% ដល់ ៧៤៦,៧ ទ្រីលានរៀល (១៨១,៧ ប៊ីលានដុល្លារអាមេរិក) និងចំនួនប្រតិបត្តិការធនាគារចល័តបានកើនឡើងដល់ ៧៧៩,៤ លានប្រតិបត្តិការ (ក្រាហ្វ ៤.៥)។

**ការប្រើប្រាស់ប័ណ្ណទូទាត់បានកើនឡើងជាលំដាប់ ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃទំហំប្រតិបត្តិការ និងចំនួនប័ណ្ណទូទាត់ដែលបានចេញផ្សាយ។** ចំនួនប័ណ្ណទូទាត់ដែលកំពុងចរាចរបានកើន ៦% ដល់ ១៣,១ លានប័ណ្ណ ដែលរួមមានប័ណ្ណបង់ប្រាក់មុន (Prepaid) ចំនួន ៧,១ លាន ប័ណ្ណទូទាត់ក្នុងស្រុក (Proprietary) ៣,២ លាន ប័ណ្ណឥណពន្ធ (Debit) ២,៥ លាន

៤.៤ ទំហំនិងទឹកប្រាក់នៃប្រតិបត្តិការតាមកាបូបអេឡិចត្រូនិក




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

៤.៥ ទំហំទឹកប្រាក់នៃប្រតិបត្តិការសេវាធនាគារអ៊ីនធឺណិត និងសេវាធនាគារចល័ត




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

និងប័ណ្ណឥណទាន (Credit) ០,២ លាន។ លើសពីនេះ ចំនួនប្រតិបត្តិការនៃការប្រើប្រាស់ប័ណ្ណទូទាត់ បានកើនឡើង ៥១,៥% ដល់ ១៩១,៥ លានប្រតិបត្តិការ ដោយមានទំហំទឹកប្រាក់សរុប ១២៩,២ ទ្រីលានរៀល (៣១,៤ ប៊ីលានដុល្លារអាមេរិក) ដែលក្នុងនោះ ប្រាក់រៀលមានសមាមាត្រ ៤២,៧% (ក្រាហ្វ ៤.៦)។

ការទូទាត់តាមឃ្យូអរកូតមានភាពពេញនិយមគួរឱ្យកត់សម្គាល់ ចាប់តាំងពីការដាក់ឱ្យប្រើប្រាស់ស្តង់ដារខេអេចឃ្យូអរកូតជាផ្លូវការនៅខែកក្កដា ឆ្នាំ២០២២ ដែលបានជួយសម្រួលដល់អន្តរប្រតិបត្តិការរវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងបានជំរុញការតភ្ជាប់ការទូទាត់ឆ្លងដែននៅក្នុងតំបន់។ ទំហំនៃការទូទាត់តាមឃ្យូអរកូត បានកើនឡើង ៧ដង ដល់ ៩៥,៨ ទ្រីលានរៀល (២៣,៣ ប៊ីលានដុល្លារអាមេរិក) ដែលក្នុងនោះ ប្រាក់រៀលមានសមាមាត្រប្រមាណមួយភាគបី (ក្រាហ្វ ៤.៧)។ ចំនួនប្រតិបត្តិការទូទាត់តាម ឃ្យូអរកូត ក៏បានកើនឡើង ៧,៦ដង ដល់ ១៧៨ លានប្រតិបត្តិការ ហើយការទូទាត់ជាប្រាក់រៀលមានសមាមាត្រ ៤៨,៤% ដែលបានបង្ហាញពីការរួមចំណែកលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ។

**ប្រព័ន្ធបាគងបានបង្កើនប្រសិទ្ធភាពនៅក្នុងប្រព័ន្ធទូទាត់ សម្រួលដល់អន្តរប្រតិបត្តិការរវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។** គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៧៤ បានក្លាយជាសមាជិកនៃប្រព័ន្ធទូទាត់កន្លែងនេះ ដែលក្នុងនោះ គ្រឹះស្ថានចំនួន ៥៨ បានដាក់ឱ្យដំណើរការដោយជោគជ័យ និងសមាជិក ១៦ ផ្សេងទៀតកំពុងធ្វើសន្ទានកម្មជាមួយប្រព័ន្ធបាគង។ លើសពីនេះ ចំនួនគណនីបាគងបានកើនឡើងដល់ ៦០០.៦៣៦ គណនី ហើយអតិថិជនជាច្រើនអាចប្រើប្រាស់ប្រព័ន្ធ

**៤.៦ ទំហំនិងចំនួនប្រតិបត្តិការនៃការទូទាត់ដោយប្រើប្រាស់ប័ណ្ណទូទាត់**
(ឆ្នាំ២០១៩ - ២០២៣)




**៤.៧ ទំហំនិងចំនួនប្រតិបត្តិការនៃការទូទាត់តាមឃ្យូអរកូត**
(ឆ្នាំ២០១៩ - ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

នេះដោយប្រយោលតាមរយៈកម្មវិធីទូរស័ព្ទចល័តរបស់គ្រឹះស្ថានជាសមាជិក។ នៅឆ្នាំ២០២៣ ទំហំទឹកប្រាក់សរុបនៃការទូទាត់តាមរយៈប្រព័ន្ធបាគងបានកើន ២,៧ដង ដល់ ៣០២ ទ្រីលានរៀល (៧៨,៥ ប៊ីលានដុល្លារអាមេរិក) ដែលក្នុងនោះ ប្រាក់រៀលមានសមាមាត្រ ២៦,៨% (ក្រាហ្វ ៤.៨)។ ជាមួយគ្នានេះ ចំនួនប្រតិបត្តិការនៃការទូទាត់តាមប្រព័ន្ធបាគងបានកើន ៥ដង ដល់ ២០០,៩ លានប្រតិបត្តិការ ហើយប្រាក់រៀលមានសមាមាត្រ ៣៤,២%។

**ការតភ្ជាប់ការទូទាត់ឆ្លងដែនជាមួយប្រទេសផ្សេងៗក្នុងតំបន់ និងក្រុមហ៊ុនផ្តល់សេវាទូទាត់អន្តរជាតិនានា ត្រូវបានលើកកម្ពស់យ៉ាងសកម្ម ដើម្បីរួមចំណែកដល់ការលើកកម្ពស់សកម្មភាពពាណិជ្ជកម្ម ការវិនិយោគ ទេសចរណ៍ និងការផ្ទេរប្រាក់ ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យកាន់តែស៊ីជម្រៅ និងលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុក្នុងស្រុក។** ធនាគារជាតិនៃកម្ពុជាបានតភ្ជាប់ប្រព័ន្ធទូទាត់ឆ្លងដែនដោយជោគជ័យជាមួយបណ្តាប្រទេសក្នុងតំបន់ និងច្រកទ្វារទូទាត់អន្តរជាតិមួយចំនួន រួមមានប្រទេសថៃ ឡាវ វៀតណាម និងក្រុមហ៊ុន UnionPay International ហើយកំពុងពង្រីកការតភ្ជាប់ការទូទាត់ឆ្លងដែនជាមួយប្រទេសជាដៃគូផ្សេងទៀត ដូចជា ឥណ្ឌា ចិន ជប៉ុន សិង្ហបុរី ម៉ាឡេស៊ី ឥណ្ឌូនេស៊ី និងក្រុមហ៊ុន Alipay។

**សរុបមក ការប្រើប្រាស់ប្រព័ន្ធទូទាត់ឌីជីថលបានកើនឡើងយ៉ាងឆាប់រហ័ស ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល ស្របតាមយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល។** ក្នុងទិសដៅនេះ ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុនិងឌីជីថល មានសារៈសំខាន់ក្នុងការជំរុញការ

៤.៨ **ទំហំនិងចំនួនប្រតិបត្តិការនៃការទូទាត់តាមប្រព័ន្ធបាគង**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ប្រើប្រាស់សេវាហិរញ្ញវត្ថុឌីជីថលប្រកបដោយប្រសិទ្ធភាព។ យុទ្ធនាការនិងកម្មវិធីផ្សព្វផ្សាយជាច្រើនត្រូវបានរៀបចំឡើងទាំងនៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្ត ក៏ដូចជាតាមរយៈបណ្ដាញសង្គមនានា ដើម្បីលើកកម្ពស់ការយល់ដឹងរបស់សាធារណជន អំពីសុវត្ថិភាពនៃការប្រើប្រាស់សេវាហិរញ្ញវត្ថុឌីជីថល ជាពិសេសក្នុងចំណោមប្រជាជនវ័យក្មេងដែលមានទំនោរប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុឌីជីថល។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏បានបន្តយកចិត្តទុកដាក់លើការពង្រឹងសន្តិសុខសាយប័រ ការគ្រប់គ្រងហានិភ័យប្រតិបត្តិការ និងការលើកកម្ពស់កិច្ចការពារអតិថិជន ដើម្បីរក្សាជំនឿទុកចិត្តសាធារណជន និងរួមចំណែកធានាបាននូវស្ថិរភាពហិរញ្ញវត្ថុ។

## ឧបសម្ព័ន្ធទី១

### តារាងទី១៖ ជញ្ជីងទូទាត់កម្ពុជា

(ភាគរយនៃផ.ស.ស., ឆ្នាំ២០១៨-២០២៣)

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| សមតុល្យជញ្ជីងទូទាត់ | ៤,៤ | ៧,៣ | ១,៨ | ០,២ | ០,៩ | -០,៤ |
| គណនីហិរញ្ញវត្ថុ | ១២,២ | ១៤,៣ | ៣,៦ | ២៩,៣ | ១៩,៤ | ២,០ |
| គណនីចរន្ត និងដើមទុន | -៧,៨ | -៧,០ | -១,៨ | -២,៩ | -១៨,៥ | ១,៦ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### តារាងទី២៖ លំហូរវិនិយោគផ្ទាល់បរទេសតាមវិស័យ

(ឆ្នាំ២០១៨-២០២៣)

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| លំហូរវិនិយោគផ្ទាល់បរទេស (ប៊ីលានដុល្លារអាមេរិក) | ៣,២ | ៣,៧ | ៣,៦ | ៣,៥ | ៣,៦ | ៤,០ |
| កសិកម្ម | ០,២ | ០,២ | ០,២ | ០,១ | ០,១ | ០,១ |
| អាជីវកម្មធនធានរ៉ែ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| កម្មន្តសាល | ០,៤ | ០,៦ | ០,៦ | ០,៧ | ០,៨ | ១,៤ |
| ហិរញ្ញវត្ថុ | ១,១ | ១,២ | ១,៤ | ១,៣ | ១,១ | ០,៩ |
| ការស្នាក់នៅ | ០,៤ | ០,៥ | ០,៤ | ០,២ | ០,២ | ០,២ |
| ទូរគមនាគមន៍ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| សំណង់និងអចលនទ្រព្យ | ០,៦ | ០,៧ | ០,៦ | ០,៦ | ០,៨ | ០,៩ |
| ផ្សេងៗ | ០,៤ | ០,៤ | ០,៤ | ០,៤ | ០,៥ | ០,៤ |
| កំណើនសរុប (ភាគរយ) | ១៥,២ | ១៤,០ | -១,០ | -៣,៩ | ២,៧ | ១០,៦ |

ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

### តារាងទី៣៖ អត្រាប្តូរប្រាក់

(ឆ្នាំ២០១៨-២០២៣)

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាម (NEER) | ៩៩,៤ | ៩៨,៣ | ៩៩,៦ | ១០១,៨ | ៩៨,៥ | ៩៥,៥៧ |
| អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិត (REER) | ៩៦,១ | ៩៧,០ | ៩៦,៧ | ៩៧,៧ | ៩៤,៤ | ៩២,៧ |
| ប្រាក់រៀលធៀបនឹងដុល្លារអាមេរិក | ៤.០៥១ | ៤.០៦១ | ៤.០៩៣ | ៤.០៩៩ | ៤.១០២ | ៤.១១១ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី៤៖ ទុនបម្រុងអន្តរជាតិ

(ឆ្នាំ២០១៨-២០២៣)

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| ទុនបម្រុងអន្តរជាតិ (ប៊ីលានដុល្លារអាមេរិក) | ១៤,៦ | ១៨,៨ | ២១,៣ | ២០,៣ | ១៧,៨ | ២០,០ |
| ចំនួនខែនៃការនាំចូលទំនិញនិងសេវា | ៦,៩ | ៩,៨ | ៧,៨ | ៧,០ | ៧,៣ | ៧,១ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី៥៖ កំណើនសេដ្ឋកិច្ចតាមវិស័យចម្បងៗ

(ភាគរយ, ឆ្នាំ២០១៨-២០២៣ប)

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ប |
|---|---|---|---|---|---|---|
| កសិកម្ម | ១,១ | -០,៤ | ០,៦ | ១,៥ | ០,៦ | ១,០ |
| កម្មន្តសាល | ១២,២ | ១០,៥ | -០,៨ | ១៤,៩ | ១០,៦ | ៧,២ |
| សំណង់ និងអចលនទ្រព្យ | ១៨,៣ | ១៥,៧ | -៧,៨ | -៨,២ | ០,៨ | ០,៨ |
| ពាណិជ្ជកម្ម ការស្នាក់នៅ និងអាហារ | ៦,៤ | ៥,៦ | -១៦,៩ | -១០,២ | ៨,០ | ១០,៨ |
| ការដឹកជញ្ជូន និងគមនាគមន៍ | ៧,៦ | ៨,៧ | ០,៩ | ៦,១ | ៥,៩ | ១០,២ |
| ហិរញ្ញវត្ថុ និងធានារ៉ាប់រង | ៨,០ | ៧,៩ | ៤,៣ | ៣,២ | -១,០ | ០,៣ |
| ផ្សេងៗ | ៧,៧ | ៧,៩ | ១,៥ | ៦,៥ | ៣,៤ | ៤,០ |
| កំណើន ផ.ស.ស.ពិត | ៨,៨ | ៧,៩ | -៣,៦ | ៣,១ | ៥,១ | ៥,០ |

ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

## តារាងទី៦៖ ការរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចតាមវិស័យចម្បងៗ

(ភាគរយ, ឆ្នាំ២០១៨-២០២៣ប)

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ប |
|---|---|---|---|---|---|---|
| កសិកម្ម | ០,២ | -០,១ | ០,១ | ០,៣ | ០,១ | ០,១ |
| កម្មន្តសាល | ២,៨ | ២,៥ | -០,២ | ៣,៧ | ៣,០ | ២,១ |
| សំណង់ និងអចលនទ្រព្យ | ២,៥ | ២,៣ | -១,២ | -១,២ | ០,១ | ០,១ |
| ពាណិជ្ជកម្ម ការស្នាក់នៅ និងអាហារ | ១,១ | ០,៩ | -២,៧ | -១,៤ | ១,០ | ១,៣ |
| ការដឹកជញ្ជូន និងគមនាគមន៍ | ០,៣ | ០,៤ | ០,០ | ០,៣ | ០,៣ | ០,៥ |
| ហិរញ្ញវត្ថុ និងធានារ៉ាប់រង | ០,៣ | ០,៣ | ០,២ | ០,១ | ០,០ | ០,០ |
| ផ្សេងៗ | ១,៥ | ១,៥ | ០,៣ | ១,៣ | ០,៧ | ០,៨ |
| កំណើន ផ.ស.ស.ពិត | ៨,៨ | ៧,៩ | -៣,៦ | ៣,១ | ៥,១ | ៥,០ |

ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

## តារាងទី៧៖ ចំនួនភ្ញៀវអន្តរជាតិបែងចែកតាមគោលបំណង

(លាននាក់, ឆ្នាំ២០១៨-២០២៣)

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| កម្សាន្ត | ៥,៣ | ៥,០ | ១,០ | ០,១ | ១,៨ | ៤,៣ |
| ធុរកិច្ច និងការងារ | ០,៧ | ១,៤ | ០,៣ | ០,១ | ០,៤ | ១,០ |
| ផ្សេងៗ | ០,២ | ០,២ | ០,១ | ០,០ | ០,១ | ០,១ |
| ចំនួនភ្ញៀវអន្តរជាតិសរុប | ៦,២ | ៦,៦ | ១,៣ | ០,២ | ២,៣ | ៥,៥ |
| កំណើនភ្ញៀវអន្តរជាតិ (ភាគរយ, ឆ្នាំលើឆ្នាំ) | ១០,៧ | ៦,៦ | -៨០,២ | -៨៥,០ | ១.០៥៨,៦ | ១៣៩,៥ |

ប្រភព៖ ក្រសួងទេសចរណ៍

## តារាងទី៨៖ ទេសចរក្នុងស្រុក

(លាននាក់, ឆ្នាំ២០១៨-២០២៣)

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| រាជធានីភ្នំពេញ | ២,៤ | ២,៤ | ១,៨ | ១,២ | ២,៤ | ៦,៦ |
| ខេត្តសៀមរាប | ៣,២ | ២,១ | ០,៧ | ០,៤ | ២,៤ | ១,៧ |
| តំបន់ឆ្នេរ | ៣,៣ | ៣,២ | ២,៩ | ២,១ | ៧,១ | ៨,៣ |
| តំបន់អេកូទេសចរណ៍ | ០,៦ | ០,៧ | ០,៦ | ០,៤ | ០,៧ | ០,៥ |
| ចំនួនទេសចរក្នុងស្រុកសរុប | ១១,១ | ១១,៣ | ៧,២ | ៤,៧ | ១៣,៩ | ១៨,៧ |
| កំណើនទេសចរក្នុងស្រុក (ភាគរយ, ឆ្នាំលើឆ្នាំ) | ១,៨ | ២,៣ | -៣៦,១ | -៣៥,៥ | ១៩៨,៨ | ៣៤,៥ |

ប្រភព៖ ក្រសួងទេសចរណ៍

## តារាងទី៩៖ សន្ទស្សន៍ថ្លៃលំនៅដ្ឋាន

(ឆ្នាំ២០២២-២០២៣)

| ២០២២ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| សន្ទស្សន៍ថ្លៃរួម | ១១៣,៨ | ១១១,៩ | ១១១,២ | ១០៩,៤ | ១០៨,៦ | ១០៩,០ | ១១១,៩ | ១១៣,៥ | ១១៤,៦ | ១១៥,១ | ១១៤,៧ | ១១៤,៨ |
| រាជធានីភ្នំពេញ | ១១៤,៨ | ១១៣,៩ | ១១៣,៣ | ១១១,១ | ១០៩,៨ | ១១០,៤ | ១១៣,៦ | ១១៥,៤ | ១១៦,៥ | ១១៦,៨ | ១១៦,០ | ១១៦,០ |
| បណ្ដាខេត្តផ្សេងទៀត | ១០៨,២ | ៩៩,៥ | ៩៧,៩ | ៩៨,៩ | ១០០,៤ | ១០០,៣ | ១០១,១ | ១០២,១ | ១០២,៤ | ១០៤,០ | ១០៧,០ | ១០៧,៦ |

| ២០២៣ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| សន្ទស្សន៍ថ្លៃរួម | ១១៣,៨ | ១១៣,១ | ១១៣,០ | ១១៤,១ | ១១៥,៦ | ១១៦,១ | ១១៥,០ | ១១៤,៨ | ១១៤,១ | ១១៣,១ | ១១១,៩ | ១១១,៥ |
| រាជធានីភ្នំពេញ | ១១៤,៨ | ១១៤,៦ | ១១៤,៧ | ១១៦,២ | ១១៧,៥ | ១១៧,៥ | ១១៥,៩ | ១១៥,៩ | ១១៥,២ | ១១៣,៨ | ១១២,២ | ១១១,៤ |
| បណ្តាខេត្តផ្សេងទៀត | ១០៨,២ | ១០៤,៩ | ១០៤,១ | ១០៣,១ | ១០៥,៧ | ១០៩,៣ | ១១០,៤ | ១០៨,៩ | ១០៨,៤ | ១០៩,៧ | ១១០,៤ | ១១១,៥ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី១០៖ ការរួមចំណែកក្នុងអតិផរណា

(ការប្រែប្រួលប្រចាំឆ្នាំគិតជាភាគរយ, ឆ្នាំ២០១៨-២០២៣)

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| អតិផរណា | ២,៥ | ១,៩ | ២,៩ | ២,៩ | ៥,៤ | ២,១ |
| ក្រុមម្ហូបអាហារ | ១,៣ | ១,១ | ២,៥ | ១,៥ | ២,៧ | ១,៨ |
| ក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ | ០,៤ | -០,១ | -០,៣ | ០,៨ | ១,១ | -០,៣ |
| ក្រុមអតិផរណាស្នូល | ០,៧ | ០,៩ | ០,៧ | ០,៦ | ១,៥ | ០,៧ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី១១៖ ដុល្លារូបនីយកម្មហិរញ្ញវត្ថុ

(ភាគរយ, ឆ្នាំ២០១៨-២០២៣)

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| សមាមាត្រប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងរូបិយវត្ថុទូទៅ | ៨៥,៧ | ៨៤,១ | ៨៣,៩ | ៨៣,០ | ៨៣,០ | ៨៣,៤ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងប្រាក់បញ្ញើសរុប | ៩៤,១ | ៩៣,៥ | ៩៣,១ | ៩១,៤ | ៩០,៤ | ៩០,៣ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ឧបសម្ព័ន្ធទី២

### តារាងទី១២៖ សូចនាករវិស័យធនាគារធៀបនឹងផ.ស.ស.

(ភាគរយ, ឆ្នាំ២០១៨-២០២៣)

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| ទ្រព្យសកម្មធៀបនឹងផ.ស.ស. | ១២៤ | ១៤០ | ១៦៧ | ១៨៧ | ១៩៣ | ១៩៥ |
| ឥណទានធៀបនឹងផ.ស.ស. | ៧៧ | ៨៨ | ១០៧ | ១២៥ | ១៣៧ | ១៣៣ |
| ប្រាក់បញ្ញើធៀបនឹងផ.ស.ស. | ៧៤ | ៨០ | ៩៥ | ១០៦ | ១០៦ | ១១២ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### តារាងទី១៣៖ ឥណទាន និងប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជតាមប្រភេទរូបិយវត្ថុ

(ឆ្នាំ២០១៨-២០២៣)

| ឥណទាន | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| ឥណទានជារៀល (ទ្រីលានរៀល) | ៣,៥ | ១០,៨ | ១៥,០ | ១៨,៣ | ២០,៧ | ២៤,៦ |
| ឥណទានជាដុល្លារអាមេរិក (ទ្រីលានរៀល) | ៧៨,៤ | ៩២,៨ | ១១២,៦ | ១៤២,៥ | ១៦៨,១ | ១៨៤,៣ |
| សមាមាត្រឥណទានជារៀល (ភាគរយ) | ៤,៣ | ១០,៤ | ១១,៨ | ១១,៤ | ១១,០ | ១១,៥ |
| **ឥណទាន** | **២០១៨** | **២០១៩** | **២០២០** | **២០២១** | **២០២២** | **២០២៣** |
| ប្រាក់បញ្ញើជារូបិយវត្ថុជាតិ (ទ្រីលានរៀល) | ៥,៤ | ៧,៥ | ៩,៥ | ១៣,៧ | ១៧,៣ | ២១,៤ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស (ទ្រីលានរៀល) | ៨៣,២ | ៩៦,០ | ១១១,៨ | ១២៩,២ | ១៣៧,៧ | ១៦៦,៦ |
| សមាមាត្រនៃប្រាក់បញ្ញើជារូបិយវត្ថុជាតិ (ភាគរយ) | ៦,១ | ៧,៣ | ៧,៩ | ៩,៦ | ១១,២ | ១១,៤ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### តារាងទី១៤៖ ឥណទានធនាគារពាណិជ្ជទៅតាមវិស័យ - តម្លៃ និងសមាមាត្រ

(ឆ្នាំ២០១៨-២០២៣)

| តម្លៃ (ទ្រីលានរៀល) | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៦,៨ | ៧,១ | ៩,៨ | ១២,៨ | ១៥,៥ | ១៩,២ |
| ឧស្សាហកម្មរ៉ែ | ០,២ | ០,៣ | ០,៥ | ០,៧ | ០,៩ | ១,១ |
| កម្មន្តសាល | ៤,៥ | ៤,៧ | ៥,២ | ៦,៤ | ៨,២ | ៩,៣ |

| | | | | | | |
|---|---|---|---|---|---|---|
| ការផ្គត់ផ្គង់សេវាសាធារណៈ | ០,៦ | ១,០ | ១,៦ | ២,១ | ១,៩ | ២,៤ |
| សំណង់ | ៧,៦ | ១០,០ | ១២,៥ | ១៥,៣ | ១៨,២ | ២០,៨ |
| ការជួញដូរដុំ | ៩,៥ | ១១,៨ | ១២,៧ | ១៥,៤ | ១៨,៦ | ១៩,២ |
| ការជួញដូររាយ | ១៣,៤ | ១៦,២ | ១៩,៨ | ២៥,៩ | ៣០,៨ | ៣៧,១ |
| សណ្ឋាគារ និងភោជនីយដ្ឋាន | ៤,០ | ៤,៧ | ៥,១ | ៧,៣ | ៨,៤ | ៨,៤ |
| ដឹកជញ្ជូន និងស្តុកបណ្តោះអាសន្ន | ១,៧ | ២,១ | ៣,៥ | ៤,៤ | ៥,០ | ៦,១ |
| បណ្តាញព័ត៌មាន និងទូរគមនាគមន៍ | ០,៧ | ០,៩ | ១,១ | ១,២ | ១,០ | ១,១ |
| អាជីវកម្មជួល និងភតិសន្យាប្រតិបត្តិការ | ២,៧ | ៣,៨ | ៣,៦ | ២,៧ | ២,៨ | ២,៨ |
| អចលនទ្រព្យ | ៦,១ | ៨,៧ | ១០,៩ | ១៤,១ | ១៨,១ | ២២,១ |
| សេវាកម្មមិនមែនហិរញ្ញវត្ថុផ្សេងទៀត | ៥,៧ | ៦,៣ | ៦,៨ | ៨,៤ | ១០,០ | ១១,០ |
| ឥណទានបុគ្គល | ៦,៧ | ៨,៤ | ១១,៥ | ១៤,០ | ១៤,២ | ១៩,៦ |
| ឥណទានទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន | ៨,៥ | ១២,១ | ១៧,១ | ២២,៣ | ២៧,៥ | ២៨,២ |
| ឥណទានផ្សេងទៀត | ១,០ | ១,៣ | ១,១ | ២,២ | ២,៦ | ២,៨ |
| សរុប | ៧៩,៨ | ៩៩,៤ | ១២២,៩ | ១៥៥,៤ | ១៨៣,៧ | ២១១,១ |
| **សមាមាត្រ (ភាគរយ)** | **២០១៨** | **២០១៩** | **២០២០** | **២០២១** | **២០២២** | **២០២៣** |
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៨,៦ | ៧,២ | ៨,០ | ៨,៣ | ៨,៥ | ៩,១ |
| ឧស្សាហកម្មរ៉ែ | ០,៣ | ០,៣ | ០,៤ | ០,៤ | ០,៥ | ០,៥ |
| កម្មន្តសាល | ៥,៧ | ៤,៧ | ៤,៣ | ៤,១ | ៤,៥ | ៤,៤ |
| ការផ្គត់ផ្គង់សេវាសាធារណៈ | ០,៧ | ១,០ | ១,៣ | ១,៣ | ១,១ | ១,១ |
| សំណង់ | ៩,៥ | ១០,០ | ១០,២ | ៩,៩ | ៩,៩ | ៩,៨ |
| ការជួញដូរដុំ | ១២,០ | ១១,៩ | ១០,៣ | ៩,៩ | ១០,១ | ៩,១ |
| ការជួញដូររាយ | ១៦,៨ | ១៦,៣ | ១៦,១ | ១៦,៧ | ១៦,៨ | ១៧,៦ |
| សណ្ឋាគារ និងភោជនីយដ្ឋាន | ៥,០ | ៤,៧ | ៤,២ | ៤,៧ | ៤,៦ | ៤,០ |
| ដឹកជញ្ជូន និងស្តុកបណ្តោះអាសន្ន | ២,១ | ២,១ | ២,៨ | ២,៨ | ២,៧ | ២,៩ |
| បណ្តាញព័ត៌មាន និងទូរគមនាគមន៍ | ០,៩ | ០,៩ | ០,៩ | ០,៨ | ០,៦ | ០,៥ |

| | | | | | | |
|---|---|---|---|---|---|---|
| អាជីវកម្មជួល និងភតិសន្យាប្រតិបត្តិការ | ៣,៣ | ៣,៩ | ២,៩ | ១,៧ | ១,៥ | ១,៣ |
| អចលនទ្រព្យ | ៧,៧ | ៨,៧ | ៨,៨ | ៩,១ | ៩,៩ | ១០,៥ |
| សេវាកម្មមិនមែនហិរញ្ញវត្ថុផ្សេងទៀត | ៧,២ | ៦,៤ | ៥,៦ | ៥,៤ | ៥,៥ | ៥,២ |
| ឥណទានបុគ្គល | ៨,៤ | ៨,៥ | ៩,៣ | ៩,០ | ៧,៧ | ៩,៣ |
| ឥណទានទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន | ១០,៦ | ១២,២ | ១៣,៩ | ១៤,៤ | ១៥,០ | ១៣,៤ |
| ឥណទានផ្សេងទៀត | ១,៣ | ១,៣ | ០,៩ | ១,៤ | ១,៤ | ១,៣ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី១៥៖ អនុបាតគ្របខ័ណ្ឌសន្ទនីយភាពរបស់ធនាគារពាណិជ្ជ

(ភាគរយ, ឆ្នាំ២០១៨-២០២៣)

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| កម្រិតអប្បបរមា | ៨០ | ៩០ | ១០០ | ១០០ | ១០០ | ១០០ |
| អនុបាតគ្របខ័ណ្ឌសន្ទនីយភាពជាក់ស្តែង | ១៥៨,៨ | ១៥៥,៧ | ១៦២,៤ | ១៥១,៦ | ១៤៣,៨ | ១៦៦,៦ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី១៦៖ សមាមាត្រប្រភពមូលនិធិធនាគារពាណិជ្ជ

(ភាគរយ, ឆ្នាំ២០១៨-២០២៣)

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| ប្រាក់បញ្ញើចរន្ត | ១៦,៨ | ១៧,១ | ១៥,២ | ១៥,៧ | ១៣,០ | ១១,២ |
| ប្រាក់បញ្ញើសន្សំ | ២៥,០ | ២២,០ | ២១,០ | ១៩,៩ | ១៧,៩ | ១៦,៣ |
| ប្រាក់បញ្ញើមានកាលកំណត់ | ២៨,៤ | ២៨,៨ | ៣០,១ | ២៩,៦ | ៣២,៣ | ៣៧,៧ |
| ផ្សេងៗ | ០,៤ | ០,៣ | ០,២ | ០,២ | ០,៩ | ១,២ |
| កម្ចីរយៈពេលខ្លីជាង១ឆ្នាំ | ៣,២ | ៤,៥ | ៤,៥ | ៤,៤ | ៤,៨ | ៤,០ |
| កម្ចីរយៈពេលវែងជាង១ឆ្នាំ | ៥,៣ | ៥,២ | ៦,៥ | ៧,៤ | ៨,២ | ៧,៧ |
| កម្ចីជាដើមទុនរយៈពេលវែងជាង១ឆ្នាំ | ១,២ | ១,៦ | ១,៦ | ១,៦ | ១,៥ | ១,៣ |
| ដើមទុន | ១៩,៨ | ២០,៤ | ២០,៩ | ២១,២ | ២១,៤ | ២០,៦ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី១៧៖ ប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម និងមូលនិធិភាគទុនិករបស់ធនាគារពាណិជ្ជ

(ភាគរយ, ឆ្នាំ២០១៨-២០២៣)

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| ប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម | ១,៦ | ១,៩ | ១,៦ | ១,៧ | ១,៤ | ០,៦ |
| មូលនិធិភាគទុនិក | ៨,៦ | ១០,២ | ៨,៧ | ៨,៩ | ៧,១ | ៣,៤ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី១៨៖ ភាពគ្រប់គ្រាន់នៃដើមទុនរបស់ធនាគារពាណិជ្ជ

(ភាគរយ, ឆ្នាំ២០១៨-២០២៣)

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| កម្រិតបទប្បញ្ញត្តិ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ១៥ |
| ដើមទុនថ្នាក់ទី១ | ២១,២ | ២០,០ | ២០,២ | ២០,០ | ១៩,៤ | ១៩,៨ |
| អនុបាតសាធនភាព | ២៣,៤ | ២៣,០ | ២៣,២ | ២៣,០ | ២២,២ | ២២,៥ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី១៩៖ ទ្រព្យសកម្មក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

(ឆ្នាំ២០១៨-២០២៣)

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| ចំនួន (ទ្រីលានរៀល) | ២៦,៦ | ៣៥,៩ | ៣៤,៣ | ៣៧,១ | ៤៤,៤ | ២៦,១ |
| កំណើន (ភាគរយ) | ៣១,២ | ៣៤,៧ | -៤,៥ | ៨,១ | ១៩,៨ | -៤១,១ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី២០៖ ឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទៅតាមវិស័យ - តម្លៃ និងសមាមាត្រ

(ឆ្នាំ២០១៨-២០២៣)

| តម្លៃ (ទ្រីលានរៀល) | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| កសិកម្ម | ៤,៦ | ៥,៧ | ៥,៣ | ៥,៧ | ៦,៩ | ៤,៦ |
| កម្មន្តសាល | ០,១ | ០,២ | ០,៣ | ០,៥ | ០,៧ | ០,៦ |
| ពាណិជ្ជកម្ម និងការជួញដូរ | ៣,៨ | ៥,៤ | ៥,៨ | ៧,៣ | ៩,១ | ៤,៣ |
| សេវាកម្ម | ២,៤ | ៤,២ | ៤,៤ | ៤,៦ | ៥,៣ | ២,៤ |
| ដឹកជញ្ជូន | ១,១ | ១,៧ | ១,៦ | ១,៦ | ១,៧ | ០,៦ |

| | | | | | | |
|---|---|---|---|---|---|---|
| សំណង់ | ០,៩ | ១,០ | ១,១ | ១,៤ | ១,៨ | ១,៥ |
| អង្គភាពគ្រួសារ | ៨,០ | ១០,០ | ៨,៦ | ១០,៣ | ១២,៩ | ៦,៦ |
| ផ្សេងៗ | ០,៨ | ១,១ | ០,៥ | ០,៤ | ០,៥ | ០,៥ |
| សរុប | ២១,៨ | ២៩,៣ | ២៧,៥ | ៣១,៧ | ៣៨,៩ | ២១,០ |
| **សមាមាត្រ (ភាគរយ)** | **២០១៨** | **២០១៩** | **២០២០** | **២០២១** | **២០២២** | **២០២៣** |
| កសិកម្ម | ២១,១ | ១៩,៤ | ១៩,៣ | ១៧,៩ | ១៧,៨ | ២២,១ |
| កម្មន្តសាល | ០,៧ | ០,៨ | ១,០ | ១,៦ | ១,៨ | ៣,០ |
| ពាណិជ្ជកម្ម និងទំនិញ | ១៧,៦ | ១៨,៣ | ២០,៩ | ២៣,០ | ២៣,៣ | ២០,៣ |
| សេវាកម្ម | ១១,០ | ១៤,៤ | ១៦,០ | ១៤,៤ | ១៣,៦ | ១១,៤ |
| ដឹកជញ្ជូន | ៥,០ | ៥,៧ | ៥,៩ | ៥,២ | ៤,៤ | ២,៨ |
| សំណង់ | ៤,២ | ៣,៥ | ៣,៨ | ៤,៣ | ៤,៥ | ៧,០ |
| អង្គភាពគ្រួសារ | ៣៦,៧ | ៣៤,២ | ៣១,២ | ៣២,៤ | ៣៣,២ | ៣១,២ |
| ផ្សេងៗ | ៣,៨ | ៣,៦ | ១,៩ | ១,១ | ១,៣ | ២,៣ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី២១៖ អនុបាតក្របខ័ណ្ឌសន្ទនីយភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

(ភាគរយ, ឆ្នាំ២០១៨-២០២៣)

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| អនុបាតក្របខ័ណ្ឌសន្ទនីយភាពរបស់ MDI | ២១៣,៦ | ១៧៨,១ | ២៤០,៤ | ១៦០,១ | ១៥៦,៧ | ២៨៥,៨ |
| កម្រិតបទប្បញ្ញត្តិ | ៨០ | ៩០ | ១០០ | ១០០ | ១០០ | ១០០ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី២២៖ គុណភាពឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

(ឆ្នាំ២០១៨-២០២៣)

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| ឥណទានហួសកាលកំណត់ទូទាត់សង រយៈពេល ៣០ថ្ងៃ (ប៊ីលានរៀល) | ២៧៥,៥ | ២២៤,៣ | ៥០១,៩ | ៧៦៥,៤ | ៩៧៩,៩ | ១.៣៥៧,៣ |
| អនុបាតឥណទានមិនដំណើរការ (ភាគរយ) | ១,៣ | ០,៨ | ១,៨ | ២,៤ | ២,៥ | ៦,៥ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី២៣៖ ប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម និងមូលនិធិភាគទុនិក របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

(ភាគរយ, ឆ្នាំ២០១៨-២០២៣)

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| ប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម | ២,៧ | ២,៨ | ២,៨ | ២,៨ | ៣,០ | ១,៥ |
| មូលនិធិភាគទុនិក | ១៣,៥ | ១៤,៨ | ១២,៤ | ១២,៧ | ១៣,៦ | ៥,៩ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី២៤៖ ស្ថានភាពដើមទុនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

(ភាគរយ, ឆ្នាំ២០១៨-២០២៣)

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| កម្រិតបទប្បញ្ញត្តិ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ១៥ |
| អនុបាតសាធនភាព | ១៩,៨ | ១៨,៩ | ២២,៤ | ២១,៥ | ២០,៦ | ២៥,៧ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ឧបសម្ព័ន្ធទី៣

# ទីផ្សារមូលបត្រកម្មសិទ្ធិ

## ទីផ្សារគោល

(គិតជារៀលក្នុងមួយភាគហ៊ុន, ឆ្នាំ២០២៣)



























ប្រភព៖ ផ្សារមូលបត្រកម្ពុជា

## ទីផ្សារកំណើន

(គិតជារៀលក្នុងមួយភាគហ៊ុន, ឆ្នាំ២០២៣)







ប្រភព៖ ផ្សារមូលបត្រកម្ពុជា

## តារាងទី២៥៖ ទំហំមូលនិធិនាគទុនិកមូលធនទូបនីយកម្មទីផ្សារ

(ប៊ីលានរៀល, ឆ្នាំ២០១៨-២០២៣)

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| ធនាគារអេស៊ីលីដា (ABC) | - | - | ៧.៤០៧,១ | ៩.៥៥៦,៩ | ៩.៦៨៦,៨ | ៩.៣៣១,៦ |
| កំពង់ផែស្វយ័តក្រុងព្រះសីហនុ (PAS) | ៨៦៦,៣ | ១.៦៦៤,០ | ១.២៨០,០ | ១.១៩២,៥ | ១.១៩២,៥ | ១.០៨៩,០ |
| រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PPWSA) | ៣៦៥,៣ | ៥២១,៨ | ៥៣០,៥ | ៦២២,៧ | ៦៥៧,៥ | ៦៣៣,៧ |
| កំពង់ផែស្វយ័តក្រុងភ្នំពេញ (PPAP) | ១៥៨,៩ | ២៥៨,៦ | ២៤២,០ | ៣០៤,១ | ២៨៩,៦ | ២៨៩,៦ |
| ជេសថិក (ខេមបូឌា) ម.ក (PESTECH) | - | - | ២១៧,៣ | ២៣៦,១ | ២៣៦,១ | ២០៥,៣ |

ប្រភព៖ ផ្សារមូលបត្រកម្ពុជា

| | | | | | | |
|---|---|---|---|---|---|---|
| ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី (PPSP) | ២០៨,៤ | ១៨៥,៤ | ៨៤,៨ | ១៩៨,៨ | ១៧១,៨ | ១៥៦,៧ |
| ហ្គ្រេនធ្វីនអ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី (GTI) | ១៧២,៨ | ១៧៦,០ | ១២៨,០ | ១៦៨,៨ | ១៥២,០ | ១១៣,៦ |
| ម៉េងលី ជេ. គួច អេឌ្យូខេសិន (MJQE) | - | - | - | - | - | ៦៩០,០២ |
| ខេមជ្ជីអេសអេម (CGSM) | - | - | - | - | - | ៥.១៥២,៩ |
| ឌីប៊ីឌី អ៊ិនជីនារីង ម.ក (DBDE) | - | - | - | ១៤,៩ | ១៥,៤ | ១៣,៨ |
| ជេអេស លែន ភីអិលស៊ី (JSL) | - | - | - | - | ១២៧,៥ | ១១៣,១ |
| សរុប | ១.៧៧១,៧ | ២.៨០៥,៨ | ៩.៨២៧,៧ | ៧.១៩៤,៨ | ៧.៤៧៩,២ | ១២.៦៧៨,១ |

ប្រភព៖ ទីផ្សារមូលបត្រកម្ពុជា (CSX)

## តារាងទី២៦៖ មូលបត្ររដ្ឋ

(ខែឧសភា ឆ្នាំ២០២៣ - ខែធ្នូ ឆ្នាំ២០២៣)

| កាលបរិច្ឆេទបោះផ្សាយ | ឧសភា-២៣ | មិថុនា-២៣ | | កក្កដា-២៣ | សីហា-២៣ | | តុលា-២៣ | វិច្ឆិកា-២៣ | ធ្នូ-២៣ |
|---|---|---|---|---|---|---|---|---|---|
| បរិមាណមូលបត្ររដ្ឋសរុប (ឯកតា) | ៤.០០០ | ៤.០០០ | ៤.០០០ | ៨.០០០ | ២៨.០០០ | ៨.០០០ | ២០.០០០ | ២៨.០០០ | ៦.០០០ |
| តម្លៃចារឹក | ១.០០០.០០០ | ១.០០០.០០០ | ១.០០០.០០០ | ១.០០០.០០០ | ១.០០០.០០០ | ១.០០០.០០០ | ១.០០០.០០០ | ១.០០០.០០០ | ១.០០០.០០០ |
| តម្លៃបោះផ្សាយ | ១.០០០.០០០ | ៩៨៦.២៣០ | ១.០០០.០០០ | ៩៩៨.៨៣២ | ៩៩៥.២៥៥ | ៩៨០.៧៨៦ | ៩៩៦.៨៨៩ | ៩៩៤.៣០៩ | ១.០០០.០០០ |
| ឥណប្រតិទាន | ២ ឆ្នាំ | ៣ ឆ្នាំ | ៥ ឆ្នាំ | ១ ឆ្នាំ | ២ ឆ្នាំ | ៣ ឆ្នាំ | ១ ឆ្នាំ | ២ ឆ្នាំ | ៣ ឆ្នាំ |
| អត្រាគូប៉ុង | ៤,០ | ៤,៥ | ៤,០ | ៣,៤៨ | ៤,០ | ៤,៥ | ៣,៨ | ៤,០ | ៤,៥ |
| អត្រាការប្រាក់ (ភាគរយក្នុង ១ ឆ្នាំ) | ៤,០ | ៥,០ | ៤,០ | ៣,៦ដល់ ៤,៣ | ៤,២៥ដល់ ៤,៣០ | ៥,២០ | ៣,៨០ដល់ ៣,៩០ | ៤,៣០ដល់ ៤,៦០ | ៤,៥០ |
| ចំនួនដងនៃការទូទាត់គូប៉ុង | ២ ដង | ២ ដង | ២ ដង | ២ ដង | ២ ដង | ២ ដង | ២ ដង | ២ ដង | ២ ដង |

ប្រភព៖ ទីផ្សារមូលបត្រកម្ពុជា (CSX)

## តារាងទី២៧៖ វិស័យធានារ៉ាប់រង

(២០១៩-២០២៣)

ទ្រព្យសកម្មសរុប

| ប៊ីលានរៀល | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ធានារ៉ាប់រងទូទៅ | ២៤៦.៩៩៤,៣ | ២៧៦.៣១៦,៧ | ២៩៣.៦៣២,៩ | ៣០៨.៩៧៦,៩ | ៣០៧.៤០០,៤ |
| ធានារ៉ាប់រងអាយុជីវិត | ៣៤៤.៦២២,៤ | ៤៦១.៤២៩,៦ | ៥៥១.៧៥៩,០ | ៦៦២.៧៦៣,៤ | ៧៦៤.១៧១,៨ |
| ធានារ៉ាប់រងខ្នាតតូច | ៦.០៤៨,៣ | ៣.២៥៧,០ | ៥.២៥០,៨ | ៥.២៤៦,៨ | ៨.៦៣០,៣ |
| សរុប | ៥៩៧.៦៦៥,១ | ៧៤១.៥០៣,២ | ៨៥០.៦៤២,៧ | ៩៧៦.៩៨៧,១ | ១.០៨០.២០២,៥ |

| សមាមាត្រ (ភាគរយ) | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ធានារ៉ាប់រងទូទៅ | ៤១,៣ | ៣៧,៣ | ៣៤,៥ | ៣១,៦ | ២៨,៥ |
| ធានារ៉ាប់រងអាយុជីវិត | ៥៧,៧ | ៦២,៣ | ៦៤,៩ | ៦៧,៨ | ៧០,៧ |
| ធានារ៉ាប់រងខ្នាតតូច | ១,០ | ០,៤ | ០,៦ | ០,៥ | ០,៨ |

បុព្វលាភសរុប

| ប៊ីលានរៀល | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ធានារ៉ាប់រងទូទៅ | ៤១០,៨ | ៤៦៦,៨ | ៥០២,៧ | ៥៤០,៩ | ៥៨៧,១ |
| ធានារ៉ាប់រងអាយុជីវិត | ៥៨៥,១ | ៦២៥,៤ | ៧០០,១ | ៧៩២,២ | ៧៧៩,៧ |
| ធានារ៉ាប់រងខ្នាតតូច | ២៨,៦ | ២០,៥ | ១៦,៨ | ២៣,៤ | ២៩,៣ |
| សរុប | ១.០២៤,៦ | ១.១១២,៧ | ១.២១៩,៦ | ១.៣៥៦,៤ | ១.៣៩៦,០ |

បុព្វលាភធានារ៉ាប់រងទូទៅ

| ប៊ីលានរៀល | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| យានយន្ត | ៧៦,៦ | ៨៥,៨ | ៨៧,៩ | ៩៦,៦ | ៩៨,៣ |
| ទ្រព្យសម្បត្តិ | ១១៩,០ | ១៥២,៩ | ១៥២,៩ | ១៨៤,៨ | ២០០,៧ |
| MAT | ១៥,៧ | ១១,៧ | ១៧,៣ | ៣០,៥ | ៣៤,៧ |
| វិស្វកម្ម | ៤១,៥ | ៣៤,៨ | ៣៦,៨ | ២៤,៤ | ៣៨,៩ |
| គ្រោះថ្នាក់បុគ្គល | ២៤,២ | ២០,៨ | ២៣,៣ | ២៨,១ | ២៩,២ |
| សុខភាព | ៧៤,៤ | ៨៨,១ | ១០៩,៩ | ១២៥,៨ | ១២៩,៤ |
| ផ្សេងៗ | ៥៩,៤ | ៧២,៦ | ៧៤,៦ | ៥០,៩ | ៥៥,៣ |

| | | | | | |
|---|---|---|---|---|---|
| សរុប | ៤១០,៨ | ៤៦៦,៨ | ៥០២,៧ | ៥៤០,៩ | ៥៨៦,៦ |
| **សមាមាត្រ (ភាគរយ)** | **២០១៩** | **២០២០** | **២០២១** | **២០២២** | **២០២៣** |
| យានយន្ត | ១៨,៧ | ១៨,៤ | ១៧,៥ | ១៧,៨ | ១៦,៨ |
| ទ្រព្យសម្បត្តិ | ២៩,០ | ៣២,៨ | ៣០,៤ | ៣៤,២ | ៣៤,២ |
| យន្តហោះ នាវា និងការដឹកជញ្ជូន | ៣,៨ | ២,៥ | ៣,៤ | ៥,៦ | ៥,៩ |
| វិស្វកម្ម | ១០,១ | ៧,៥ | ៧,៣ | ៤,៥ | ៦,៦ |
| គ្រោះថ្នាក់បុគ្គល | ៥,៩ | ៤,៥ | ៤,៦ | ៥,២ | ៥,០ |
| សុខភាព | ១៨,១ | ១៨,៩ | ២១,៩ | ២៣,៣ | ២២,១ |
| ផ្សេងៗ | ១៤,៥ | ១៥,៦ | ១៤,៨ | ៩,៤ | ៩,៤ |

**បុព្វលាភធានារ៉ាប់រងអាយុជីវិត**

| ប៊ីលានរៀល | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| មានកាលកំណត់ | ៧៣,១ | ៨៩,២ | ១២៤,០ | ១៥៣,៧ | ១៦១,១ |
| ពេញមួយជីវិតកាល | ២,២ | ៤,៥ | ៥,០ | ៣,២ | ៤,៩ |
| ទាយជ្ជទាន | ៥០៦,២ | ៥២៥,១ | ៥៦០,២ | ៦៣២,៦ | ៦១៣,៣ |
| ផ្សេងៗ | ៣,៦ | ៦,៥ | ១១,០ | ២,៦ | ០,៣ |
| សរុប | ៥៨៥,១ | ៦២៥,៤ | ៧០០,១ | ៧៩២,២ | ៧៧៩,៧ |
| **សមាមាត្រ (ភាគរយ)** | **២០១៩** | **២០២០** | **២០២១** | **២០២២** | **២០២៣** |
| មានកាលកំណត់ | ១២,៥ | ១៤,៣ | ១៧,៧ | ១៩,៤ | ២០,៧ |
| ពេញមួយជីវិតកាល | ០,៤ | ០,៧ | ០,៧ | ០,៤ | ០,៦ |
| ទាយជ្ជទាន | ៨៦,៥ | ៨៤,០ | ៨០,០ | ៧៩,៩ | ៧៨,៧ |
| ផ្សេងៗ | ០,៦ | ១,០ | ១,៦ | ០,៣ | ០,០៣ |

**បុព្វលាភធានារ៉ាប់រងខ្នាតតូច**

| ប៊ីលានរៀល | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| សុខភាព | ១១,២ | ៧,៤ | ៤,៥ | ៣,៩ | ៣,៤ |
| គ្រោះថ្នាក់បុគ្គល | ៣,៤ | ៣,១ | ២,៣ | ៨,២ | ១២,៨ |
| មានកាលកំណត់ | ១០,១ | ៧,៧ | ៦,៧ | ២,២ | ៤,២ |
| ផ្សេងៗ | ៣,៩ | ២,៣ | ៣,២ | ៩,០ | ៨,៩ |
| សរុប | ២៨,៦ | ២០,៥ | ១៦,៨ | ២៣,៤ | ២៩,៣ |

| សមាមាត្រ (ភាគរយ) | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| សុខភាព | ៣៩,១ | ៣៦,១ | ២៦,៩ | ១៦,៧ | ១១,៦ |
| គ្រោះថ្នាក់បុគ្គល | ១២,០ | ១៥,២ | ១៣,៨ | ៣៥,៣ | ៤៣,៨ |
| មានកាលកំណត់ | ៣៥,២ | ៣៧,៥ | ៤០,១ | ៩,៣ | ១៤,៣ |
| ផ្សេងៗ | ១៣,៧ | ១១,២ | ១៩,២ | ៣៨,៧ | ៣០,៣ |

ប្រភព៖ និយ័តករធានារ៉ាប់រងកម្ពុជា

**ឧបសម្ព័ន្ធទី៤**

## តារាងទី២៨៖ ទំហំទឹកប្រាក់នៃការទូទាត់រាយតាមប្រព័ន្ធអេឡិចត្រូនិក

(ទ្រីលានរៀល, ឆ្នាំ២០១៩-២០២៣)

| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ការទូទាត់ជាប្រាក់រៀល | ៥៨,៩ | ៨៩,០ | ១៣៧,៣ | ១៩៧,២ | ២៦៤,៨ |
| ការទូទាត់ជាប្រាក់ដុល្លារអាមេរិក | ២៨៥,២ | ៤២៩,៤ | ៦៨៧,៩ | ៩១៣,៤ | ៩៩៣,៦ |
| ទំហំទឹកប្រាក់សរុប | ៣៤៤,១ | ៥១៨,៣ | ៨២៥,២ | ១.១១០,៦ | ១.២៥៨,៤ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី២៩៖ ចំនួនគណនីកាបូបអេឡិចត្រូនិក និងអតិថិជន Walk-in

(លានគណនី, ឆ្នាំ២០១៩-២០២៣)

| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| គណនីកាបូបអេឡិចត្រូនិក | ៥,២ | ៩,៦ | ១៣,៦ | ១៩,៥ | ១៩,៧ |
| អតិថិជន Walk-in | ៤៤,៧ | ៥៦,៥ | ១០៦,២ | ១៣៥,៦ | ១៥០,៦ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី៣០៖ ទំហំទឹកប្រាក់និងចំនួនប្រតិបត្តិការនៃការទូទាត់ តាមគណនីកាបូបអេឡិចត្រូនិក

(ទ្រីលានរៀល, ឆ្នាំ២០១៩-២០២៣)

| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ការទូទាត់ជាប្រាក់រៀល | ៤៩,៨ | ៧០,៧ | ៨៨,៥ | ១១៩,៩ | ២០១,០ |
| ការទូទាត់ជាប្រាក់ដុល្លារអាមេរិក | ៩១,៤ | ៩៨,១ | ១០៩,៦ | ១៥០,២ | ២៥៧,៩ |
| ទំហំទឹកប្រាក់សរុប | ១៤១,២ | ១៦៨,៩ | ១៩៨,១ | ២៧០,១ | ៤៥៨,៩ |
| ចំនួនប្រតិបត្តិការសរុប (គិតជាលាន) | ១៩៨,៩ | ២៥៨,៧ | ៣៤៣,៨ | ៤៦៧,៤ | ៨១១,០ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី៣១៖ ទំហំទឹកប្រាក់នៃសេវាធនាគារអ៊ីនធឺណិត និងសេវាធនាគារចល័ត

(ទ្រីលានរៀល, ឆ្នាំ២០១៩-២០២៣)

| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| សេវាធនាគារអ៊ីនធឺណិត | ៩១,៦ | ៩៧,២ | ៩០,១ | ៨០,១ | ៧៤,៥ |
| សេវាធនាគារចល័ត | ១១៤,០ | ២៣២,១ | ៤៥២,៩ | ៦៧២,៤ | ៧៤៦,៧ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី៣២៖ ការប្រើប្រាស់ប័ណ្ណទូទាត់

(ទ្រីលានរៀល, ឆ្នាំ២០១៩-២០២៣)

| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ការទូទាត់ជាប្រាក់រៀល | ៣,២ | ៨,០ | ១២,៨ | ២២,៤ | ៥៥,១ |
| ការទូទាត់ជាប្រាក់ដុល្លារអាមេរិក | ៤៤,១ | ៦២,២ | ៧១,៣ | ៧៥,៧ | ៧៤,១ |
| ទំហំទឹកប្រាក់សរុប | ៤៧,៣ | ៧០,២ | ៨៤,១ | ៩៨,០ | ១២៩,២ |
| ចំនួនប្រតិបត្តិការសរុប (គិតជាលាន) | ៧៤,៤ | ៩៧,៣ | ១០៥,៣ | ១១៩,៧ | ១៨១,៥ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី៣៣៖ ការទូទាត់តាមប្រព័ន្ធបាគង

(ទ្រីលានរៀល, ឆ្នាំ២០២០-២០២៣)

| | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|
| ការទូទាត់ជាប្រាក់រៀល | ០,១ | ៤,២ | ២៣,៥ | ៨១,១ |
| ការទូទាត់ជាប្រាក់ដុល្លារអាមេរិក | ០,២ | ១៩,០ | ៨៩,៨ | ២២១,០ |
| ទំហំទឹកប្រាក់សរុប | ០,៣ | ២៣,២ | ១១៣,៣ | ៣០២,០ |
| ចំនួនប្រតិបត្តិការសរុប (គិតជាលាន) | ០,២ | ៨,២ | ៤០,៤ | ២០០,៩ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី៣៤៖ ការទូទាត់តាមយន្តអេឡិចត្រូនិក

(ឆ្នាំ២០១៩-២០២៣)

| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ទំហំទឹកប្រាក់សរុប (ប៊ីលានរៀល) | ៨៣,៥ | ២៩៨,១ | ៩៥៣,៧ | ១៣.៦៤៣,៣ | ៩៥.៧៨២,១ |
| ចំនួនប្រតិបត្តិការសរុប (គិតជាលាន) | ២,១ | ៤,៨ | ៤,៤ | ២៣,៣ | ១៧៧,៩ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា



បោះពុម្ពដោយ ធនាគារជាតិ នៃកម្ពុជា